ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ២ | មេសា - មិថុនា ឆ្នាំ២០០៩ | តម្លៃ ១.៥០០៛

# សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៩ "ប្រទេសកម្ពុជា និង វិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព"*


ភ្ញៀវទេសចរចូលមកប្រទេសកម្ពុជា តាមច្រកព្រំដែនប៉ោយប៉ែត

សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៣ ដែលផ្ដោតលើប្រធានបទ "ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព" បានប្រារព្ធធ្វើនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ១២ មីនា ២០០៩ ក្រោមកិច្ចសហការជាដៃគូររវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal ។ ក្នុងសុន្ទរកថាគន្លឹះបើកសន្និសីទ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ប្រាប់ភ្ញៀវកិត្តិយសទាំង ៣៥០នាក់ថា "នេះជាព្រឹត្តិការណ៍ដ៏វិសេសមួយនៅប្រទេសកម្ពុជា ដែលជារៀងរាល់ឆ្នាំ សន្និសីទនេះបានអញ្ជើញថ្នាក់ដឹកនាំមកពីខាង រដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ សង្គមស៊ីវិល និងសហគមន៍អភិវឌ្ឍន៍អន្តរជាតិ មកជួបប្រជុំគ្នា ដើម្បីពិចារណាលើសមិទ្ធផល និងអនាគតរបស់ប្រទេសកម្ពុជា ។ កាលបរិច្ឆេទ និងប្រធានបទសន្និសីទចក្ខុវិស័យនាឆ្នាំនេះ មានសារៈសំខាន់ជាពិសេស ពីព្រោះយើងកំពុងទទួលរងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងតំបន់ និងក្នុងពិភពលោក និងកំពុងប្រឹងប្រែងដោះស្រាយវិបត្តិទាំងនេះ ។"

សន្និសីទឆ្នាំ២០០៩ រួមមានវគ្គមួយចំនួនស្ដីពី វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ដល់តំបន់យើង និងប្រទេសកម្ពុជា, ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា - ការកសាងកំលាំងពលកម្មមានជំនាញ, ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ - ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំនើនទៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ, អាទិភាពសំរាប់គោលនយោបាយ និងការធ្វើសកម្មភាពដោយរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ ស្ថាប័នខាងស្រាវជ្រាវ និងគោលនយោបាយ ។

ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខពិសេសនេះ មានចុះផ្សាយអត្ថបទនានាស្ដីពីបទបង្ហាញ និងការពិភាក្សាទាំងឡាយ នៅក្នុងសន្និសីទ ។ វិទ្យាស្ថានក៏មានចេញផ្សាយ អត្ថបទសង្ខេបចក្ខុវិស័យប្រទេសកម្ពុជា មួយឈុត ជាភាសាខ្មែរ និងអង់គ្លេសផងដែរ ។ ម្យ៉ាងទៀត កម្មវិធីទាំងមូល បទបង្ហាញនានា និងឯកសារជាប់ទាក់ទងនឹងសន្និសីទទាំងអស់ មានចុះនៅក្នុងវេបសាយ របស់ CDRI ៕

* Larry Strange នាយកប្រតិបត្តិ CDRI ណែនាំបង្ហាញពីទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា លេខពិសេសនេះដែលផ្ដោតលើសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។

## មាតិកា

ប្រទេសកម្ពុជា និងវិបត្តិសាកលៈ សន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ........ ២
វិបត្តិសាកល — ផលប៉ះពាល់ ចក្ខុវិស័យ... សំរាប់កម្ពុជា........ ៤
វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ក្នុងតំបន់........ ៧
ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើផ្នែកវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា........ ១១
ផលប៉ះពាល់ជាសក្ដានុពលនៃវិបត្តិហិរញ្ញវត្ថុទៅលើគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះនៅកម្ពុជា........ ១៣
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — កសិកម្ម........ ១៦
វិបត្តិអាហារ និងហិរញ្ញវត្ថុ — ផលប៉ះពាល់លើវិស័យកសិកម្ម........ ១៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ទេសចរណ៍........ ២៣
ការគ្រប់គ្រងវិបត្តិសាកល — ទេសចរណ៍នៅប្រទេសកម្ពុជា និងក្នុងតំបន់........ ២៦
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ហេដ្ឋារចនាសម្ព័ន្ធ........ ២៩
ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — អចលនទ្រព្យ........ ៣៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស........ ៣៦
— ស្ថានភាពក្នុងប្រទេស........ ៣៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ........ ៤៤

# ប្រទេសកម្ពុជា និងវិបត្តិសាកលៈ ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព — សន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩*

សន្និសីទចក្ខុវិស័យនៅឆ្នាំនេះ បានរៀបចំឡើងទាន់ពេលវេលា ហើយប្រធានបទដែលលើកឡើងនៅពេលនេះ មានសារៈសំខាន់ និងចំពេលវេលាដែលយើងទាំងអស់គ្នាកំពុងជួបនឹងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរិះរកវិធីសាស្ត្រ ដើម្បីឆ្លើយតបឱ្យបានស័ក្តិសម និងមានប្រសិទ្ធភាព ។ វិបត្តិនេះ មិនមែនកើតចេញពីកម្ពុជាទេ ។ វាកើតឡើងដោយកត្តាខាងក្រៅដែលហួសពីកំលាំងគ្រប់គ្រងរបស់កម្ពុជា ប៉ុន្តែជះឥទ្ធិពលយ៉ាងខ្លាំងមកលើយើងទាំងអស់គ្នា ។

## សមិទ្ធិផលក្នុងពេលកន្លងមកៈ កំណើន និង ការកាត់បន្ថយភាពក្រីក្រ

កម្ពុជាមានភ័ព្វសំណាង ដោយត្រូវប្រឈមមុខនឹងវិបត្តិ នៅចំពេលដែលសេដ្ឋកិច្ចរបស់ខ្លួនកំពុងមានសន្ទុះខ្លាំងនៅឡើយ ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចល្អប្រសើរក្នុងពេញមួយទសវត្សរ៍កន្លងមក ។ ការសិក្សាមួយរបស់ធនាគារពិភពលោកនាពេលថ្មីៗនេះ បានដាក់បញ្ចូលកម្ពុជាក្នុងចំណោម ១០ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ជាងគេ គិតពីឆ្នាំ១៩៩៨ ដល់ ២០០៧ ដោយកម្ពុជាមានអត្រាកំណើនជាមធ្យមជាលេខពីរខ្ទង់ ក្នុងមួយទសវត្សរ៍កន្លងមក ។ ទន្ទឹមគ្នានេះ កម្ពុជាបានកាត់បន្ថយយ៉ាងច្រើននូវភាពក្រីក្រពី ៤៥% នៅឆ្នាំ ១៩៩៤ មកនៅត្រឹម ៣០% នៅឆ្នាំ២០០៨ ។

ជោគជ័យល្អវិសេសក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនេះ អាចសម្រេចបានតាមរយៈ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ព្រមទាំងសន្ទុះលូតលាស់របស់វិស័យឯកជន និងការខិតខំប្រឹងប្រែង និងផលិតភាពរបស់ប្រជាជនកម្ពុជា ។ ប្រទេសកម្ពុជា បានជឿនលឿនទៅមុខយ៉ាងច្រើន ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពាន ធារាសាស្ត្រ ការដឹកជញ្ជូន និងទូរគមនាគមន៍ និងក្នុងការជំរុញស្តង់ដារពលកម្មអន្តរជាតិ នៅក្នុងឧស្សាហកម្មកាត់ដេរ ការជំរុញវិស័យទេសចរណ៍ និងការពង្រឹងបរិយាកាសវិនិយោគមានសម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិនិយោគ ។ ទោះបីនៅកម្ពុជា វិស័យធនាគារមានទំហំតូចក្តី ប៉ុន្តែបានរីកចម្រើនគួរឱ្យកត់សម្គាល់ និងទទួលរងផលប៉ះពាល់មិនសូវខ្លាំងទេពីវិបត្តិហិរញ្ញវត្ថុពិភពលោក ។ វិស័យនេះមានការគ្រប់គ្រងយ៉ាងហ្មត់ចត់ពីធនាគារជាតិនៃកម្ពុជា និងទទួលបានការជឿទុកចិត្តពីសំណាក់រដ្ឋាភិបាល វិស័យឯកជន និងប្រជាជនគ្រប់ស្រទាប់ ។

កន្លងមក កម្ពុជាអាចប្រើប្រាស់ចំណុចខ្លាំងរបស់ខ្លួនបាន ។ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាធ្វើការគ្រប់គ្រង និងទាញយកផលពីធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេស ប្រកបដោយទំនួលខុសត្រូវខ្ពស់ ដើម្បីបានផលចំណេញជាអតិបរមាដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ការបង្កើនចំណូលជូនប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ និងដើម្បីដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងអភិបាលកិច្ច ការគ្រប់គ្រង ការដោះស្រាយទំនាស់ ទំនួលខុសត្រូវរបស់ក្រុមហ៊ុន និងការគ្រប់គ្រងបរិស្ថាន ។ រដ្ឋាភិបាលក៏ប្តេជ្ញាបន្តអនុវត្តវិធីសាស្ត្រមានតុល្យភាពល្អ សំដៅជំរុញការប្រើប្រាស់ដីប្រកបដោយផលិតភាពជាពិសេសការប្រើប្រាស់ដីនៅតាមតំបន់ជនបទ សម្រាប់ការអភិវឌ្ឍកសិកម្ម និងជនបទ និងការកាត់បន្ថយភាពក្រីក្រ ។ រដ្ឋាភិបាលក៏បង្ហាញពីជំហរព្យាយាមឆ្លើយតបតាមតម្រូវការរបស់វិស័យឯកជន ហើយរឿងនេះសំខាន់ខ្លាំងណាស់សំរាប់វិស័យត្រូវអភិវឌ្ឍន៍ជាអាទិភាព ដូចជា ពិពិធកម្មសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ថាមពល ទូរគមនាគមន៍ និងសេវាកម្មហិរញ្ញវត្ថុ ។ តាមរយៈគំនិតផ្តួចផ្តើមផ្សេងៗ ដូចជា វេទិការដ្ឋាភិបាលជាមួយវិស័យឯកជន គោលនយោបាយចំហជើងមេឃ និងគោលនយោបាយវិនិយោគ ជាដើម រដ្ឋាភិបាលបានជួយគាំទ្រ និងលើកស្ទួយសមត្ថភាពរបស់វិស័យឯកជនឱ្យរីកលូតលាស់ និងអាចប្រកួតប្រជែងនៅទីផ្សារក្នុងតំបន់ និងពិភពលោក ។

## វិបត្តិសាកលៈ ផលប៉ះពាល់ និងការឆ្លើយតប

ដោយសារតែស្ថានភាពមិនអំណោយផលផុសចេញពីវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងឆ្នាំ២០០៨ មានប្រមាណ ៧% ប៉ុណ្ណោះ ធៀបនឹងកំណើនជាមធ្យមជាង ១០% ក្នុងមួយឆ្នាំ ក្នុងរយៈពេលបួនឆ្នាំបន្តបន្ទាប់មុននេះ ហើយតាមការព្យាករណ៍ កំណើនក្នុងឆ្នាំ២០០៩ នឹងបន្តធ្លាក់ចុះទៀត ។ ក្នុងស្ថានភាពដ៏លំបាកនេះ រដ្ឋាភិបាលបានចាត់វិធានការណ៍ជាប្រព័ន្ធ និងជាខ្សែសង្វាក់ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពរឹងមាំនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងជំរុញកំណើនតាមរយៈវិធានការសារពើពន្ធ និងការជួយសម្រួលពាណិជ្ជកម្ម និងវិនិយោគ ។ រដ្ឋាភិបាលក៏ផ្តោតផងដែរលើការពង្រឹងបន្ថែមនូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ ។

ទោះបីរដ្ឋាភិបាល បានដាក់អនុវត្តវិធានការមួយចំនួនដើម្បីដោះស្រាយឥទ្ធិពលវាក៏ដោយ ក៏វិបត្តិនៅតែកើតមានជាបន្តទៀតដែរ ។ វិបត្តិនេះមានផលប៉ះពាល់ទៅលើវិស័យសេដ្ឋកិច្ចសំខាន់ៗ ធ្វើឱ្យអត្រាកំណើនខាងកាត់ដេរ ទេសចរណ៍ និងសំណង់ ជាដើម ធ្លាក់ចុះអស់ ១៥-២០% ហើយជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចទាំងមូល និងប្រជាជនកម្ពុជា ។ ប្រការនេះមានន័យថា គ្រប់ៗគ្នាត្រូវប្រឹងប្រែងច្រើនថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមធំៗមួយចំនួន (ប្រអប់ ១) ។

វិធានការឆ្លើយតបនឹងវិបត្តិនេះ ត្រូវរៀបចំឱ្យបានសក្តិសិទ្ធិ ដើម្បីជួយការពារ និងគាំទ្រដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ជាពិសេសអ្នកដែលបានបាត់បង់ការងារដោយសារការធ្លាក់ចុះនៃវិស័យនាំចេញ (ដូចជា កាត់ដេរ កម្មន្តសាល សំណង់ ទេសចរណ៍) ពលករធ្វើចំណាកស្រុកទៅប្រទេសជិតខាងដែលត្រូវចូលមកកម្ពុជាវិញ គ្រួសារក្រីក្រនៅទីជនបទដែលបានថយចុះប្រាក់ចំណូល និងកើនបន្ទុកចំណាយដោយសារមានសមាជិកគ្រួសារវិលត្រលប់មកពីទីក្រុងព្រោះមិនមានការងារធ្វើ សហគ្រាសខ្នាតតូចនិងមីក្រូ ជាអ្នកផ្តល់សេវានៅទីប្រជុំជនជួយទ្រទ្រង់ដល់ឧស្សាហកម្មនានាដែលត្រូវប៉ះពាល់ជាអវិជ្ជមានដោយសារវិបត្តិ ប្រជាជនក្រីក្រស្រាប់ដែលជាអ្នកមានការងារធ្វើ ឬមានការងារធ្វើមិនពេញលេញ និងដែលបានបាត់បង់ឱកាសល្អដោយសារសកម្មភាពសេដ្ឋកិច្ចរួមចុះ ព្រមទាំងពួកយុវជនដែលឈានចូលមកក្នុងទីផ្សារការងារចំពេលសេដ្ឋកិច្ចរួមចុះ និងមានឱកាស

* អត្ថបទនេះ ជាសេចក្តីសង្ខេបសុន្ទរកថាគន្លឹះបើកសន្និសីទ ថ្លែងដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

ការងារតិចតួច ។ ចំពោះក្រុមជនងាយរងគ្រោះទាំងអស់នេះ យើងមានកាតព្វកិច្ចធ្វើយ៉ាងណា ឱ្យការឆ្លើយតបរបស់យើងចំពោះវិបត្តិ មានភាពសមស្របតាមតម្រូវការរបស់ពួកគេ ។

បញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានមិនត្រឹមតែកិច្ចសហប្រតិបត្តិការដ៏សក្តិសិទ្ធិ និងសកម្មរវាងរដ្ឋាភិបាល គ្រប់ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការសម្របសម្រួល និងកិច្ចសហការដ៏សក្តិសិទ្ធិនៅក្នុង និងរវាងក្រសួងមន្ទីររបស់រដ្ឋាភិបាល និងសហគមន៍អ្នកអភិវឌ្ឍន៍ទៀតផង ។ ក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម និងអភិវឌ្ឍន៍ជនបទ ជាដើម ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការស្រោចស្រពនិងគ្រប់គ្រងធនធានទឹក ការជួយសម្រួលពាណិជ្ជកម្ម ការប្រស្រ័យទាក់ទង និងសហប្រតិបត្តិការកាន់តែប្រសើររវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នានា ទាំងអស់នេះគឺចាំបាច់បំផុត ដើម្បីធានាថា កម្មវិធីអភិវឌ្ឍន៍នានារចនារៀបចំបានល្អ អនុវត្តបានលឿននិងមានប្រសិទ្ធភាព ហើយធនធានសំរាប់ជួយទ្រទ្រង់របស់ដៃគូអភិវឌ្ឍន៍នានា ត្រូវបានបើកផ្តល់ជាក់ស្តែង និងឆាប់រហ័ស ។ ការងារទាំងនេះ មិនមែនងាយស្រួលទេ ប៉ុន្តែលក្ខណៈធ្ងន់ធ្ងរនៃវិបត្តិតម្រូវឱ្យយើងធ្វើការរួមគ្នាទាំងអស់គ្នា ។

គេតែងនិយាយថា "វិបត្តិតែងតែដើរទន្ទឹមគ្នានឹងឱកាសល្អ" ។ វិបត្តិហិរញ្ញវត្ថុសាកលនាពេលបច្ចុប្បន្ន បានផ្តល់ឱកាសល្អសម្រាប់ឱ្យកម្ពុជា ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មក្នុងតំបន់ ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមាពីការពង្រីកទីផ្សារតំបន់ ក៏ដូចជា ការពង្រីកពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់ ដែលជាកត្តាសំខាន់សម្រាប់ជួយកាត់បន្ថយការពឹងផ្អែកខ្លាំងពេក ទៅលើទីផ្សារខាងក្រៅ និងសម្រាប់បង្កើនសមត្ថភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគពីខាងក្រៅតំបន់ថែមទៀត ។

កម្ពុជា ត្រូវធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយ ប្រទេសជិតខាងក្នុងមហាអនុតំបន់មេគង្គ សមាជិកអាស៊ាន និងដៃគូនានានៅក្នុងតំបន់ ដូចជា ចិន កូរ៉េខាងត្បូង និងជប៉ុន ដើម្បីស្វែងរកដំណោះស្រាយ និងយុទ្ធសាស្ត្រក្នុងតំបន់សំរាប់ជួយទប់ទល់នឹងវិបត្តិ និងធ្វើឱ្យតំបន់មានភាពរឹងមាំ អាចធន់ទ្រាំបានល្អនឹងវិបត្តិផ្សេងៗនាពេលអនាគត ។ កម្ពុជា ត្រូវធ្វើការរួមគ្នាជាមួយសមាជិកអាស៊ានឯទៀតៗ ដើម្បីលើកកម្ពស់ពាណិជ្ជកម្មសេរីក្នុងតំបន់ បណ្តាញផលិតកម្ម និងចំណាយប្រើប្រាស់ ដើម្បីបង្កើតយុទ្ធសាស្ត្រជាក់លាក់សំដៅញុំាងឱ្យការប្តេជ្ញាចិត្តផ្សេងៗនៅក្នុងធម្មនុញ្ញអាស៊ាន អនុវត្តបានសំរេច ដើម្បីកាត់បន្ថយគម្លាតកំរិតអភិវឌ្ឍន៍នៅក្នុងអាស៊ាន និងដើម្បីអនុវត្តគំនិតផ្តួចផ្តើមឈៀងម៉ៃ សំដៅពង្រឹងយន្តការ និងស្ថាប័នហិរញ្ញវត្ថុក្នុងតំបន់សំរាប់ជួយគាំទ្រដល់កំណើន និងការអភិវឌ្ឍន៍ និងការពារបណ្តាប្រទេសអាស៊ីខាងកើតទប់ទល់នឹងការប៉ះទង្គិចផ្សេងៗពីខាងក្រៅនាពេលអនាគត ។

ក្នុងបរិការណ៍សេដ្ឋកិច្ចសាកល កម្ពុជាគាំទ្រចំពោះប្រទេសកំពុងអភិវឌ្ឍន៍ធំៗគឺ ចិន ឥណ្ឌា និងឥណ្ឌូនេស៊ី ដែលអាចនិយាយក្នុងនាមប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ ដើម្បីធានាឱ្យមានការកសាងយុទ្ធសាស្ត្រដ៏សក្តិសិទ្ធិក្នុងតំបន់ និងពិភពលោក សំរាប់ឆ្លើយតបនឹងវិបត្តិ ធានាឱ្យមានការប្តេជ្ញាចិត្តកាន់តែមុតមាំលើការកាត់បន្ថយគម្លាតកំរិតអភិវឌ្ឍន៍ លើការអនុវត្តការប្តេជ្ញាចិត្តផ្តល់ជំនួយអភិវឌ្ឍន៍របស់ប្រទេសអភិវឌ្ឍន៍ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការបើកផ្តល់ថវិកាទាន់ពេលវេលា និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍នានា និងលើការជឿនលឿនទៅមុខឥតឈប់នៃកំណែទម្រង់ជាបន្ទាន់នូវស្ថាប័នហិរញ្ញវត្ថុសំខាន់ៗ ដើម្បីឱ្យស្ថាប័នទាំងនោះដំណើរការកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបតាមតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ។

បញ្ហាសំខាន់ៗផ្សេងទៀតដែលផុសចេញពីបទពិសោធន៍របស់កម្ពុជាក្នុងការទប់ទល់នឹងវិបត្តិ ក៏គួរយកមកពិចារណាយ៉ាងល្អិតល្អន់ដែរ ដូចជា ១-តើកម្ពុជា និងប្រទេសក្នុងតំបន់ អាចតាមដានយ៉ាងណាពីផលប៉ះពាល់នៃវិបត្តិ ដើម្បីបង្កើតយុទ្ធសាស្ត្រឆ្លើយតប ជាពិសេសសម្រាប់ជួយជនក្រីក្រ និងជនងាយទទួលរងគ្រោះ ២-តើរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នអប់រំ អាចធ្វើការជាមួយគ្នាបែបណា ដើម្បីឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ជាពិសេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់កសាងកម្លាំងពលកម្មជំនាញ ៣-តើមានយុទ្ធសាស្ត្រអ្វីខ្លះ សំរាប់ឱ្យកម្ពុជាគ្រប់គ្រងបានល្អបំផុតលើដំណើរការឆ្លងកាត់វិបត្តិ និងការពារពង្រឹងវិស័យគន្លឹះៗដែលជំរុញកំណើន និងការអភិវឌ្ឍនៅកម្ពុជា គឺមានកសិកម្ម ការអភិវឌ្ឍជនបទ ទេសចរណ៍ កម្មន្តសាលកម្ម អចលនទ្រព្យ និងសំណង់ ៤-តើមានគោលនយោបាយ និងសកម្មភាពជាអាទិភាពអ្វីខ្លះ ដែលគួរដាក់ចូលក្នុងផែនការអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីឆ្លើយតបនឹងវិបត្តិ និងដែលជួយជំរុញកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នស្រាវជ្រាវខាងគោលនយោបាយ ៥-តើស្ថាប័នកម្រិតតំបន់ និងពិភពលោក ដូចជា ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារអភិវឌ្ឍន៍ពហុភាគី ជាដើម អាចធ្វើអ្វីខ្លះ ដើម្បីជួយបំពេញតម្រូវការ របស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការទប់ទល់នឹងវិបត្តិបច្ចុប្បន្ន និងបង្ការវិបត្តិនាពេលអនាគត?

ការងារត្រូវធ្វើនៅមានច្រើនណាស់ ហើយជោគជ័យភាគច្រើនពឹងផ្អែកលើការប្តេជ្ញាចិត្ត និងកិច្ចសហការរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងស្ថាប័នស្រាវជ្រាវខាងគោលនយោបាយនានា ដែលត្រូវធ្វើការរួមគ្នា ដើម្បីបម្រើផលប្រយោជន៍របស់ប្រទេសកម្ពុជា ៕

### ប្រអប់ ១: បញ្ហាប្រឈមសំខាន់ៗផុសចេញពីវិបត្តិ

**បញ្ហាប្រឈម ១:** ធ្វើពិពិធភាវូបនីយកម្មទីផ្សារសម្រាប់ផលិតផលកាត់ដេរ និងទំនិញកម្មន្តសាលផ្សេងទៀត ដោយចូលទៅទីផ្សារ អាស៊ីបូព៌ា មជ្ឈិមបូព៌ា អាហ្វ្រិក និងទីផ្សារខុសប្លែកពីមុនផ្សេងៗ ។

**បញ្ហាប្រឈម ២:** កែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិស័យទេសចរណ៍ និងអភិវឌ្ឍតំបន់ទេសចរណ៍ថ្មីៗបន្ថែមទៀត និងយកចិត្តទុកដាក់រៀបចំកញ្ចប់ទេសចរណ៍ឱ្យកាន់តែមានភាពទាក់ទាញ ។

**បញ្ហាប្រឈម ៣:** ពង្រីក និងធ្វើពិពិធកម្មវិស័យកសិកម្ម, ទាក់ទាញវិនិយោគប្រកបដោយគុណភាពក្នុងវិស័យកសិអាជីវកម្ម និងកែលំអតំណភ្ជាប់ផ្សេងៗក្នុងពាណិជ្ជខាងកសិកម្ម កំណែទម្រង់ដីធ្លី និងការកែច្នៃកសិផល ។

**បញ្ហាប្រឈម ៤:** បង្កើនវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសការផលិតថាមពល ដើម្បីកាត់បន្ថយថ្លៃដើមថាមពល ។

**បញ្ហាប្រឈម ៥:** ជំរុញខ្លាំងក្លា និងជួយទ្រទ្រង់ដល់ការបង្កើតទ្រព្យធន និងការកែលំអជីវភាពរស់នៅរបស់ប្រជាជន ដោយអនុលោមតាមគោលការណ៍ និងនីតិវិធីទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ។

**បញ្ហាប្រឈម ៦:** ជួយដល់ជនក្រីក្រ និងជនងាយរងគ្រោះ ដែលប្រឈមមុខនឹងវិបត្តិតាមរយៈការពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម ដោយអនុវត្តវិធានការ ដូចជាការផ្តល់ជំនួយស្បៀងសង្គ្រោះបន្ទាន់និងការឧបត្ថម្ភសង្គមកិច្ចជាទឹកប្រាក់ជាដើម ។

**បញ្ហាប្រឈម ៧:** ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងតំបន់ និងបណ្តាប្រទេសមិនសូវអភិវឌ្ឍ ដើម្បីលើកកំពស់ផលប្រយោជន៍រួមនៅក្នុងឆាកអន្តរជាតិ ។

# វិបត្តិសាកល — ផលប៉ះពាល់ ចក្ខុវិស័យ និងជំរើសគោល នយោបាយសំរាប់កម្ពុជា

*អត្ថបទនេះ ពណ៌នាសង្ខេបនូវចំនុចសំខាន់ៗនៃបទបង្ហាញរបស់លោក John Nelmes ក្នុងវគ្គទី១ នៃសន្និសីទស្តីពីចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៩ ។*

## វិបត្តិៈ ដើមហេតុ និងផលប៉ះពាល់ជាសាកល

វិបត្តិសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន មានសភាពអាក្រក់ជាងមហាវិបត្តិសេដ្ឋកិច្ចទសវត្សរ៍១៩៣០ ទៅទៀត ។ ចំនុចទីមួយ និងសំខាន់បំផុត គឺផលប៉ះពាល់នៃវិបត្តិ បានរីករាលដាលទៅឆ្ងាយ និងយ៉ាងលឿន ដោយសឹងមិនចន្លោះប្រទេសណាមួយឡើយ ។ វិបត្តិនេះ ផ្តើមចេញពីសហរដ្ឋអាមេរិក និងរាលដាលទៅកាន់ប្រទេសអភិវឌ្ឍន៏ដទៃទៀត ហើយនៅអំឡុងឆ្នាំ២០០៨ វាឡើងដល់កំរិតកំពូលនិងរាលដាលទៅដល់ប្រទេសឯទៀតៗក្នុងពិភពលោក ដោយមានផលប៉ះពាល់ធ្ងន់ធ្ងរ និងជ្រាលជ្រៅជាងមហាវិបត្តិទសវត្សរ៍ ១៩៣០ ទៅទៀត ។ វិបត្តិនេះ កើតចេញពីវិបត្តិទ្រព្យអុីប៉ូតែកលេខ២ ហើយវាជះឥទ្ធិពលទៅលើទ្រព្យសកម្ម និងវិស័យផ្សេងៗទៀតនៃសេដ្ឋកិច្ច បង្កឱ្យមានការផ្តាច់ឥណទាន និងសាច់ប្រាក់ ការកាត់បន្ថយការងារ និងចំណូល និងការរលំរលាយអាជីវកម្ម និងទំនុកចិត្តរបស់អ្នកប្រើប្រាស់ ។

ទិន្នន័យក្នុងបទបង្ហាញនេះ បានបង្ហាញឡើងយ៉ាងច្បាស់ពីការថយចុះខ្លាំងនៃកំណើនសេដ្ឋកិច្ច ដោយសារវិបត្តិ ហើយគួបផ្សំនឹងទិន្នន័យនៅក្នុងព័ត៌មានថ្មីៗអំពីសេដ្ឋកិច្ចពិភពលោក ក្នុងខែមករា ឆ្នាំ២០០៩ របស់ IMF ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងទូទាំងពិភពលោក គឺអាចមើលឃើញយ៉ាងច្បាស់ ។ កំណើនផលិតផលពិភពលោក បានធ្លាក់ចុះពី ៥,២% នៅឆ្នាំ២០០៧ មកត្រឹម ៣,៤% នៅឆ្នាំ២០០៨ ដោយសារការថយចុះកំណើន ផសស នៅក្នុងតំបន់ និងប្រទេសសំខាន់ៗទាំងអស់ ។ ក្នុងពេលជាមួយគ្នា កំណើនធាតុចេញនៅ

ក្រាហ្វិក ១: កំណើន ផសស ត្រីមាសទី៤ ឆ្នាំ២០០៨ (% នៃ SAAR)




*ប្រភព: ការវិភាគ Haver*

**SAAR: អត្រាប្រចាំឆ្នាំប្រែប្រួលតាមរដូវ*

សហរដ្ឋអាមេរិក ធ្លាក់ចុះជិត ១% តំបន់អឺរ៉ុបធ្លាក់ចុះ ១,៦% ជប៉ុនធ្លាក់ចុះ ២,៧% មកដល់ -0,៣% ខណៈពេលដែលចិនធ្លាក់ចុះ ៤% និងតំបន់អាស៊ាន-៥ ធ្លាក់ចុះ 0,៩% ។ ផសស របស់ប្រទេសជឿនលឿន និងប្រទេសឧស្សាហកម្មថ្មីៗ (NIEs) នៅត្រីមាសទី៤ ឆ្នាំ២០០៨ សុទ្ធតែបានរួមចុះទាំងអស់ (សូមមើលក្រាហ្វិក ១) ។

ផលិតកម្មឧស្សាហកម្ម និងការនាំចេញ ក៏ធ្លាក់ចុះយ៉ាងគំហុកដែរនៅឆ្នាំ២០០៨ (ក្រាហ្វិក២) ។មិនតែប៉ុណ្ណោះ កំរិតទំនុកចិត្តរបស់បណ្តាអាជីវកម្ម និងអ្នកប្រើប្រាស់ ក៏ធ្លាក់ចុះដល់កំរិតទាបជាប្រវត្តិសាស្ត្រ ដែលបង្កការព្រួយបារម្ភយ៉ាងខ្លាំងពីសភាពការណ៍ដែលនឹងខិតមកដល់ ។

ក្រាហ្វិក ២: ផលិតកម្មឧស្សាហកម្ម និងការនាំចេញទំនិញ ក្នុងពិភពលោក (បំរែបំរួលជា % ក្នុង ៣ខែ នៃមធ្យមភាគបីខែរំកិល គិតជាប្រចាំឆ្នាំ)




*ប្រភព: IMF, ទិន្នន័យ GDS*

## វិបត្តិៈ ផលប៉ះពាល់នៅកម្ពុជា

ដោយសារប្រទេសកម្ពុជា មានពាក់ព័ន្ធតិចតួចណាស់នឹងប្រភេទផលិតផលកំចីលេខ២ដែលបង្កគ្រោះថ្នាក់ ដូច្នេះក៏មិនទទួលរងឥទ្ធិពលដោយផ្ទាល់ពីចលាចលហិរញ្ញវត្ថុទេ ប៉ុន្តែត្រូវវិបត្តិប៉ះពាល់បាន តាមរយៈឥទ្ធិពលរបស់វាទៅលើវិស័យជំរុញកំណើនសំខាន់ៗ ។ ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចកម្ពុជាពីកំណើនជាមធ្យមយ៉ាងខ្ពស់ដល់ ១០% នៅប៉ុន្មានឆ្នាំថ្មីៗ មកត្រឹម ៦% (តួលេខប៉ាន់ស្មានរបស់ IMF) ក្នុងឆ្នាំ២០០៨ គឺបណ្តាលមកពីការធ្លាក់ចុះនៃឧស្សាហកម្មកាត់ដេរ ទេសចរណ៍ និងសំណង់ ។ ការនាំចេញសំលៀកបំពាក់របស់កម្ពុជា ងាយនឹងទទួលរងការប៉ះទង្គិចពីផ្នែកខាងក្រៅណាស់ ដោយសារវាពឹងផ្អែកយ៉ាងខ្លាំងទៅលើទីផ្សារសហរដ្ឋអាមេរិក ។ កន្លងមក ផ្នែកនេះតែងដើរតាមនិន្នាការនៃការលក់រាយនៅសហរដ្ឋអាមេរិក ដូច្នេះវាក៏ធ្លាក់ចុះនៅពេលការលក់រាយនោះចាប់ផ្តើមធ្លាក់ចុះយ៉ាងខ្លាំង នៅពាក់កណ្តាលឆ្នាំ២០០៨ (ក្រាហ្វិក៣) ។កំណើនបរិមាណនាំចេញសំលៀកបំពាក់ពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះជិតដល់ 0% នៅខែមករា ២០០៩ ។ វិស័យទេសចរណ៍ក៏ធ្លាក់ចុះស្រដៀងគ្នាដែរ ដោយកំណើនជាមធ្យមពីមួយឆ្នាំទៅមួយឆ្នាំ ធ្លាក់ចុះពី ២៥% មកត្រឹមប្រហែល ៩% នៅឆ្នាំ២០០៨ ។ ដោយសារប្រទេសរបស់ពួកគេទទួលរងការប៉ះពាល់ពីវិបត្តិ ភ្ញៀវទេសចរមកដល់កម្ពុជាក៏បានថយចុះចំនួន ហើយបានប៉ះពាល់ដល់ចំណូលលក់សំបុត្រចូលទស្សនាប្រាសាទអង្គរវត្ត (ក្រាហ្វិក ៤) ចំណូលពីការចាយវាយរបស់ទេសចរ ចំណូលពន្ធ និងការចិញ្ចឹមជីវិតរបស់ប្រជាជន ។ អតិផរណាខ្ពស់នៅឆ្នាំ២០០៨ និងការឡើងថ្លៃប្រាក់រៀល បានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅទេសចរណ៍មានថ្លៃខ្ពស់ ធៀបនឹងប្រទេសដទៃទៀត ។

* លោក John Nelmes ជាតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំប្រទេសកម្ពុជា ។

ក្រាហ្វិក ៣: ការនាំចេញផលិតផលកាត់ដេរកម្ពុជា និងការលក់រាយនៅសហរដ្ឋអាមេរិក (កំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




សរុប មានកំណើនត្រឹមតែ ១% ប៉ុណ្ណោះ នៅចុងឆ្នាំ២០០៨ ហើយក៏ដាក់សំពាធទៅលើប្រព័ន្ធធនាគារក្នុងស្រុក ។ ការធ្លាក់ចុះវិស័យអចលនទ្រព្យ បានបង្កើនការព្រួយបារម្ភរបស់ប្រព័ន្ធធនាគារ ហើយក៏ជំរុញឱ្យមានការដាក់កំហិតលើកំចីធនាគារ ចំពោះវិស័យអចលនទ្រព្យនេះ ។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃឥណទានដល់វិស័យឯកជន បានធ្លាក់ចុះមកត្រឹម ៤៥% នៅខែមករា ២០០៩ ធៀបនឹងកំណើន ១០០% នៅខែឧសភា ២០០៨ ។

លទ្ធផលវិជ្ជមាននៃវិស័យកសិកម្មនៅឆ្នាំ២០០៨ បានជួយទ្រទ្រង់ដល់សេដ្ឋកិច្ចកម្ពុជា ។ ជាទូទៅ វិស័យកសិកម្ម បានបង្ហាញពីភាពធន់ទ្រាំល្អនឹងវិបត្តិ ទោះបីជាដំណាំសំរាប់នាំចេញសំខាន់ៗមួយចំនួន រងការប៉ះទង្គិចធ្ងន់ធ្ងរពីវិបត្តិក៏ដោយ ។ វិបត្តិសាកលបានជួយមួយកំរិតដល់អ្នកប្រើប្រាស់ ដោយវាបានបញ្ឈប់ការឡើងថ្លៃទំនិញផ្សេងៗ ដែលផុសចេញពីការឡើងថ្លៃម្ហូបអាហារ និងថាមពល តាំងពីឆ្នាំ២០០៦ មក ។ ប៉ុន្តែការធ្លាក់ថ្លៃផលិតផលបានកាត់បន្ថយប្រាក់ចំណេញរបស់ផលិតករ និងអ្នកនាំចេញ ហើយការថយចុះតំរូវការលើពិភពលោក បានធ្វើឱ្យពួកគេនៅសល់ផលិតផលក្នុងដៃ ព្រោះមិនមានអ្នកត្រូវការ ។ ទោះយ៉ាងនេះក្តី ថ្លៃផលិតផលនៅកម្ពុជា នៅតែមានកំរិតខ្ពស់ជាងកំរិតមធ្យមកាលពីមុនដដែល ហើយគួបផ្សំនឹងការឡើងថ្លៃប្រាក់រៀល កំលាំងប្រកួតប្រជែងរបស់កម្ពុជាត្រូវស្ថិតក្រោមសំពាធមួយ ។

ក្រាហ្វិក ៤: កម្ពុជា : ចំនួនទេសចរមកដល់សរុប និងប្រាក់ចំណូលពីអង្គរវត្ត ឆ្នាំ២០០៦_០៨ (កំណើនពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ ចំណូលបានពីការលក់សំបុត្រ ។ *ប្រភព: ទិន្នន័យផ្តល់ដោយអាជ្ញាធរកម្ពុជា និង ការប៉ាន់ស្មានរបស់បុគ្គលិក IMF*

វិស័យជំរុញកំណើនមួយទៀត គឺ វិស័យសំណង់ ក៏មានដំណើរការមិនសូវល្អដែរ នៅចំពោះមុខវិបត្តិនេះ ។ កត្តាសំខាន់នៃភាពស្ងប់ទ្រឹងក្នុងវិស័យសំណង់គឺ ការកាត់បន្ថយវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ដោយសារការរឹតបន្តឹងលក្ខខណ្ឌផ្តល់ហិរញ្ញប្បទាន និងកំណើនការភ័យខ្លាចគ្រោះថ្នាក់ ។ សកម្មភាពសាងសង់នៅកម្ពុជា ជាប់ពាក់ព័ន្ធជិតស្និទ្ធនឹងការវិវត្តខាងអចលនទ្រព្យ ។ ការថយចុះលំហូរចូលវិនិយោគពីបរទេស រួមនឹងការរលំរលាយផ្នែកអចលនទ្រព្យក្នុងស្រុក បានប៉ះទង្គិចយ៉ាងខ្លាំងលើវិស័យសាងសង់ដែលមានកំណើនលឿនៗ កាលពីមួយឆ្នាំមុននេះ ។ លំហូរចូលវិនិយោគផ្ទាល់ពីបរទេស បានធ្លាក់ចុះរហូត នៅត្រីមាសទី៣ និង ទី៤ ឆ្នាំ២០០៨។

ស្ថានភាពសាច់ប្រាក់នៅក្នុងស្រុក ក៏តានតឹងឡើង ស្របគ្នានឹងនិន្នាការខាងលើដែរ ។ រូបិយវត្ថុទូទៅ ស្ទើរតែគ្មានកំណើនសោះ នៅខែមករា ២០០៩ ។ បញ្ញើជារូបិយវត្ថុបរទេស ដែលជាមធ្យមមានចំនែក ៩០% នៅក្នុងបញ្ញើ

## វិបត្តិ: ចក្ខុវិស័យ និងគោលនយោបាយ

ក្នុងពេលចំពោះមុខនេះ គេមិនទាន់មើលឃើញពីចុងបញ្ចប់នៃការធ្លាក់ចុះសេដ្ឋកិច្ចនៅឡើយទេ ។ ការទស្សន៍ទាយសំរាប់ឆ្នាំ២០០៩ នៅតែអាប់អួរដែលបង្ហាញពីកំណើនគំនិតទុទិដ្ឋិនិយមចំពោះស្ថានភាពសេដ្ឋកិច្ចសាកល ។ កន្លងមក គេបានប៉ាន់ស្មានថា ផលិតផលរបស់ពិភពលោក នឹងមានកំណើន ២,២% ប៉ុន្តែឥឡូវនេះ IMF ព្យាករណ៍ថា នឹងមានកំណើនតែ ០,៥% ប៉ុណ្ណោះ ។ ស្រដៀងគ្នាដែរ ចក្ខុវិស័យជាទូទៅសំរាប់កម្ពុជា មានភាពអាប់អួរជាងមុន ហើយ IMF បានកែតំរូវបញ្ចុះតួលេខប៉ាន់ស្មាន កំណើន ផសស ពិត របស់

ក្រាហ្វិក ៥: កំណើន ផសស ពិតនៅកម្ពុជា (បំរែបំរួលពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




កម្ពុជាសំរាប់ឆ្នាំ២០០៩ ពី ៤,៨% មកត្រឹម -០,៥% (ក្រាហ្វិក ៥) ។ ការរួម
ចុះខ្លាំងនេះ បណ្ដាលមកពីភាពរាំរ៉ៃ និងកាន់តែធ្ងន់ធ្ងរ នៃការធ្លាក់ចុះខាង
កាត់ដេរ ទេសចរណ៍ និងសំណង់ ។ លោក Nelmes បានរំលឹកថា តាម
ការព្យាករណ៍ ការលក់រាយរបស់សហរដ្ឋអាមេរិកត្រូវធ្លាក់ចុះអស់ ១០%
នៅឆ្នាំនេះ ដូច្នេះការនាំចេញផលិតផលកាត់ដេរកម្ពុជា ប្រាកដជាត្រូវរង
គ្រោះ ។ ទន្ទឹមគ្នានេះ កំណើនវិស័យទេសចរណ៍ឆ្នាំ២០០៩ នៅកម្ពុជា នឹងធ្លាក់
ចុះរហូតដល់ -០,៥% ។ ផ្ទុយទៅវិញ វិស័យកសិកម្មរំពឹងថានឹងបន្តដំណើរការ
វិជ្ជមានពីឆ្នាំមុនទៀត បើទោះជាសំពាធបរិត្តផរណាដែលកំពុងតែកើតមាន
មិនសូវអំណោយផលដល់វិស័យនេះក្ដី ។ នៅឆ្នាំ២០១០ សេដ្ឋកិច្ចប្រហែល
រើបឡើងវិញយឺតៗ ប៉ុន្តែការធ្លាក់ចុះក៏នៅតែអាចកើតមានទៀត ។

ជាការពិតណាស់ ផ្លូវសំរាប់ការរើបសេដ្ឋកិច្ចឡើងវិញ វាមានការលំបាក
ច្រើន ។ ក្នុងនេះគួរអនុវត្តយុទ្ធសាស្ត្រ បន្ធូរបន្ថយបន្ទុកពន្ធមួយ ដើម្បីជួយសង្គ្រោះ
ដល់វិស័យ និងប្រជាជននានាដែលរងគ្រោះដោយវិបត្តិ ។ ឆ្នាំនេះ ថវិកា
ជាតិរំពឹងថានឹងមានឱនភាពដល់ ៤,៧៥% នៃ ផសស ។ ដើម្បីឱ្យគោលនយោ
បាយបង្កើនចំណាយថវិកានេះ អាចសំរេចគោលដៅបាន ត្រូវផ្ដល់អាទិភាព
ទៅលើចំនាយសំរាប់ប្រព័ន្ធសុវត្ថិភាពសង្គម និងហេដ្ឋារចនាសម្ព័ន្ធ ។
ម្យ៉ាងទៀតក៏មិនគួរបោះបង់ចោលនូវជោគជ័យដែលទទួលបានដោយលំបាក
ក្នុងប៉ុន្មានឆ្នាំកន្លងមក ក្នុងការគ្រប់គ្រងចំណូលនោះទេ ។

គោលនយោបាយផ្សេងទៀតសំរាប់ដោះស្រាយ រួមមាន ការបង្កើន
សាច់ប្រាក់ (ប៉ុន្តែមធ្យោបាយនេះគឺមានកំរិត) និងការបង្កើតឧបករណ៍
រូបិយវត្ថុដែលអាចជួយសំរួលដល់ប្រតិបត្តិការអន្តរធនាគារ ។ សកម្មភាព
នាពេលថ្មីៗ ដើម្បីពង្រឹងការគ្រប់គ្រងធនាគារពីចម្ងាយ និងដល់កន្លែង បាន
ផ្ដល់លទ្ធផលគួរឱ្យពេញចិត្ត ហើយត្រូវបន្តអនុវត្ត និងកែលំអថែមទៀត ។
ឱសថសំខាន់បំផុតសំរាប់ព្យាបាល ឬបង្ការវិបត្តិបច្ចុប្បន្ន និងវិបត្តិនាពេល
អនាគតនោះ គឺការដោះស្រាយនូវឧបសគ្គខាងរចនាសម្ព័ន្ធ ដែលកំពុងរារាំង
ដល់កំណើនសេដ្ឋកិច្ចមានមូលដ្ឋានធំទូលាយ និងការពង្រីកសមត្ថភាព
ប្រកួតប្រជែង ៕

***តើអ្នកដឹងទេថា ...?***

... ជាលទ្ធផលនៃវិបត្តិ សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានធ្លាក់ចុះ
សេដ្ឋកិច្ចព្រមៗគ្នា ជាលើកដំបូង គិតតាំងពីសង្គ្រាមលោកលើកទី២ មក?
សេដ្ឋកិច្ចសហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានរួមចុះជាផ្លូវការ នៅចុង
ឆ្នាំ២០០៨ ។ តាមធម្មតាគេតែងចាត់ទុកថា មានការរួមចុះសេដ្ឋកិច្ច
បើសិនមានកំណើនអវិជ្ជមាននៃ ផសស យ៉ាងតិចបំផុតចំនួន ២ ត្រីមាស
បន្តបន្ទាប់ ។

*ប្រភព: **CNN (2008), J. Menon** នៅក្នុងរបាយការណ៍អភិវឌ្ឍន៍
ប្រចាំឆ្នាំ ២០០៨-២០០៩*

... ជាលទ្ធផលនៃវិបត្តិ សេដ្ឋកិច្ចប្រទេសអៀឡង់ បានដួលរលំ ហើយប្រទេស
ជាច្រើនទៀតក៏កំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះដែរ? តាំងពីពាក់
កណ្ដាលឆ្នាំ២០០៨ ធនាគារសំខាន់ៗទាំងបីរបស់ប្រទេសអៀឡង់ បានដួល
រលំ ហើយរូបិយវត្ថុរបស់អៀឡង់ បានធ្លាក់ថ្លៃយ៉ាងលឿន រហូតដល់សឹង
អស់តំលៃរលីង ។ គេបានវាយស្មានថា ប្រទេសមួយចំនួន ដូចជា ស្វីស និង
ចក្រភពអង់គ្លេសជាដើម អាចមានលទ្ធផលដូចប្រទេសអៀឡង់ដែរ ។
ទោះបីមានការជជែកដេញដោលជាច្រើនថាប្រទេសមួយអាចក្ស័យធនបាន
ពិតមែនឬយ៉ាងណាក្ដី ប៉ុន្តែស្ថានភាពក្ស័យធនរបស់ប្រទេសតាមធម្មតាតែង
មានន័យថាប្រទេសនោះលែងអាចសងបំណុលក្រៅប្រទេសរបស់ខ្លួនបាន ។

*ប្រភព: ទស្សនាវដ្ដី Economist (2008), សារព័ត៌មាន Market Oracle
(2009)*

# វិបត្តិហិរញ្ញវត្ថុសាកលៈ ផលប៉ះពាល់ក្នុងតំបន់

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់លោក Jayant Menon* ក្នុងសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ និងព័ត៌មានផ្សេងទៀតស្រង់ពីអត្ថបទរបស់លោកនៅក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨_០៩ បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។*

## ផលប៉ះពាល់នៅលើកំណើនផលិតផល

ពិភពលោកបាននិងកំពុងប្រយុទ្ធប្រឆាំងនឹងវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្ងន់ធ្ងរមិនធ្លាប់ជួបប្រទះពីមុនមក ។ វិបត្តិបានចាប់ផ្ដើមក្នុងឆ្នាំ២០០៧ ជាមួយនឹងការរលំរលាយកម្ចីមានអ៊ីប៉ូតែកលេខ២ នៅសហរដ្ឋអាមេរិក ហើយវិវត្តិរីតតែធ្ងន់ធ្ងរ និងរីករាលដាលកាន់តែធំឡើង ។ នៅក្រោយសង្គ្រាមលោកលើកទី២ នេះជាលើកទីមួយហើយដែលមហាអំណាចសេដ្ឋកិច្ចទាំង ៣ (G3) រួមមាន សហរដ្ឋអាមេរិក តំបន់អឺរ៉ូ និងជប៉ុន បានធ្លាក់ចុះសេដ្ឋកិច្ចក្នុងពេលតែមួយ ។ កំណើនផលិតផលរបស់សហរដ្ឋអាមេរិក បានធ្លាក់ចុះពី ២% នៅឆ្នាំ២០០៧ មកត្រឹម ១,១% នៅឆ្នាំ២០០៨ ដែលធ្វើឱ្យអត្រាអត់ការងារធ្វើ កើនដល់ ៧,៨% នៅខែធ្នូ ២០០៨ ។ នៅពេលជាមួយគ្នានោះ កំណើនផលិតផលនៅអឺរ៉ុបថយចុះពី ២,៦% មកត្រឹម ០,៧% ។ តំបន់អឺរ៉ូ បានធ្លាក់ចូលក្នុងវិបត្តិនេះជាផ្លូវការនៅចុងឆ្នាំ២០០៨ បន្ទាប់ពីស្ថាប័នហិរញ្ញវត្ថុសំខាន់ៗបានទទួលរងគ្រោះដោយផ្ទាល់ពីវិបត្តិ ហើយវិនិយោគពាណិជ្ជកម្ម និងចំណាយលើការប្រើប្រាស់បានថយចុះ ។ ជាមួយគ្នានោះ សេដ្ឋកិច្ចជប៉ុនធ្លាក់ចុះប្រហែល ៣% ហើយកំណើនជំរុញដោយការនាំចេញ ក៏ត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតំរូវការសាកលលោកថយចុះ (តារាង ១) ។ មកដល់ពេលនេះ វិបត្តិបានជះឥទ្ធិពលស្ទើរតែទូទាំងសាកលលោក ហើយបញ្ហាវិបត្តិកើតចេញពីណា វាលែងសំខាន់ទៀតហើយ ។ ការពិចារណាដែលសំខាន់ជាងគេ គឺធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ច ងើបឡើងវិញពីការខូចខាតយ៉ាងធ្ងន់ធ្ងរ បង្កឡើងដោយវិបត្តិ និងជៀសវាងកុំឱ្យរឿងនេះកើតមានជាថ្មី ដោយផ្អែកលើការយល់ដឹង និងដំណោះស្រាយលើបញ្ហាដែលនាំឱ្យមានវិបត្តិ ។ កង្វះខាតបទបញ្ញត្តិ និងការត្រួតពិនិត្យពីគោលការណ៍ប្រុងប្រយ័ត្ន លើកម្ចីអ៊ីប៉ូតែកលេខ២ បាននាំឱ្យវិស័យហិរញ្ញវត្ថុដួលរលំ ដូច្នេះវាជាបញ្ហាចំបង ដែលត្រូវតែលើកមកដោះស្រាយភ្លាមៗ ។

តំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង (សំដៅជារួមដល់ អាស៊ាន ប្រទេសឧស្សាហកម្មថ្មី ឬ NIEs និងប្រទេសចិន) ក៏មិនបានគេចផុតពីផលប៉ះពាល់នៃវិបត្តិដែរ ហើយវាខុសស្រឡះពីការវាយស្មានពីដំបូងថាប្រទេសភាគច្រើនក្នុងតំបន់ នឹងគេចផុតពីការរីករាលសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះ ។ ទោះជាយ៉ាងនេះក្ដី តំបន់នេះអាចទ្រាំទ្រនឹងវិបត្តិបានប្រសើរជាងតំបន់ផ្សេងទៀត ក្នុងពិភពលោក ។ នៅឆ្នាំ២០០៨ កំណើនផលិតផលធ្លាក់មកត្រឹម ៦,១% ធៀបនឹង ៩% នៅឆ្នាំ២០០៧ ។ កំណើន ផសស អាស៊ានបានថយចុះមកត្រឹម ៤,៣% ធៀបនឹង ៦,៣%កាលពីឆ្នាំមុន ។ កំណើន ផសស របស់ប្រទេសឧស្សាហកម្មថ្មី ថយចុះយ៉ាងខ្លាំង មកត្រឹម ១,៨% នៅឆ្នាំ២០០៨ ធៀបនឹង ៥,៦% នៅឆ្នាំ២០០៧ ។ នៅពេលជាមួយគ្នានោះ កំណើននៅប្រទេសចិនថយចុះគួរឱ្យកត់សំគាល់អស់ប្រហែល ៣% បន្ទាប់ពីបានឡើងខ្ពស់បំផុត កាលពីឆ្នាំមុន (តារាង ១) ។

## ផលប៉ះពាល់នៅលើផលិតកម្ម និងពាណិជ្ជកម្ម

ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានស្ដែងឡើងដោយការថយចុះផលិតកម្ម និងពាណិជ្ជកម្ម ។ ផលិតផលកម្មន្តសាលសាកល បានធ្លាក់ចុះ ដោយសារតំរូវ

តារាង ១: កំណើន ផសស

| | 2006 | 2007 | 2008 | បំរែបំរួល 07-08 |
|---|---|---|---|---|
| តំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង | 8.7 | 9 | 6.1 | -2.9 |
| តំបន់អាស៊ាន | 6 | 6.5 | 4.3 | -2.2 |
| ប្រទេសឧស្សាហកម្មថ្មី | 5.5 | 5.6 | 1.8 | -3.8 |
| ចិន | 11.6 | 11.9 | 9 | -2.9 |
| ជប៉ុន | 2 | 2.4 | -0.7 | -3.1 |
| សហរដ្ឋអាមេរិក | 2.8 | 2 | 1.1 | -0.9 |
| តំបន់អឺរ៉ុប | 2.8 | 2.6 | 0.7 | -1.9 |

*កំណត់សំគាល់: នេះ គឺជាទិន្នន័យដើមសំរាប់តារាង១ នៃអត្ថបទទី ៣ នៃសង្ខេបអត្ថបទរបស់លោក J. Menon ។ សូមកត់សំគាល់ផងដែរថា ក្រាហ្វិកទាំងអស់ក្នុងអត្ថបទនេះ យកចេញដោយផ្ទាល់ពីបទបង្ហាញនានា ។*

ក្រាហ្វិក ១: កំណើនផលិតផលឧស្សាហកម្ម[1] (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*១ មធ្យមភាគរំកិលបីខែ*
*២ សំដៅលើអាស៊ាន-៤ គឺ ប្រទេសកូរ៉េ សិង្ហបុរី និង ថៃ ប៉ុន្តែមិនរាប់បញ្ចូល ហុងកុង ចិន ប្រ៊ុយនេ កម្ពុជា ឡាវ ភូមា និងវៀតណាម ដោយសារទិន្នន័យប្រចាំខែ មិនអាចរកបាន ។*

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

* លោក Jayant Menon ជាសេដ្ឋវិទូជាន់ខ្ពស់ នៃការិយាល័យសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នៃធនាគារអភិវឌ្ឍន៍អាស៊ី ។

ក្រាហ្វិក ២: ការនាំចូលទំនិញ¹ (គិតជា ដុល្លារUS, ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

២ សំដៅលើប្រទេសចិន ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ក្រាហ្វិក ៣: កំណើនការនាំចេញ¹ (គិតជា ដុល្លារUS, ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

២ រាប់បញ្ចូលទាំង ប្រទេសចិន ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ក្រាហ្វិក ៤: កំណើនផលិតកម្មឧស្សាហកម្ម¹ – អាស៊ាន-៤ និង វៀតណាម (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC

ការនាំចូលរបស់មហាអំណាចសេដ្ឋកិច្ចទាំង ៣ (G3) បានធ្លាក់ចុះយ៉ាងលឿន ។ ស្ថិតិបានពីតំបន់អាស៊ីបូព៌ា ដែលមានសេដ្ឋកិច្ចកំពុងឈានឡើង បានបង្ហាញថា ការធ្លាក់ចុះតំរូវការពីបណ្ដាប្រទេសអភិវឌ្ឍន៍ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់ការនាំចេញនៃប្រទេសមានសេដ្ឋកិច្ចកំពុងឈានឡើង ។ ក្រៅពីចិន កំណើនផលិតកម្មឧស្សាហកម្មនៅអាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង បានដាំក្បាលចុះពី ១១,១% នៅខែមករាកាលពីឆ្នាំមុន មកដល់ -៨% នៅខែមករា ២០០៩ (មធ្យមភាគបីខែរំកិល) (ក្រាហ្វិក ១) ។ បណ្ដាប្រទេសក្នុងតំបន់ ដូចជា ចិន ប្រទេសឧស្សាហកម្មថ្មី (ក្រៅពី តៃវ៉ាន់) និង អាស៊ាន-៤ ក៏មានកំណើននៃតម្លៃនាំចេញ និងនាំចូល ផលិតផលធ្លាក់ដល់អវិជ្ជមានដែរ នៅចុងឆ្នាំ២០០៨ (ក្រាហ្វិក ២ និង ក្រាហ្វិក ៣) ។

បើពិនិត្យលំអិតលើស្ថានភាពខាងលើ ផលិតផលឧស្សាហកម្ម និងការនាំចេញរបស់ប្រទេសនីមួយៗក្នុងអាស៊ាន-៥ (រួមទាំង វៀតណាម) សុទ្ធតែធ្លាក់ចុះ ដោយសារតំរូវការពិភពលោកនូវផលិតផលរបស់ប្រទេសទាំងនេះ បានថយចុះ ។ រហូតមកដល់ត្រីមាសទី៣ ឆ្នាំ២០០៨ ផលិតកម្មឧស្សាហកម្មរបស់វៀតណាមរក្សាលំនឹងបានល្អគួរសម ប៉ុន្តែក្រោយមកក៏ទទួលរងផលប៉ះពាល់ពីវិបត្តិដែរ ដោយបានរួមចុះ ១៤% នៅខែមករា ២០០៩ (មធ្យមភាគបីខែរំកិលគិតពីមួយឆ្នាំទៅមួយឆ្នាំ) ។ប្រទេសអាស៊ាន-៥ ផ្សេងទៀត ជួបការរួមចុះផលិតកម្មឧស្សាហកម្មដូចគ្នា ប៉ុន្តែថៃមានសភាពធ្ងន់ធ្ងរជាងគេ (ក្រាហ្វិក ៤) ។ ការរីកវរខាងនយោបាយនៅក្នុងប្រទេសថៃ បាននាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ ។ តំលៃនៃការនាំចេញ និងនាំចូលផលិតផលបានរួមចុះយ៉ាងខ្លាំងនៅចុងឆ្នាំមុន ។ នៅតំបន់អាស៊ាន-៤ តម្លៃនេះ ធ្លាក់ចុះអស់ ៦% និង ១១% ត្រឹមខែធ្នូ ២០០៨ (ក្រាហ្វិក ៦ និង ៧) ។ ក្នុងចំណោមប្រទេសអាស៊ាន-៤ ការនាំចេញរបស់ហ្វីលីពីនទទួលរងគ្រោះខ្លាំងជាងគេនៅក្នុងឆ្នាំ២០០៨ ។

ដោយសារឧស្សាហូបនីយកម្មនៅបណ្ដាប្រទេសឧស្សាហកម្មថ្មី (NIEs) គឺជំរុញឡើងដោយការបើកចំហសេដ្ឋកិច្ច ដូច្នេះវិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរណាស់ដល់ប្រទេសទាំងនេះដែលត្រូវពឹងផ្អែកលើពាណិជ្ជកម្ម ។ កំណើនផលិតកម្មឧស្សាហកម្មរបស់កូរ៉េ ធ្លាក់ចុះយ៉ាងខ្លាំងពីខែតុលា ២០០៨ ដល់ មករា ២០០៩ ។ នៅសិង្ហបុរី កំណើនផលិតកម្មឧស្សាហកម្ម បានធ្លាក់ចុះយ៉ាងគំហុកពីខែតុលា ២០០៧ ដល់ កក្កដា ២០០៨ ដោយធ្លាក់ចុះដល់កំរិតទាបបំផុតគឺ -១៧% នៅខែមករា ២០០៩ (ក្រាហ្វិក៥) ។ស្រដៀងគ្នានឹងនិន្នាការនៅអាស៊ាន-៤ដែរ កំណើនតម្លៃនាំចេញ និងនាំចូលផលិតផល នៅប្រទេសឧស្សាហកម្មថ្មី បានប្រែជាអវិជ្ជមាននៅចុងឆ្នាំ២០០៨ (ក្រាហ្វិក ៦ និង ក្រាហ្វិក ៧) ។ នៅខែធ្នូ ២០០៨

ក្រាហ្វិក ៥: កំណើនផលិតកម្មឧស្សាហកម្ម[១] – កូរ៉េ និង សឹង្ហបុរី
(ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*១ មធ្យមភាគរំកិលបីខែ*
*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៦: កំណើនការនាំចេញទំនិញ[១] – ប្រទេសឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤
(ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*១ មធ្យមភាគរំកិលបីខែ*
*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៧: កំណើនការនាំចេញ[១] – ប្រទេសចូឧស្សាហកម្មថ្មី-៣ និងអាស៊ាន-៤




*១ មធ្យមភាគរំកិលបីខែ*
*២ អាស៊ាន-៤ មាន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃ រីឯប្រទេសឧស្សាហកម្មថ្មី-៣ មាន ហុងកុង ចិន ។*
*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

សកម្មភាពនាំចេញរបស់តៃវ៉ាន់ ធ្លាក់ចុះធ្ងន់ធ្ងរជាងប្រទេសឧស្សាហកម្មថ្មីៗផ្សេងទៀត ។

នៅខែមករា ២០០៩ ផលិតកម្មឧស្សាហកម្មនៅចិន នៅតែកើនឡើង ទោះបីយឺតជាមុនក្តី ដោយតួលេខមធ្យមភាគបីខែរំកិល មានកំរិត ៦,៤៣% ។ ការថយចុះការបញ្ជាទិញទំនិញនាំចេញ និងវិនិយោគ គឺជាមូលហេតុចំបងនៃការថយចុះកំណើន ទោះបីកត្តាផ្សេងទៀត ដូចជាការបិទរោងចក្រមួយចំនួនក្នុងពេលប្រកួតកីឡាអូឡាំពិកជាដើម ក៏មានចំណែកក្នុងការធ្លាក់ចុះនេះដែរ ។ ការនាំចេញរបស់ចិន កើនឡើងជាវិជ្ជមាននៅខែធ្នូ ២០០៩ ប៉ុន្តែប្រហែលយឺតជាងមុន (ក្រាហ្វិក ៣) ។ ក្នុងខែដដែលនោះ ការនាំចូលផលិតផលរួមចុះ ៩% (ក្រាហ្វិក ២) ។ នៅជប៉ុន ផលិតកម្ម និងពាណិជ្ជកម្មទទួលរងគ្រោះធ្ងន់ធ្ងរណាស់ ។ ផលិតកម្មឧស្សាហកម្មជប៉ុន ធ្លាក់ចុះគួរឱ្យបារម្ភអស់ប្រហែល ២៣% នៅខែមករា (មធ្យមភាគបីខែរំកិលពីមួយឆ្នាំទៅមួយឆ្នាំ) (ក្រាហ្វិក ៨) ដោយសារតំរូវការសាកលនូវផលិតផលកម្មន្តសាលជប៉ុន បានធ្លាក់ចុះយ៉ាងខ្លាំង និងបញ្ហាចោទជាយូរមកហើយ នៃតំរូវការក្នុងស្រុកដែលស្ពឹកទ្រឹង ។ ការនាំចេញរបស់ជប៉ុន ធ្លាក់តម្លៃ ១០% នៅចុងឆ្នាំ២០០៨ (មធ្យមភាគបីខែរំកិល ពីមួយឆ្នាំទៅមួយឆ្នាំ) ។

## ផលប៉ះពាល់លើការប្រើប្រាស់ និងវិនិយោគ

ដោយមានចំណាយសាធារណៈជួយទ្រទ្រង់ផង ចំណាយប្រើប្រាស់នៅប្រទេសអាស៊ាន-៤ នៅតែមានកំណើនថេរជាវិជ្ជមាន ហើយវាបានផ្តល់ជំនួយទ្រទ្រង់ដ៏ចាំបាច់ដល់សេដ្ឋកិច្ចប្រទេសទាំងនេះ នៅចំពោះមុខការធ្លាក់ចុះវិនិយោគ ។ បន្ទាប់ពីមានកំណើនខ្ពស់ដល់ ៩,៣% នៅត្រីមាសទី១ ឆ្នាំ២០០៨ កំណើនវិនិយោគជាប់លាប់នៅក្នុងតំបន់ បានធ្លាក់ចុះមកត្រឹម ១,៦% វិញ នៅត្រីមាសទី៤ នៃឆ្នាំដដែល (ក្រាហ្វិក ៩) ។ ការថយចុះឥណទានយ៉ាងធ្ងន់ធ្ងរ ក្តីសង្ឃឹមតិចតួចចំពោះកំណើន និងកំណើនការប្រុងប្រយ័ត្នរបស់វិនិយោគិន ជាកត្តាចំបងនៃការធ្លាក់ចុះនេះ ។ វិនិយោគជាប់លាប់នៅក្នុងប្រទេសឧស្សាហកម្មថ្មី បានរួមចុះខ្លាំងជាងនៅអាស៊ាន-៤ ទៀត ដោយកំណើនតិចតួចត្រឹម ៣,៣% កាលពីត្រីមាសទី៣ ឆ្នាំ២០០៨ បានធ្លាក់ចុះភ្លាមៗអស់ ១០% នៅត្រីមាស ទី៤ ក្នុងឆ្នាំដដែល ។ ផ្ទុយស្រឡះពីអាស៊ាន-៤ នៅប្រទេសឧស្សាហកម្មថ្មី ចំណាយប្រើប្រាស់ធ្លាក់ចុះ ២% នៅត្រីមាស ទី៤ ឆ្នាំ២០០៨ (ក្រាហ្វិក ១០) ។ រដ្ឋាភិបាលនៃប្រទេសឧស្សាហកម្មថ្មី បានអនុម័តវិធានការផ្សេងៗ ដូចជា កញ្ចប់សារពើពន្ធជំរុញតំរូវការក្នុងស្រុក ជាដើម ប៉ុន្តែវិធានការទាំងនោះ មិនទាន់ហុចលទ្ធផលជាដុំកំភួនទេ ។

ក្រាហ្វិក ៨: កំណើនផលិតផលឧស្សាហកម្ម: ជប៉ុន[១] (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




១ មធ្យមភាគរំកិលបីខែ

*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ៩: កំណើនតំរូវការក្នុងស្រុក - អាស៊ាន-៤ (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ក្រាហ្វិក ១០: កំណើនតំរូវការក្នុងស្រុក - ប្រទេសឧស្សាហកម្មថ្មី-៣ (ពីមួយឆ្នាំទៅមួយឆ្នាំ ជា %)




*ប្រភព: ការគណនារបស់បុគ្គលិក OREI ផ្អែកលើទិន្នន័យរបស់ CEIC*

ភាគហ៊ុននៅអាស៊ាន-៤ និងប្រទេសឧស្សាហកម្មថ្មី ក៏ធ្លាក់ថ្លៃដែរ ហើយវាបានប៉ះពាល់ដល់វិនិយោគ និងចំណាយប្រើប្រាស់ឯកជន ។ នៅកូរ៉េខាងត្បូង និងតៃវ៉ាន់ សន្ទស្សន៍ទីផ្សារហ៊ុនធ្លាក់ចុះប្រហែល ៣៥% ទៅ ៤០% ដោយសារការរឹតបន្តឹងលក្ខខណ្ឌឥណទាន ការថយចុះតំរូវការនូវផលិតផលបច្ចេកវិទ្យានាំចេញ ហើយគំរោងវិនិយោគនៅក្រៅប្រទេស ក៏ទទួលការខាតបង់ច្រើនគួរកត់សំគាល់ ។ សន្ទស្សន៍ហ៊ុនរបស់ឥណ្ឌូនេស៊ី និងថៃ ធ្លាក់ចុះប្រហែល ៥០% ។ រូបិយវត្ថុភាគច្រើននៅតំបន់ទាំងនេះ ធ្លាក់ថ្លៃខ្លាំងបន្ទាប់ពីជួបវិបត្តិ ។ ក្នុងចំណោមប្រទេសឧស្សាហកម្មថ្មី រូបិយវត្ថុរបស់កូរ៉េខាងត្បូងធ្លាក់ថ្លៃខ្លាំងជាងគេ ដោយសារឱនភាពគណនីចរន្តកំធំ និងការដកចេញយ៉ាងគំហុកនូវវិនិយោគបរទេសលើមូលប័ត្រ ។ ក្នុងចំណោមប្រទេសអាស៊ាន៤ ប្រាក់រ៉ូពីរបស់ឥណ្ឌូនេស៊ី រងគ្រោះខ្លាំងជាងគេ ដោយសារការថយចុះយ៉ាងខ្លាំងនូវវិនិយោគបរទេសលើភាគហ៊ុន និងការរត់ចេញទៅវិញនូវទុនវិនិយោគបរទេស ។

## ចក្ខុវិស័យ និងគោលនយោបាយឆ្លើយតប

សេដ្ឋកិច្ចក្នុងតំបន់ និងសាកលលោក នៅតែស្ថិតក្នុងបរិយាកាសអាប់អួរ ហើយការខូចខាតកាន់តែធ្ងន់ធ្ងរ នៅតែអាចកើតមាន ។ ស្ថានភាពបច្ចុប្បន្ន បង្ហាញពីហានិភ័យនៃការធ្លាក់ចុះកាន់តែខ្លាំង ។ ស្របតាមគំនិតនេះ ការគន់គូរពីកំណើន ក៏មានលក្ខណៈកាន់តែទុទិដ្ឋិនិយម ។ ផ្អែកលើតួលេខប៉ាន់ស្មានរបស់ IMF គេរំពឹងថា នៅឆ្នាំ២០០៩ សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូ នឹងរួមចុះ ១,៦% និង ២% ចំណែកឯសេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីនឹងមានកំណើនយឺតជាងមុន ។ រដ្ឋាភិបាលនៅគ្រប់ប្រទេសរួមទាំងតំបន់អាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើងនោះផង បានចាត់វិធានការយ៉ាងរហ័ស និងម៉ឺងម៉ាត់ដោះស្រាយបញ្ហាផុសចេញពីវិបត្តិ ។ ធនាគារកណ្តាលចំបង៧ក្នុងពិភពលោក បានចាត់វិធានការពិសេស និងជាប្រវត្តិសាស្ត្រ ដូចជាការដាក់បញ្ចូលសាច់ប្រាក់យ៉ាងច្រើនទៅក្នុងគ្រឹះស្ថាន និងទីផ្សារ ជាដើម ដើម្បីជួយសំរាលនិងទប់ទល់ការប៉ះទង្គិច ។ ធនាគារកណ្តាលសហរដ្ឋអាមេរិកបានបញ្ចុះអត្រាការប្រាក់ ឱ្យនៅទាបបំផុត មិនធ្លាប់មាន ក្នុងប្រវត្តិសាស្ត្រនៃគោលនយោបាយរូបិយវត្ថុសម័យទំនើប ។ ប្រទេសនៅតំបន់អឺរ៉ុប បានចាត់វិធានការពិសេសបំផុត ដើម្បីជួយសង្គ្រោះប្រព័ន្ធធនាគារ ដោយក្នុងនោះ ប្រទេសដាណឺម៉ាក និងអៀរឡង់ បានប្រកាសផ្តល់ការធានាជាទូទៅដល់ប្រាក់បញ្ញើ និងបំណុល ។ នៅអាស៊ីបូព៌ាដែលមានសេដ្ឋកិច្ចកំពុងឈានឡើង មានការអនុម័តកញ្ចប់ជំរុញខាងហិរញ្ញវត្ថុផ្សេងៗ ដើម្បីបង្កើនចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធសុវត្ថិភាពសង្គម ។ ការកាត់បន្ថយពន្ធ និងបង្កើនឧបត្ថម្ភធន ក៏បានផ្តួចផ្តើមធ្វើឡើង ដើម្បីជួយដល់សេដ្ឋកិច្ចដែលកំពុងធ្លាក់ចុះ ។ ទោះបីជាមានវិធានការដ៏ម៉ឺងម៉ាត់បែបនេះក្តី ក៏ស្ថានភាពហិរញ្ញវត្ថុនៅតែតឹងតែង ហើយតំរូវការក្នុងស្រុកនិងក្រៅស្រុកនៅតែមានតិច ដូច្នេះហើយ គេក៏ព្យាករណ៍ថា ការរើបសេដ្ឋកិច្ចឡើងវិញ នឹងមានល្បឿនយឺត ៕

# ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល លើផ្នែកវិនិយោគ និងពាណិជ្ជកម្មរបស់កម្ពុជា

*អត្ថបទនេះ សង្ខេបចំនុចសំខាន់ៗនៃបទបង្ហាញរបស់ ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ[1] ក្នុងវគ្គទី ១ នៃសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

តើហានិភ័យពីខាងក្រៅ មិនអាចប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាឬ? ចម្លើយ គឺមិនមែនទេ ។ សរសរគ្រឹះនៃកំណើននៅកម្ពុជា ពោលគឺ វិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម អាចងាយរងគ្រោះខ្លាំង ឬតិច ដោយហានិភ័យមកពីខាងក្រៅ ។ បញ្ហានេះស្ដែងឡើងយ៉ាងច្បាស់នាបច្ចុប្បន្ននេះ នៅពេលដែលវិបត្តិបានបញ្ឈប់កំណើនសេដ្ឋកិច្ចពិភពលោក ធ្វើឱ្យបណ្ដាប្រទេសជឿនលឿនធ្លាក់ចុះសេដ្ឋកិច្ចធ្ងន់ធ្ងរ បន្ទុចបង្អាក់ ផលិតកម្មឧស្សាហកម្ម និងការនាំចេញព្រមទាំង ធ្វើឱ្យប្រជាជនបាត់បង់ទំនុកចិត្តខ្លាំងបំផុត មិនធ្លាប់ជួប ។ ការកែតំរូវបញ្ចុះតួលេខគន់គូរកំណើន របស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ជាសញ្ញាប្រាប់ថា វិបត្តិកាន់តែធ្ងន់ធ្ងរឡើង ។ សំរាប់កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៩ IMF បានកែតំរូវបញ្ចុះតួលេខប៉ាន់ស្មានពី ៤,៨% មកត្រឹម -០,៥% ប៉ុន្តែគេរំពឹងថា កំណើននេះនឹងកើនដល់ ៣% វិញ នៅឆ្នាំ២០១០ ។

## ផលប៉ះពាល់លើវិស័យកាត់ដេរ

វិបត្តិសាកល បានបង្ហាញថា វិស័យជំរុញកំណើននានារបស់កម្ពុជា ងាយរងគ្រោះដោយសារការធ្លាក់ចុះសេដ្ឋកិច្ចនៅខាងក្រៅប្រទេស ។ ក្នុងនេះគួរពិនិត្យមើលពីផលប៉ះពាល់នៃវិបត្តិ មកលើឧស្សាហកម្មកាត់ដេរ ដែលជាវិស័យនាំចេញឈានមុខរបស់កម្ពុជា ។ យោងតាមនិន្នាការថ្មីៗ ផលិតផលកាត់ដេររួមចំណែកប្រហែល ៦៥% នៃការនាំចេញសរុបរបស់កម្ពុជា ។ វិស័យកាត់ដេរបានធ្លាក់ចុះលឿនណាស់ ដោយសារជាសំខាន់ កង្វះភាពសំបូរបែបនៃទីផ្សារនាំចេញ និងមុខផលិតផល ។ បន្ទាប់ពីមានកំណើនដល់ ២១% នៅឆ្នាំ២០០៦ តំលៃការនាំចេញសំលៀកបំពាក់ បានកើនត្រឹម ៨% និង ៣,៣% ប៉ុណ្ណោះ នៅឆ្នាំ ២០០៧ និង ២០០៨ ( ក្រាហ្វិក ១) ។ ទិន្នន័យថ្មីៗនេះទៀតបង្ហាញថាស្ថានការណ៍បានប្រែប្រួលកាន់តែអាក្រក់ឡើង ដោយតម្លៃការនាំចេញសំលៀកបំពាក់ប្រចាំខែ បានធ្លាក់ចុះគួរឱ្យបារម្ភមកត្រឹម ១៦៥លានដុល្លារអាមេរិក នៅខែមករា ២០០៩ និង ១០២លានដុល្លារអាមេរិក នៅខែកុម្ភៈ ធៀបនឹងតម្លៃជាមធ្យម ២០០លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ហើយការរួមចុះនេះ ដើរស្របតាមការធ្លាក់ចុះខ្លាំងនៃការលក់រាយនៅសហរដ្ឋអាមេរិក ។ យោងតាមតួលេខថ្មីៗ ជាមធ្យមប្រហែល ៦៥% ទៅ ៧០% នៃការនាំចេញសំលៀកបំពាក់របស់កម្ពុជា គឺឆ្ពោះទៅកាន់សហរដ្ឋអាមេរិក ដូច្នេះការធ្លាក់ចុះសេដ្ឋកិច្ច និងការធ្លាក់ចុះតំរូវការនាំចូលរបស់សហរដ្ឋអាមេរិក បានប៉ះពាល់ជាខ្លាំងដល់វិស័យកាត់ដេរនៅកម្ពុជា ។

សកម្មភាពកាត់ដេរភាគច្រើន ប្រមូលផ្ដុំក្នុងផ្នែកមានតំលៃបន្ថែមទាប ដែលរារាំងដល់ការពង្រាយហានិភ័យ ផុសចេញពីវិបត្តិនាពេលថ្មីៗ ។ ការលំបាកដែលវិនិយោគិនបរទេសត្រូវប្រឈម បានចោទបញ្ហាបន្ថែមលើឧស្សាហកម្មកាត់ដេរដែលត្រូវពឹងផ្អែកលើវិនិយោគផ្ទាល់ពីបរទេស ។ ការវិវត្តមិនអំណោយផលទាំងនេះ បានប៉ះពាល់ដោយផ្ទាល់ដល់ដំណើរការរោងចក្រកាត់ដេរ និងការងារផ្នែកនេះ ។ ចំនួនសរុបនៃរោងចក្រកំពុង ដំណើរការបានធ្លាក់ចុះពី ២៩២ នៅចុងឆ្នាំ២០០៨ មកត្រឹម ២៧៧ ក្នុងរយៈពេល ២ខែ

ក្រាហ្វិក ១: ការនាំចេញវាយនភ័ណ្ឌ និងសំលៀកបំពាក់របស់កម្ពុជា ទៅទីផ្សារនានា ឆ្នាំ២០០៤-០៨ (គិតជាលានដុល្លារUS)




*ប្រភព: ក្រសួងពាណិជ្ជកម្ម ថ្ងៃទី៦ មីនា ២០០៩*

ក្រោយមក ។ ក្រាហ្វិក ២ បង្ហាញថា ចំនួនកម្មករកាត់ដេរ កើនខ្ពស់បំផុតដល់ ៣៥២.០០០នាក់ នៅខែកញ្ញា ២០០៨ ហើយក៏ធ្លាក់ចុះមកត្រឹម ៣០១.០០០នាក់ វិញ នៅខែកុម្ភៈ ២០០៩ ដោយមានការបាត់បង់ការងារចំនួន ៥១.០០០កន្លែង ។ ក្រៅពីការបញ្ឈប់ពីការងារ ការព្យាយាមកាត់បន្ថយចំណាយប្រតិបត្តិការរបស់រោងចក្រកាត់ដេរ ក៏បង្កកំណើន ភាពគ្មានការងារធ្វើពេញលេញផងដែរ ។ មានរបាយការណ៍ថា ការនាំចេញស្បែកជើងក៏ធ្លាក់ចុះដែរ ដោយកំណើនប្រចាំឆ្នាំធ្លាក់ចុះពី ៤២,៦% នៅឆ្នាំ២០០៧ មកត្រឹម ៤,៨% នៅឆ្នាំ២០០៨ ។ ជាទូទៅ សហភាពអឺរ៉ុប ជាគោលដៅនៃការនាំចេញស្បែកជើងភាគច្រើន ។

## ផលប៉ះពាល់លើវិស័យទេសចរណ៍ និងសំណង់

វិស័យទេសចរណ៍ នៅតែមានកំណើន ប៉ុន្តែយឺតជាងមុនខ្លាំងណាស់ ។ ភ្ញៀវទេសចរមកដល់កម្ពុជាកើនលើសកំរិត ២លាននាក់ នៅឆ្នាំ២០០៧ ហើយកើនដល់ ២.១លាននាក់ នៅឆ្នាំ២០០៨ ប៉ុន្តែអត្រាកំណើនបានធ្លាក់ចុះខ្លាំង ពីកំរិតមធ្យម ២៥% មកត្រឹម ៥% នៅឆ្នាំ២០០៨ ( ក្រាហ្វិក ៣) ។

សកម្មភាពសំណង់ ក៏ឃើញធ្លាក់ចុះយ៉ាងច្បាស់ ។ នៅឆ្នាំ២០០៨ វិនិយោគលើវិស័យសំណង់ ធ្លាក់ចុះ ៤០% ដោយសារការថយចុះវិនិយោគផ្ទាល់ពីបរទេស (FDI) ។ កំណើនសេដ្ឋកិច្ចដ៏ប្រសើររបស់កម្ពុជាកាលពីពេលថ្មីៗ វាជាប់ទាក់ទងយ៉ាងខ្លាំងនឹង FDI ដែលតំណាងឱ្យស្មើរតែ ៦០% នៃវិនិយោគសរុបក្នុងអំឡុងឆ្នាំ២០០៤ ដល់ ២០០៨ ។ ប៉ុន្តែគួរឱ្យស្ដាយ ទិន្នន័យរបស់ IMF ស្ដីពីជំពឹ្ញងទូទាត់ បង្ហាញថា តួលេខប៉ាន់ស្មាន FDI បានធ្លាក់ចុះពី ៨៦៦លានដុល្លារអាមេរិក នៅឆ្នាំ២០០៦ មកត្រឹម ៧៨៥លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ។

ម្យ៉ាងទៀត ទិន្នន័យបានពីធនាគារជាតិនៃកម្ពុជា បានបង្ហាញពីការធ្លាក់ចុះ FDI នៅឆមាសទី២ ឆ្នាំ២០០៨ ( ក្រាហ្វិក ៤) ។ IMF បានគន់គូរថា FDI នឹងធ្លាក់ចុះខ្លាំងមកត្រឹម ៤៨៨លានដុល្លារអាមេរិកក្នុងឆ្នាំនេះ ។ វិនិយោគពីកូរ៉េខាងត្បូង មានភាពឈប់ទ្រឹង ដោយសារតែវិបត្តិឥណទានយ៉ាងធ្ងន់ធ្ងរកើតមានក្នុងប្រទេសនោះ ។ ទោះយ៉ាងនេះក្ដី វិនិយោគិនកូរ៉េខាងត្បូងនៅតែមានទំនុកចិត្តខ្ពស់មកលើសេដ្ឋកិច្ចកម្ពុជា ហើយគំរោងខ្នាតតូច នឹងមធ្យមមួយចំនួន នៅតែហូរចូលមកកម្ពុជា ។

១ ឯកឧត្តម បណ្ឌិត ចម ប្រសិទ្ធ ជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ក្រាហ្វិក ២: ការងារក្នុងវិស័យកាត់ដេរ មករា ២០០៨–កុម្ភៈ ២០០៩ (ពាន់នាក់)




*ប្រភព: ក្រសួងពាណិជ្ជកម្ម ថ្ងៃទី៦ មីនា ២០០៩*

ក្រាហ្វិក ៣: ភ្ញៀវទេសចរមកដល់ប្រទេសកម្ពុជា




*ប្រភព: ក្រសួងទេសចរណ៍*

ក្រាហ្វិក ៤: វិនិយោគផ្ទាល់ពីបរទេសសុទ្ធ (គិតជាលានដុល្លារUS)




*ប្រភព: របាយការណ៍ប្រចាំត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា*

## ចក្ខុវិស័យ និងការឆ្លើយតបជាយថាហេតុ

ដូចបានរៀបរាប់ខាងលើ ចក្ខុវិស័យសំរាប់កម្ពុជានៅឆ្នាំ២០០៩ កាន់តែអាប់អួរឡើង ហើយ IMF បានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចនៅឆ្នាំនេះ នឹងធ្លាក់ចុះដល់ -0,៥% ។ កម្ពុជាអាចនឹងចូលដល់ការរួមចុះសេដ្ឋកិច្ច ។ គេទស្សទាយថាសេដ្ឋកិច្ចនឹងរើបឡើងវិញបន្តិចនៅឆ្នាំ២០១០ ប៉ុន្តែហានិភ័យនៃការធ្លាក់ចុះថែមទៀតក៏នៅតែមាន ។ដើម្បីទប់ស្កាត់ការរួមចុះសេដ្ឋកិច្ចដែលកាន់តែគំរាមកំហែងខ្លាំងឡើង ភាគីពាក់ព័ន្ធទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន ហើយរដ្ឋាភិបាលត្រូវតែពង្រឹងកំណែទំរង់នានារបស់ខ្លួន ។ វិធានការផ្សេងៗដែលរដ្ឋាភិបាល បានដាក់ចេញមកទល់ពេលនេះ ដូចជា ការលើកលែងពន្ធបង់មុនលើប្រាក់ចំណេញ ១% ជាដើម ពិតជាមានប្រយោជន៍ និងគួរឱ្យកោតសរសើរ ប៉ុន្តែនៅមានការងារច្រើនទៀតដែលត្រូវធ្វើ ។ យើងត្រូវតែជំទាស់គោលនយោបាយការពារផលិតផលក្នុងស្រុក ព្រោះក្នុងពេលជួបការលំបាកបែបនេះ ប្រទេសនានាតែងចង់បង្កើតរបាំងពាណិជ្ជកម្មដើម្បីការពារសេដ្ឋកិច្ចរបស់ខ្លួន ទោះបីវាប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រទេសឯទៀតក្តី ។ ដំណោះស្រាយដែលសមស្រប គឺ ការបើកចំហពាណិជ្ជកម្ម និងធ្វើសមាហរណកម្មកាន់តែច្រើន ។ ចំពោះកម្ពុជា ការបង្កើនពាណិជ្ជកម្មជាមួយប្រទេសក្នុងតំបន់របស់ខ្លួន អាចផ្តល់ផលចំណេញ ពីព្រោះវាជួយបំបែកពង្រាយហានិភ័យទៅតាមទិសដៅផ្សេងៗកាន់តែច្រើន និងជួយកាត់បន្ថយបន្ទុកចំណាយពាណិជ្ជកម្ម ។ ប៉ុន្តែចំណុចសំខាន់ គឺ ការធ្វើសមាហរណកម្មទីផ្សារកាន់តែខ្លាំងនៅកំរិតតំបន់ និងពិភពលោក ត្រូវតែមានបំពេញបន្ថែមដោយ យុទ្ធសាស្ត្រមួយសំរាប់បង្កើនសមត្ថភាពប្រកួតប្រជែងរបស់ប្រទេស និង ការធ្វើពិពិធកម្មទីផ្សារ និងផលិតផល ។ ដោយទទួលស្គាល់ពីធនធានមានកំរិតរបស់រដ្ឋាភិបាល គំរោងជំនួយពាណិជ្ជកម្ម (Aid for Trade) អាចជាជំនួយមួយដល់រដ្ឋាភិបាល ក្នុងការផ្តល់ហិរញ្ញប្បទានដល់គំរោងហេដ្ឋារចនាសម្ព័ន្ធដ៏ចាំបាច់ សំរាប់ទាញយកប្រយោជន៍ពីឱកាសល្អខាងពាណិជ្ជកម្ម ។ ហិរញ្ញប្បទានធនាគារ គឺជាប្រភពទុនមួយទៀតដែលអាចប្រើបាន ហើយឥណទានសំរាប់ការនាំចេញ អាចជួយសង្គ្រោះអ្នកនាំចេញ ដែលរងគ្រោះដោយវិបត្តិ និងជួយពង្រឹងពាណិជ្ជកម្មទាំងមូលទៀតផង ។ ការធ្វើពិពិធកម្មទីផ្សារ ជាការងារចាំបាច់បំផុតដែលបានលើកឡើងជារឿយៗហើយ ជាពិសេសទីផ្សារទាំងឡាយដែលមិនធ្លាប់ពាក់ព័ន្ធពីមុនមក ក៏គួរសិក្សាស្រាវជ្រាវដែរ ។ កំណែទំរង់កាន់តែស៊ីជំរៅលើបែបបទសម្របសម្រួលពាណិជ្ជកម្ម ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែង គឺជាវិធានការមួយទៀត ដែលគ្រប់ភាគីគួរជួយជ្រោមជ្រែង ។ ការវិនិយោគបន្ថែមទៀត ក្នុងវិស័យកសិកម្ម អាចជួយកាត់បន្ថយផលប៉ះពាល់ខ្លះនៃវិបត្តិបច្ចុប្បន្ន និងវិបត្តិផ្សេងៗនាពេលអនាគត ៕

### តើអ្នកបានដឹងទេថា

***... ឧស្សាហកម្មកាត់ដេរនៅកម្ពុជាពីមុន បានទទួលផលប្រយោជន៍ ពីរបបកូតា និង វិធានការការពាររបស់សហរដ្ឋអាមេរិក ទល់នឹងផលិតផលរបស់ប្រទេសចិន?*** ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីសាច់កំណាត់គ្រប់មុខ (Multi-Fibre Agreement – MFA) ជាមួយសហរដ្ឋអាមេរិក នៅឆ្នាំ១៩៩៥ គឺជាចំនុចស្ទុះឡើងនៃការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា ។ កិច្ចព្រមព្រៀងនេះផុតកំណត់នៅឆ្នាំ២០០៤ ។វិធានការការពាររបស់សហរដ្ឋអាមេរិក ទល់នឹងការនាំចូលសំលៀកបំពាក់ពីប្រទេសចិន បានផុតកំណត់នៅខែធ្នូ ២០០៨ ។វិធានការនេះបានជួយការពារ ការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា បន្តពីកិច្ចព្រមព្រៀង MFA បានមួយរយៈ ។ ការវិវត្តទាំងនេះ គួបផ្សំនឹងវិបត្តិក្នុងពេលបច្ចុប្បន្ន គឺជាមូលហេតុនៃការប្រយុទ្ធតស៊ូរបស់វិស័យកាត់ដេរកម្ពុជានាពេលសព្វថ្ងៃ ។

*ប្រភព: កម្មវិធីកំណែលំអរោងចក្រកម្ពុជា (២០០៥, ២០០៨)*

***... តំរូវការរថយន្ត និងទោចក្រយានយន្តនៅកម្ពុជា បានធ្លាក់ចុះយ៉ាងលឿន ចាប់តាំងពីខែឧសភា ឆ្នាំ២០០៨មក?*** កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃបរិមាណការនាំចូលរថយន្ត និងទោចក្រយានយន្ត បានធ្លាក់ចុះបន្ទាប់ពីកើនខ្ពស់បំផុតនៅខែឧសភា ២០០៨ ។ ក្រៅពីវិបត្តិបច្ចុប្បន្ន មូលហេតុនៃការធ្លាក់ចុះតំរូវការដ៏ខ្លាំងបែបនេះ រួមមាន ឥទ្ធិពលនៃការឡើងថ្លៃថាមពល ការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ ការធ្លាក់ចុះប្រាក់ចំណូលពិត និង ជាពិសេស ការធ្លាក់ចុះទំនុកចិត្តរបស់អាជីវករ និងអ្នកប្រើប្រាស់ ។

*ប្រភព: ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ការវាយតំលៃរបស់បុគ្គលិក*

# ផលប៉ះពាល់ជាសក្ដានុពលនៃវិបត្តិហិរញ្ញវត្ថុទៅលើគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ នៅកម្ពុជា

*អត្ថបទនេះជាសេចក្ដីសង្ខេបនៃបទបង្ហាញរបស់ បណ្ឌិត Hossein Jalilian[១] ក្នុងវគ្គទី១ នៃសន្និសីទចក្ខុវិស័យ ស្ដីពីប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## សេចក្ដីផ្ដើម

វិបត្តិហិរញ្ញវត្ថុសាកល ជះឥទ្ធិពលភាគច្រើនទៅលើភាពក្រីក្រ តាមរយៈផលប៉ះពាល់ទៅលើ កំណើនសេដ្ឋកិច្ច ។ ហេតុនេះ ជាដំបូងត្រូវពិចារណាពីផលប៉ះពាល់ទៅលើកំណើនសេដ្ឋកិច្ចនេះ ។ កំណើនសេដ្ឋកិច្ច នៅកម្ពុជាអាចទទួលផលប៉ះពាល់តាមរយៈពាណិជ្ជកម្ម វិនិយោគពីបរទេស ទេសចរណ៍ ការផ្ទេរប្រាក់ និងជំនួយអន្តរជាតិ ជាដើម ។

ផលប៉ះពាល់នៃវិបត្តិ ទៅលើទីផ្សារហិរញ្ញវត្ថុ ទំនងជាមិនធំដុំទេ ពីព្រោះកម្ពុជាមិនទាន់ធ្វើសមាហរណកម្ម ចូលទៅក្នុងទីផ្សារហិរញ្ញវត្ថុសាកល ហើយទីផ្សារហិរញ្ញវត្ថុនៅកម្ពុជានៅអន់ថយនៅឡើយ ។ ទោះយ៉ាងនេះក្ដី ផលប៉ះពាល់ដោយប្រយោលទំនងជាមានច្រើនគួរកត់សំគាល់ ។វិបត្តិ បានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ហើយស្ថានភាពនេះទំនងកាន់តែយ៉ាប់យ៉ឺនថែមទៀត ក្នុងរយៈពេលខ្លី និងមធ្យម ។ រឿងនេះ ទំនងជះឥទ្ធិពលច្រើនណាស់ដល់ការិត និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ ។

ក្រាហ្វិក ១: កំណើនតាមវិស័យនៅកម្ពុជា ១៩៩៤-២០០៧




*ប្រភព : ផ្អែកលើទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ*

## ផលប៉ះពាល់លើកំណើន

ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិទៅលើកំណើន ដំបូងគេគួរពិនិត្យពីផលិតផលក្នុងស្រុកសរុប (ផសស) និងកំណើនតាមវិស័យ ព្រមទាំងចំណែកនៃវិស័យនីមួយៗ នៅក្នុងកំណើនសរុបរបស់កម្ពុជា ។ ក្រាហ្វិក ១ បង្ហាញពីកំណើនតាមវិស័យ និងកំណើន ផសស នៅកម្ពុជា ហើយ ក្រាហ្វិក ២ បង្ហាញពី ចំណែកតាមវិស័យនៅក្នុងកំណើនសរុប ។

នៅឆ្នាំ១៩៩៤-២០០៧ កម្ពុជាមានកំណើន ផសស ជាមធ្យមប្រហែល ១០% ដោយសារកំណើនខ្លាំងក្នុង វិស័យឧស្សាហកម្ម និង វិស័យសេវាកម្មជាទី២ ។ កំណើនវិស័យឧស្សាហកម្ម បានមកពីកំណើនដ៏ខ្ពស់ នៃវិស័យកាត់ដេរ និងសំណង់ ហើយ វិស័យសេវាកម្មកើនឡើងដោយផ្អែកលើវិស័យទេសចរណ៍ ។

វិស័យឧស្សាហកម្ម និងសេវាកម្ម បានចូលរួមចំណែកធំណាស់ក្នុងកំណើន ផសស រីឯវិស័យកសិកម្ម រួមចំណែកមិនសូវច្រើនទេរហូតមកទល់សព្វថ្ងៃ ហើយកំណើនរបស់វាក៏មិនសូវមានស្ថិរភាពដែរ ។

ក្នុងស្ថានភាពបែបនេះ ផលប៉ះពាល់នៃវិបត្តិ ទៅលើកំណើន ផសស នៅកម្ពុជា ទំនងជាមានសភាពធ្ងន់ធ្ងរ ហើយមានការទស្សទាយថា វិស័យឧស្សាហកម្ម និងសេវាកម្ម នឹងត្រូវប៉ះពាល់ខ្លាំងជាងគេ ។ ឧស្សាហកម្មមានកំណើនដោយសារវិស័យកាត់ដេរ និងសំណង់ ប៉ុន្តែវិស័យទាំងពីរនេះបានជួបប្រទះការធ្លាក់ចុះ ដែលគេប៉ាន់ស្មានថា នឹងធ្ងន់ធ្ងរឡើងទៀតក្នុងរយៈពេលខ្លី ដោយអាចធ្លាក់ចុះអស់ ២៥% ។ វិស័យទេសចរណ៍ក៏រំពឹងថានឹងធ្លាក់ចុះដូចគ្នា ។ ការធ្លាក់ចុះរួមគ្នានៃវិស័យទាំងនេះ នឹងធ្វើឱ្យកំណើន ផសស ថយចុះ ដោយអ្នកវិភាគភាគច្រើនប៉ាន់ស្មានថា កំណើននឹងធ្លាក់ចុះមកត្រឹមពាក់កណ្ដាលនៃកំណើនមធ្យមក្នុងទសវត្សរ៍កន្លងទៅនេះ ។នៅពេលវិបត្តិវិវត្តទៅមុខ ពួកអ្នកព្យាករណ៍ហាក់ដូចកាន់តែទុទិដ្ឋិនិយមឡើង ហើយការព្យាករណ៍ថ្មីៗបំផុត បានបង្ហាញថា ផសស របស់កម្ពុជានៅឆ្នាំនេះ នឹងមានកំណើនអវិជ្ជមាន ។

ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យកសិកម្មមានកំណើន ៥% ក្នុងមួយឆ្នាំ ។ តួលេខនេះទំនងមិនផ្លាស់ប្ដូរ ច្រើនទេ ដោយសារមិនសូវមានតម្រូវការពីក្រៅស្រុកលើផលិតផលកសិកម្ម ។ ប្រសិនបើមានការអនុម័ត គោលនយោបាយសមស្របសំរាប់គាំទ្រកសិកម្ម វិស័យនេះអាចជួយជំរុញកំណើន និងកាត់បន្ថយភាពក្រីក្រ ។

## ផលប៉ះពាល់លើភាពក្រីក្រ

កំណើនសេដ្ឋកិច្ចមានទំនាក់ទំនងផ្ទាល់ជាមួយការកាត់បន្ថយភាពក្រីក្រ ។ ផ្អែកលើកំណើនដ៏ខ្ពស់ នាពេលថ្មីៗ ការកាត់បន្ថយភាពក្រីក្រគួរតែខ្ពស់ខ្លាំងជាងការិត ១០% ដែលសំរេចបានក្នុងពេលកន្លងទៅ និងដែលកើតមានដូច្នេះឡើង ដោយសារវិស័យមានកំណើនខ្ពស់ មានចំណងទាក់ទងតិចជាមួយវិស័យឯទៀតនៃសេដ្ឋកិច្ច ។ ការចូលរួមចំណែកសំខាន់បំផុតរបស់វិស័យមានកំណើនខ្ពស់ គឺការបង្កើតការងារ ហើយក្រៅពីនេះមិនសូវមានចំណងទាក់ទងអ្វីច្រើនជាមួយវិស័យឯទៀតទេ ប៉ុន្តែចំពោះទេសចរណ៍វាលក្ខណៈគ្រាន់បើជាងគេ ។

ដើម្បីអាចពិចារណាបានកាន់តែពេញលេញពី ផលប៉ះពាល់នៃការធ្លាក់ចុះកំណើនទៅលើភាពក្រីក្រ គេគួរធ្វើការបែងចែករវាងឥទ្ធិពលនៃកំណើនដែលផ្ទេរតាមរយៈទីផ្សារពលកម្ម និងផលប៉ះពាល់ទៅលើវិនិយោគ និងចំណាយប្រើប្រាស់ ។ ដោយសារមានចំណងទាក់ទងតិចរវាងវិស័យមាន

១ បណ្ឌិត Hossein Jalilian ជាប្រធានផ្នែកស្រាវជ្រាវនៃ CDRI ។

ក្រាហ្វិក ២: ចំណែកតាមវិស័យ ក្នុងកំណើន ផសស នៅកម្ពុជា ១៩៩៤-២០០៧




*ប្រភព: វិទ្យាស្ថានជាតិស្ថិតិ*

កំណើនខ្ពស់ និងវិស័យឯទៀតនៃសេដ្ឋកិច្ច ឥទ្ធិពលដោយផ្ទាល់នៃការធ្លាក់ចុះកំណើនទៅលើភាពក្រីក្រ ដែលត្រូវបានផ្ទេរតាមរយៈទីផ្សារពលកម្ម ប្រហែលមិនសូវធ្ងន់ធ្ងរប៉ុន្មានទេ ។ ទោះយ៉ាងនេះក្តី ការបាត់បង់ការងារមិនមែនប៉ះពាល់តែលើសុខុមាលភាពរបស់ អ្នកគ្មានការងារធ្វើនោះទេ ប៉ុន្តែប៉ះពាល់ដល់ក្រុមគ្រួសារដែលបុគ្គលទាំងនោះផ្គត់ផ្គង់ផងដែរ ពីព្រោះជនចំណាកស្រុកពីតំបន់ជនបទទៅទីប្រជុំជនភាគច្រើន តែងផ្ញើប្រាក់ទៅភូមិកំណើតរបស់ខ្លួន ។

បន្ថែមលើចំណាកស្រុកពីជនបទទៅទីប្រជុំជន មានពលករកម្ពុជាប្រហែល ២៥.០០០នាក់ បានធ្វើចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសទៅប្រទេសថៃ ។ ជនចំណាកស្រុកទាំងនេះមួយភាគធំ ទំនងត្រូវបាត់បង់ការងារ ដោយសារប្រទេសគោលដៅត្រូវវិបត្តិប៉ះពាល់ ក្នុងនេះអ្នកទៅប្រទេសថៃ ប្រហែលត្រូវជួបបញ្ហាធ្ងន់ធ្ងរជាង ។ លើសពី ៨០% នៃជនចំណាកស្រុកកម្ពុជាទៅថៃ ជាជនចំណាកស្រុកមិនស្របច្បាប់ ហើយអាជ្ញាធរថៃបានប្រកាសថា អ្នកទាំងនេះនឹងត្រូវបញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ។ រឿងនេះ អាចប៉ះពាល់យ៉ាងខ្លាំងដល់ការប្រាក់ផ្ញើទៅផ្ទះ ហើយបន្ទាប់មកគឺសុខុមាលភាពរបស់ក្រុមគ្រួសារ ដែលបានប្រាក់ផ្ញើទាំងនេះជួយទ្រទ្រង់ ពីព្រោះពួកគេប្រើប្រាស់វាដើម្បីដោះស្រាយការចាយវាយផ្សេងៗ ក៏ដូចជាការចំណាយខាងធនធានមនុស្ស និងទ្រព្យរូបវន្ត ។

ការធ្លាក់ចុះកំណើន ជាពិសេសក្នុងកំរិតដែលបានព្យាករណ៍នាពេលថ្មីៗនេះ អាចប៉ះពាល់ខ្លាំងណាស់ទៅលើគ្រួសារនានា តាមការជះឥទ្ធិពលទៅលើចំណាយប្រើប្រាស់ និងវិនិយោគ ។ ប្រជាជនមួយភាគធំ មានកំរិតជីវភាពនៅកៀកនឹងបន្ទាត់ក្រីក្រ ដូច្នេះការធ្លាក់ចុះប្រាក់ចំណូលតែបន្តិច អាចរុញច្រានពួកគេ ឱ្យធ្លាក់ទៅក្រោមបន្ទាត់ក្រីក្រ ។ ការសិក្សាពីការចាកផុតពីភាពក្រីក្រ ដែល CDRI បានបោះពុម្ពផ្សាយកាលពីឆ្នាំមុន បានបង្ហាញច្បាស់ពីភាពងាយរងគ្រោះនេះ ។ ការសិក្សានៅភូមិមួយចំនួនបានបង្ហាញថា ការប្រែប្រួលប្រាក់ចំណូល ត្រឹមតែប៉ុន្មានរយរៀល ក៏អាចធ្វើឱ្យភាពក្រីក្រធ្ងន់ធ្ងរខ្លាំងឡើងដែរ ។ ការសិក្សានេះ ក៏បង្ហាញពីការផ្លាស់ប្តូរខ្លាំង គួរឱ្យកត់សំគាល់នៃអត្រា និងកំរិតធ្ងន់ធ្ងរនៃភាពក្រីក្រ រវាងរដូវវស្សា និងរដូវប្រាំង ផងដែរ ។ ដូច្នេះគេឃើញថា ប្រជាជនក្រីក្រមានមធ្យោបាយតិចតួចណាស់ សំរាប់ដោះស្រាយបញ្ហាប្រាក់ចំណូលប្រែប្រួលតាមរដូវកាល ។

ក្រៅពីឥទ្ធិពលអវិជ្ជមានទៅលើចំនួនការងារធ្វើ វិបត្តិក៏ប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនក្រីក្រ និងក្រុមងាយរងគ្រោះផងដែរ ដោយសារការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច ។ វាក៏ជះឥទ្ធិពលមិនល្អផងដែរទៅលើ អ្នកធូរធារគួរសម និងអ្នកមានៗ ។ អ្នកទាំងនេះប្រហែលធ្វើការកាត់បន្ថយចំណាយប្រើប្រាស់ និងជាពិសេស វិនិយោគ ។ ការធ្លាក់ចុះតំរូវការ និងចំណាយ នឹងជះឥទ្ធិពលដល់ប្រជាជនមួយភាគធំ ។ តាមធម្មតា ក្រុមដែលងាយបាត់បង់មធ្យោបាយទ្រទ្រង់ជីវភាពអស់មួយផ្នែក ឬទាំងមូល គឺ ក្រុមដែលគ្មាន ឬមិនសូវមានធនធានមនុស្ស និងមូលធនរូបវន្ត ហើយក្រុមទាំងនោះរួមមាន គ្រួសារក្រីក្រ និងក្រីក្រគួរសម ។

សរុបមក កម្ពុជាទំនងត្រូវប្រឈមមុខនឹងស្ថានភាពក្រីក្រកាន់តែធ្ងន់ធ្ងរ ប៉ុន្តែបញ្ហាធ្ងន់ធ្ងរដល់កំរិតណា ព្រមទាំងផលវិបាកផ្សេងៗទៀតនេះ វាជាប់ទាក់ទងនឹងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ដូចជា សហរដ្ឋអាមេរិក និងសហគមន៍អឺរ៉ុប ជាដើម និងចំណុចថា តើប្រទេសទាំងនេះអាចទប់ទល់នឹងវិបត្តិបានល្អប៉ុណ្ណា ហើយជាពិសេស គឺ ប្រតិកម្មរបស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ។

## ជម្រើសគោលនយោបាយ ដើម្បីទប់ទល់នឹងឥទ្ធិពលអវិជ្ជមាន

ការសិក្សាមួយដែល IMF ទើបបោះពុម្ពផ្សាយ បានចាត់ថ្នាក់កម្ពុជាចូល ក្នុងចំណោម ប្រទេសមានប្រាក់ចំណូលទាបដែលងាយប៉ះពាល់ជាងគេ ។ ភាពងាយប៉ះពាល់នេះ គេវាស់វែងតាម កំណើនភាពងាយរងគ្រោះធ្លាក់ខ្លួនក្រីក្រ និងកំណើនជីវភាពលំបាករបស់គ្រួសារនានា ។ កត្តាសំខាន់ក្នុងនេះ គឺត្រូវមានគោលនយោបាយ កាត់បន្ថយផលប៉ះពាល់នៃវិបត្តិទៅលើជនក្រីក្រ ភ្លាមៗ ឬក្នុងរយៈពេលខ្លី និងបំបាត់សំពាធដែលរារាំងកំណើន និងការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលមធ្យម និងវែង ។

ក្នុងពេលចំពោះមុខភ្លាមៗ និងក្នុងរយៈពេលខ្លី រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ គួរដាក់អនុវត្តយន្តការនានា ដើម្បីជួយទ្រទ្រង់គ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ ។ យន្តការទាំងនេះអាចមានទម្រង់ជា ស្បៀងពលកម្ម ឧបត្ថម្ភធនលើស្បៀងអាហារនៅតាមសាលា និង ប័ណ្ណអាហារ ជាដើម ។ ពេលនេះក៏អាចជាឱកាសល្អ សំរាប់អនុវត្តកម្មវិធីសុវត្ថិភាពសង្គមប្រកបដោយប្រសិទ្ធភាពដែរ ដែលជួយយ៉ាងច្រើនដល់គ្រួសារក្រីក្រ និងមានផលល្អសំរាប់សេដ្ឋកិច្ច និងស្ថិរភាពនយោបាយ-សង្គមកិច្ច ទៀតផង ។

ទោះជាយ៉ាងនេះក្តី នៅមានឧបសគ្គមួយចំនួនដែលអាចរារាំងដល់ការងារខាងលើនេះ ។ ទោះបីជាមាន គោលនយោបាយល្អខាងហិរញ្ញវត្ថុ និងរូបិយវត្ថុក្តី ក៏រដ្ឋាភិបាលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់លើផ្នែកហិរញ្ញវត្ថុ និងរូបិយវត្ថុទេ ដើម្បីអនុម័តប្រើគោលនយោបាយបង្កើនចំណាយថវិកាដ៏ចាំបាច់ទាំងនោះ ។ គោលនយោបាយខាងអត្រាប្តូរប្រាក់ បានកាត់បន្ថយជាខ្លាំងនូវតួនាទីនៃគោលនយោបាយខាងរូបិយវត្ថុ ហើយរដ្ឋាភិបាលមានជំរើសមិនច្រើនទេក្នុងការដាក់អនុវត្តគោលនយោបាយបង្កើនចំណាយថវិកា ព្រោះមានលទ្ធភាពតិចទាំងខាងថវិកា និងសមត្ថភាពដាក់អនុវត្តគោលនយោបាយទាំងនោះ ។ តួអង្គឯទៀតដូចជាដៃគូអភិវឌ្ឍន៍ជាដើម អាចដើរតួនាទីយ៉ាងសំខាន់ ប៉ុន្តែនៅក្នុងបរិយាកាសសេដ្ឋកិច្ចបច្ចុប្បន្ន លក្ខខណ្ឌនេះពុំកើតមានភ្លាមៗនោះទេ ទោះបីមានកិច្ចប្រឹងប្រែងក្នុងតំបន់ និងពិភពលោក ដើម្បីជួយទ្រទ្រង់ប្រទេសក្រីក្រក៏ដោយ ។

វិធានការរយៈពេលវែងគួរដាក់អនុវត្ត ដើម្បីកែលំអសន្តិសុខស្បៀង និងកាត់បន្ថយភាពងាយរងគ្រោះ ។ ការដាក់ចេញនូវគោលនយោបាយសមស្រប មានសារសំខាន់ណាស់ ដោយវាជួយជំរុញកំណើនមានលក្ខណៈរាប់បញ្ចូល ដែលក្នុងនោះប្រជាជនភាគច្រើនអាចទទួលបាននូវផ្លែផ្ការបស់វា ។ នៅដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍ យុទ្ធសាស្ត្រប្រសើរបំផុតអាចជាការកាត់បន្ថយកត្តារារាំង និងសំពាធលើវិស័យកសិកម្ម ។ កត្តារារាំងមានជាច្រើន ហើយដោយសារកង្វះខាតធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យរូបវន្តសំរាប់ដោះស្រាយ ដូច្នេះគេត្រូវធ្វើការជ្រើសរើសដាក់អនុវត្តនូវ គោលនយោបាយទាំងឡាយណាដែលជួយកាត់បន្ថយ កត្តារាំងស្ទះខ្លាំងៗជាងគេ ។ កត្តារាំងស្ទះហាក់ដូចធ្ងន់ធ្ងរបំផុតលើផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវន្ត ។ កម្ពុជាស្ថិតក្នុងចំណោម ប្រទេសមានសមត្ថភាពប្រកួតប្រជែងតិចជាងគេនៅក្នុងតំបន់ ដែលបណ្តាលមួយចំណែកមកពី បន្ទុកចំណាយខ្ពស់ខាងពាណិជ្ជកម្ម និងផលិតកម្ម ។ ការដោះស្រាយឧបសគ្គខាងហេដ្ឋារចនាសម្ព័ន្ធ ទំនងជានឹងជួយកែលំអសមត្ថភាពប្រកួតប្រជែងនេះ ។

## សេចក្តីសន្និដ្ឋាន

ទោះបីវិបត្តិទំនងជះឥទ្ធិពលអវិជ្ជមានខ្លាំងមកលើកម្ពុជាក្តី ប៉ុន្តែវាបានផ្តល់ឱកាសឱ្យ រដ្ឋាភិបាលធ្វើការពិចារណាលើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ខ្លួន ។ សមាសភាគសំខាន់បំផុត អាចជា ការអភិវឌ្ឍវិស័យកសិកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់ និងស៊ីចង្វាក់គ្នា ដូចជា យុទ្ធសាស្ត្រសំរាប់ដោះស្រាយឧបសគ្គធំៗក្នុងវិស័យនេះ ជាដើម ។ ឧបសគ្គទាំងនេះ រួមមាន កង្វះវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត កង្វះខាតចំណងទាក់ទងរវាងវិស័យកសិកម្ម និងវិស័យឯទៀតក្នុងសេដ្ឋកិច្ច និង បញ្ហាខាងម៉ាឃីតធីងជាទូទៅ និងសំរាប់ផលិតផលកសិកម្មជាពិសេស ។

យុទ្ធសាស្ត្រទាំងឡាយខាងលើនេះ សុទ្ធតែពាក់ព័ន្ធគ្នាចុះឡើង ហើយវាមានផលប៉ះពាល់ច្រើនណាស់ទៅលើកំណើន និងភាពក្រីក្រ ។ ដោយឡែកគេគួរយកចិត្តទុកដាក់បន្ថែមលើ ការកាត់បន្ថយកត្តារាំងស្ទះដល់ផលិតកម្ម និងការលក់ស្រូវទាំងនៅក្នុង និងទៅក្រៅប្រទេស ។ អតិរេកស្រូវនៅកម្ពុជាមានលើសពី ២លានតោនក្នុងមួយឆ្នាំ ហើយការកែលំអប្រព័ន្ធធារាសាស្ត្រតែមួយមុខ ក៏អាចបង្កើនអតិរេកស្រូវទ្វេមួយជាពីរដែរ ។ ខុសពីផលិតផលកសិកម្មដទៃទៀត ថ្លៃស្រូវនៅទីផ្សារអន្តរជាតិបានកើនឡើងជាប់រហូតក្នុងទសវត្សរ៍នេះ ។ ទោះបីវាបានធ្លាក់ចុះខ្លះៗនៅពេលថ្មីៗក្តី ក៏ថ្លៃស្រូវនៅខ្ពស់ជាងកាលពីឆ្នាំមុននេះដែរ ហើយប្រាក់ចំណូលបានមកពីដំណាំស្រូវតែមួយមុខ ក៏អាចរួមចំណែកបានយ៉ាងច្រើនដល់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ៕

# ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ៖ កសិកម្ម និងការអភិវឌ្ឍជនបទ

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ ឯកឧត្តម ណាំ ទុំ និង បណ្ឌិត ថេង វុទ្ធី[១] នៅវគ្គទីបីៈ ក (១) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

នៅកម្ពុជា ក៏ដូចជានៅតាមប្រទេសលូតលាស់តិចជាងគេឯទៀតដែរ ភាពក្រីក្រ ច្រើនកើតមាននៅតំបន់ជនបទ ហើយវាមានកំរិតកាន់តែខ្ពស់នៅតាមតំបន់ជនបទណាដែលពឹងផ្អែកជាចំបងលើកសិកម្ម សំរាប់ទ្រទ្រង់ជីវិត ដោះស្រាយជីវភាពរស់នៅ និងផ្តល់ការងារ ។ ឈរលើទស្សនៈនេះ គេចាំបាច់ត្រូវផ្តល់តួនាទីស្នូលដល់ វិស័យកសិកម្ម និងកែប្រែចំណាប់អារម្មណ៍សើៗ ដែលវិស័យនេះតែងទទួលបានក្នុងពេលកន្លងមក ។

## ការរួមចំណែកនៃវិស័យកសិកម្មដើម្បីកំណើន និងការងារ

តាំងពីដើមមក ការចូលរួមចំណែកនៃវិស័យកសិកម្មនៅក្នុងកំណើន មិនមានស្ថិរភាពទេ និងពេលខ្លះអវិជ្ជមានទៀតផង ។ ធនាគារពិភពលោក បានវាយតំលៃថា ការចូលរួមចំណែកនៃវិស័យកសិកម្មក្នុង កំណើនប្រចាំឆ្នាំនៅកម្ពុជាពីឆ្នាំ១៩៩៨-២០០៧ មាន ២% ដែលទាបជាខ្លាំង បើធៀបនឹងកំរិត ៤,៥% នៃវិស័យឧស្សាហកម្ម និង ៤,៨%នៃវិស័យសេវាកម្ម ។ សំរាប់ផលិតផលក្នុងស្រុកសរុប (ផសស)ក្នុងឆ្នាំ២០០៧ វិស័យកសិកម្មរួមចំណែកបានប្រមាណ ២៩% ចំណែកឯវិស័យឧស្សាហកម្មបាន ៣០% និងសេវាកម្ម ៤១% ។ វិស័យកសិកម្ម មានកំណើនយឺតជាង វិស័យឧស្សាហកម្ម និងសេវាកម្ម ប៉ុន្តែតាំងពីដើមរៀងមក បានប្រើកម្លាំងពលកម្មភាគច្រើននៅកម្ពុជា ដូចជាក្នុងឆ្នាំ២០០៧ ៥៩% នៃកម្លាំងពលកម្មសរុប បានប្រកបការងារក្នុងវិស័យកសិកម្ម (ក្រាហ្វិក ១) ។ សម្បត្តិធម្មជាតិ និងចំនួនដ៏ច្រើននៃពលករយកកំរៃទាបក្នុង វិស័យកសិកម្ម ក៏បានផ្តល់ឱ្យប្រទេសកម្ពុជានូវសមត្ថភាពប្រកួតប្រជែងខាងកសិកម្មដែរ ។ ដោយសារមូលហេតុទាំងនេះ ការអភិវឌ្ឍកសិកម្មមានសារសំខាន់ដូចគ្នានឹងការធ្វើឧស្សាហូបនីយកម្មដែរ ។ វិស័យនេះនៅមានសក្តានុពលជាច្រើន ដែលមិនទាន់បានប្រើប្រាស់នៅឡើយ ។

វិបត្តិស្បៀងនៅពេលថ្មីៗ និងវិបត្តិសេដ្ឋកិច្ចបច្ចុប្បន្ន បានបង្ហាញច្បាស់ទោះបីមិនសូវរៀបរយក្តី នូវសក្តានុពល និងសារៈសំខាន់នៃវិស័យកសិកម្មកម្ពុជា។ វិបត្តិស្បៀងបានបង្ហាញពីបែបបទដែលវិស័យកសិកម្ម អាចក្លាយជាចង្កូតនៃនាវាសេដ្ឋកិច្ច ហើយវិបត្តិសេដ្ឋកិច្ច បានបង្ហាញពីដំណើរការដែលវិស័យកសិកម្មក្លាយជា ទូកសង្គ្រោះជីវិត នៅពេលនាវាសេដ្ឋកិច្ចត្រូវលិចលង់ ។

ពិតហើយ វិបត្តិទាំងពីរមានផលប៉ះពាល់ផ្ទុយគ្នាទៅលើពាណិជ្ជកម្ម និងផលិតកម្មកសិកម្ម ។ វិបត្តិស្បៀងបានគំរាមកំហែងដល់សន្តិសុខស្បៀងនៅ

១ ឯកឧត្តម ណាំ ទុំ ជាទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និង អភិបាលខេត្តកំពង់ធំ ចំណែកឯ បណ្ឌិត ថេង វុទ្ធី ជាអ្នកសំរបសំរួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន វបសអ ។

ក្រាហ្វិក ១: ចំណែកការងារ គិតជា %




*ប្រភព: ធនាគារពិភពលោក ខែមករា ឆ្នាំ២០០៩*

បណ្តាប្រទេសក្រីក្រ ក៏ពិតមែន ប៉ុន្តែវាក៏ជាកត្តាគេទន្ទឹងយូរមកហើយ ដើម្បីជួយតំលើងថ្លៃកសិផលដែលធ្លាក់ចុះទាប បង្កើតបរិយាកាសអំណោយផលសំរាប់ផលិតករ និងអ្នកនាំចេញ និងប្រោះព្រំឱ្យវិស័យកសិកម្មរស់ឡើងវិញ ។ ជាការខាតបង់សំរាប់ផលិតករ និងអ្នកនាំចេញ ប៉ុន្តែជាផលចំណេញសំរាប់អ្នកប្រើប្រាស់ គឺវិបត្តិនាពេលនេះបានបញ្ចុះថ្លៃទំនិញកសិកម្មវិញ តែមិនទាបដូចមុនទេ ពីព្រោះកំរិតថ្លៃនៅតែខ្ពស់ជាង ថ្លៃជាមធ្យមកាលពីឆ្នាំមុនៗដែរ ។

## ផលប៉ះពាល់នៃវិបត្តិស្បៀងទៅលើកសិកម្ម

តាំងពីឆ្នាំ២០០៦ រហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ការឡើងថ្លៃម្ហូបអាហារបានបញ្ជូនសញ្ញាអាសន្ន ដល់សាកលលោកទាំងមូល ដោយសារផលវិបាកដ៏ធ្ងន់ធ្ងរចំពោះស្ថានភាពអត់ឃ្លានក្នុងពិភពលោក ។ ការឡើងថ្លៃខ្ពស់កប់ពពកវាផុសចេញពីកត្តាជំរុញ ដូចជាវិបត្តិថាមពល ការប្រមូលផលបានតិច លក្ខខណ្ឌអាកាសធាតុមិនអំណោយផល និង កំណើនការប្រកួតប្រជែងរវាងផលិតកម្មជីវឧស្ម័ន និងស្បៀង ។ នៅឆ្នាំ២០០៧ ផលិតផលកសិកម្មនាំចេញចំបង៧របស់កម្ពុជា គឺមាន ស្រូវ ដំឡូងឈើ និងកៅស៊ូ បានឡើងថ្លៃដល់ ២២៥ដុល្លារ ៧០ដុល្លារ និង ២០១៦ដុល្លារ ក្នុងមួយតោន ហើយស្រូវ និងកៅស៊ូ បន្តឡើងថ្លៃទៀតរហូតដល់ ត្រីមាសទី៣ ឆ្នាំ២០០៨ ។ ជាក់ស្តែងណាស់ កំណើនថ្លៃនេះ បានជួយជំរុញផលិតកម្ម ។ ពីឆ្នាំ២០០៧ ដល់ ២០០៨ ផលិតកម្មដំឡូងឈើកើនឡើងប្រហែល ១,២លានតោន និងកៅស៊ូកើនពី ៣២.០០០តោន ដល់ ៣៧.០០០តោន ។ ក្នុងពេលជាមួយគ្នា ផ្ទៃដីដាំដុះដំឡូងឈើសរុប កើន ៨៨% និង ដីដាំកៅស៊ូកើន ៣២% ។ ឯផលិតកម្មស្រូវ និងសណ្តែកសៀង ក៏កើនឡើងស្របគ្នានឹងផ្ទៃដីដាំដុះវាដែរ ។ សរុបមក ការនាំចេញផលិតផលកសិកម្មបានស្ទុះឡើងនៅពាក់កណ្តាលឆ្នាំ ២០០៧ (ក្រាហ្វិក ២) ។

ក្រាហ្វិក ២: ការនាំចេញតាមវិស័យ (គិតជាលានដុល្លារ US)




*ប្រភព: ទីចាត់ការគយ និងរដ្ឋាករ ស្រង់ចេញដោយធនាគារជាតិនៃកម្ពុជា*

ក្រាហ្វិក ៣ : ផលប៉ះពាល់លើចំណូលបានពីផលិតផលកសិកម្មជ្រើសរើសមួយចំនួន




*ប្រភព: ផលប៉ះពាល់នៃថ្លៃអាហារខ្ពស់នៅកម្ពុជា (វិបសអ ឆ្នាំ២០០៨) និងតារាងតំលៃផលិតផល ខែមករា ឆ្នាំ២០០៧ ដល់ ២០០៩*

## ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ទៅលើវិស័យកសិកម្ម

សេដ្ឋកិច្ចសាកលធ្លាក់ចុះ បានបំបាត់និន្នាការអតិផរណាខ្ពស់ ដោយវាបានកាត់បន្ថយតំរូវការសាកល និងធ្វើឱ្យថាមពលធ្លាក់ថ្លៃ ។ នៅឆ្នាំ២០០៨ ផលដំឡូងឈើ និងកៅស៊ូនៅកម្ពុជា ធ្លាក់ថ្លៃជាខ្លាំង មកត្រឹម ៣០ដុល្លារអាមេរិក និង ១០២០ដុល្លារអាមេរិក ក្នុងមួយតោន ឬធ្លាក់ចុះប្រហែល ៥០% ធៀបនឹងកាលពីឆ្នាំទៅ ។ នៅឆ្នាំ២០០៨ ផលិតកម្មដំឡូងឈើ និងកៅស៊ូកើនឡើង ប៉ុន្តែនៅត្រីមាសទី៤ កំណើនផលិតកម្មពីមួយឆ្នាំទៅមួយឆ្នាំបានរួមចុះយ៉ាងខ្លាំងវិញ ។ តម្លៃនាំចេញនៃដំឡូងឈើ និងកៅស៊ូ ធ្លាក់ចុះ ហើយតាមការប៉ាន់ស្មាន ដំឡូងឈើបានបាត់បង់តម្លៃនាំចេញ ៩៥លានដុល្លារ ហើយកៅស៊ូបានបាត់បង់ ៣៧លានដុល្លារ ។ ការនាំចេញសណ្ដែកសៀង និងពោត ក៏រងផលប៉ះពាល់ពីវិបត្តិដែរ ។ ប៉ុន្តែចំណុចគួរកត់សម្គាល់ គឺការនាំចេញស្រូវរបស់កម្ពុជា អាចធន់ទ្រាំបាននឹងល្អ ហើយពីឆ្នាំ២០០៧ ដល់ ២០០៨ តម្លៃនាំចេញបានកើនឡើងថែមទៀត ។

ស្ថានភាពខាងលើបង្ហាញច្បាស់ថា វិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរជាងគេដល់កសិករធម្មតាៗដែលដាំដំឡូងឈើ និងកៅស៊ូ ។ ចំណាយលើធាតុចូលខ្ពស់ គួបផ្សំនឹងការធ្លាក់ចុះកំរិតថ្លៃ នឹងតំរូវការ បានកាត់បន្ថយប្រាក់ចំណេញរបស់ប្រជាកសិករ ។ គេប៉ាន់ស្មានថា នៅឆ្នាំ២០០៨ កសិករដែលដាំដំឡូងឈើត្រូវទទួលការខាតបង់ ហើយកសិករដែលដាំកៅស៊ូ មានប្រាក់ចំណេញថយចុះជាខ្លាំង ។ នៅចុងឆ្នាំ២០០៨ ស្រូវប្រាំង ស្រូវវស្សា ពោត និងសណ្ដែកសៀងនៅតែអាចផ្ដល់ប្រាក់ចំណេញ ប៉ុន្តែសំរាប់ ស្រូវវស្សា ពោត និងសណ្ដែកសៀងប្រាក់ចំណេញនេះបានថយចុះ (ក្រាហ្វិក ៣) ។ ដោយសារការធ្លាក់ចុះប្រាក់ចំណូល ប្រជាកសិករដែលរងផលប៉ះពាល់ កាន់តែលំបាកជាងមុនក្នុងការប្រមូលទុនវិនិយោគមកវិញ ឬសងបំណុលគេ ។

ទោះបីមានឧបសគ្គរាំងដល់ផលដំណាំសំរាប់នាំចេញក្ដី ក៏គេប៉ាន់ស្មានថា វិស័យកសិកម្មកម្ពុជាទាំងមូល មានកំណើន ៤,៥% នៅឆ្នាំ២០០៨ ។

## ឱកាស និង គោលនយោបាយជាសក្ដានុពល

គេមិនគួរមើលស្រាលពីសារៈសំខាន់នៃវិស័យកសិកម្មដែលអាចធន់ទ្រាំបានល្អនិងវិបត្តិ ជួយទប់ទល់ការធ្លាក់ចុះសេដ្ឋកិច្ចនេះទេ ។ ក្នុងពេលមានការព្យាករណ៍ទុទិដ្ឋិនិយមនៅគ្រប់កន្លែង កសិកម្មជាវិស័យភ្លឺថ្លាមួយ ដែលទំនងមានដំណើរការរីកចំរើនបន្តទៀតនៅឆ្នាំនេះ ទោះបីការធ្លាក់ចុះកំរិតថ្លៃនៅតែចោទជាបញ្ហាក្ដី ។ អង្កេតមួយស្ដីពីឱកាសល្អមានស្រាប់ និងឱកាសល្អរំពឹងទុក បានបង្ហាញពីសក្ដានុពលដ៏ធំធេងនានាដែលបង្កប់នៅក្នុងវិស័យកសិកម្ម និងដែលគេអាចមើលឃើញមួយភាគនៅអំឡុងពេលមានវិបត្តិស្បៀង និងសេដ្ឋកិច្ច ។ ជាបឋម គេរំពឹងថា សំពាធបរិត្តផរណាលើកំរិតថ្លៃផលិតផលកសិកម្ម នឹងមិនអូសបន្លាយយូរទេ ដោយសារតំរូវការពីចិន ឥណ្ឌា និងតំបន់មជ្ឈិមបូព៌ាទំនងជាកើនឡើងវិញ ។ ទីពីរ កម្ពុជានៅមានលទ្ធភាពពង្រីកផ្ទៃដីដាំដុះយ៉ាងច្រើន ។ ទីបី កិច្ចព្រមព្រៀងទ្វេភាគីជាមួយ បណ្ដាប្រទេសនៅមជ្ឈិមបូព៌ា អាហ្វ្រិក និងអាស៊ីបូព៌ា (ជាពិសេស ប្រទេសចិន) នឹងបើកចំហទីផ្សារកាន់តែច្រើន សំរាប់ផលិតផលកសិកម្មកម្ពុជា ។

លក្ខខណ្ឌបឋមក្នុងការចាប់យកឱកាស គឺការអនុវត្តនូវគោលនយោបាយជាអាទិភាពមួយចំនួន ។ អនុសាសន៍មួយដែលតែងមានលើកឡើងជារឿយៗ គឺការបង្កើនវិនិយោគខាងកសិកម្ម ។ ដើម្បីបង្កើនផលិតកម្ម និងផលិតភាព គេត្រូវដោះស្រាយផងដែរនូវបញ្ហា កំណែទម្រង់ដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ។ ចំពោះកំណែទម្រង់ដីធ្លី ដំណើរការចុះបញ្ជីដីធ្លី ការធានាកម្មសិទ្ធិអចលនទ្រព្យ និង ការកែលំអការបែងចែក និងគ្រប់គ្រងដីធ្លី ត្រូវតែពន្លឿនថែមទៀត ។ ប្រព័ន្ធធារាសាស្ត្រ និងផ្លូវជនបទ ត្រូវកែលំអឡើង ។ គេប៉ាន់ស្មានថា ផលចំណេញពីវិនិយោគលើធារាសាស្ត្រ អាចបានរហូតដល់ពីរដងនៃទឹកប្រាក់វិនិយោគ ។ បណ្ដាញផ្លូវថ្នល់ដែលកែលំអរួចនឹងកាត់បន្ថយចំណាយផលិតកម្ម និងតំឡើងកំរិតថ្លៃនៅកសិដ្ឋាន ។ គេត្រូវផ្ដល់កម្ចីកាន់តែច្រើន ជាមួយការប្រាក់កាន់តែទាប និងរយៈពេលសងកាន់តែវែង ដើម្បីជួយសំរួលឱ្យមានវិនិយោគខាងកសិកម្មកាន់តែច្រើន ។ ត្រូវជំរុញផងដែរនូវការប្រើប្រាស់គ្រាប់ពូជមានទិន្នផលខ្ពស់ និងការប្រើប្រាស់ជីឱ្យបានកាន់តែប្រសើរ ។ គេរកឃើញថា កំណើន ១%នៃការប្រើប្រាស់ជីបានត្រឹមត្រូវ នឹងបង្កើនទិន្នផលបាន 0,២២% សំរាប់ស្រូវប្រាំង និង 0,២៧% សំរាប់ស្រូវវស្សា ។ ដើម្បីបង្កើនពាណិជ្ជកម្មកសិកម្ម គេចាំបាច់ត្រូវបន្តកាត់បន្ថយចំណាយលើការជួញដូរ អភិវឌ្ឍបច្ចេកវិទ្យាត្រូវប្រើក្រោយពេលប្រមូលផល និងសិក្សារិះរកគ្រោងការផ្សេងៗ ដូចជា ការចុះកិច្ចសន្យាធ្វើកសិកម្ម ជាដើម ។ ការកែលំអព័ត៌មានទីផ្សារ ក៏ចាំបាច់ដែរ ។ បច្ចុប្បន្នព័ត៌មានទីផ្សារនៅមានតិច ហើយរឿងនេះបានប៉ះពាល់ដល់ប្រជាកសិករសាមញ្ញ ពីព្រោះដោយសារមិនបានដឹងពីកំរិតថ្លៃបច្ចុប្បន្ន ពួកគាត់ក៏ងាយត្រូវគេបោកប្រាស់ ។ ដើម្បីអភិវឌ្ឍកសិកម្មដែលអំណោយផលដល់អ្នកក្រ ត្រូវមានការដោះស្រាយ បញ្ហាទាំងនេះជាអាទិភាព ៕

### តើអ្នកបានដឹងទេ ថា

*... ផលិតកម្មជីវឥន្ធនៈ បានប្រកួតប្រជែងជាមួយនឹងផលិតកម្មស្បៀង និងប៉ះពាល់ដល់កំរិតថ្លៃទំនិញប្រើប្រាស់សាកល ?* ទោះបីចំណែកនៃជីវឥន្ធនៈនៅក្នុងការប្រើប្រាស់ និងការផ្គត់ផ្គង់ថាមពលសាកលនៅមានតិចតួច និងនៅតែមានតិច (ពី 0,៩%នៃការប្រើប្រាស់ថាមពលដឹកជញ្ជូនសរុបនៅក្នុងឆ្នាំ២០០៨ ដល់ប្រហែល ២,៣% នៅឆ្នាំ២០១៥) កំណើនតំរូវការជីវឥន្ធនៈ ជាពិសេស អេតាណុល បានប៉ះពាល់គួរកត់សំគាល់ទៅលើផលិតកម្ម និងថ្លៃដំណាំ ដូចជា ដំឡូងឈើ ជាដើម ។ គេរំពឹងថា ដំឡូងឈើ នឹងឡើងថ្លៃជាមធ្យម ១១% ដោយសារការពង្រីកផលិតកម្មជីវឧស្ម័ន ។

*ប្រភព : អង្គការស្បៀង និងកសិកម្ម (Food and Agriculture Organization-FAO) 2008*

*...ប្រជាជនកម្ពុជារាប់លាននាក់ អាចកំពុងកាន់កាប់ដីរបស់ខ្លួនដោយស្របច្បាប់ ប៉ុន្តែពុំមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ?* យោងតាមច្បាប់ភូមិបាល ឆ្នាំ២០០១ អ្នកកាន់កាប់ដីដោយស្របច្បាប់មានសិទ្ធិស្នើសុំការចុះបញ្ជីដីធ្លី និងរស់នៅលើដីនោះ រហូតទាល់តែទទួលបានការចុះបញ្ជីដីនោះ ។ ប៉ុន្តែ ទោះបីមានកម្មវិធីរដ្ឋបាល និងគ្រប់គ្រងដីធ្លី ដែលទទួលបានការគាំទ្រពី ម្ចាស់ជំនួយជាច្រើនក្ដី ក៏មានការរិះគន់ថា ការចុះបញ្ជីដីធ្លី មានដំណើរការយឺត និងមានលក្ខណៈរើសអើង ។

*ប្រភព: ក្រុមការងារលើដីធ្លី និងសំណង់នៅកម្ពុជា (Land and Housing Working Group Cambodia) 2009*

# វិបត្តិអាហារ និង ហិរញ្ញវត្ថុ — ផលប៉ះពាល់លើវិស័យកសិកម្ម និង អាទិភាពគោលនយោបាយជំរុញកំណើនកសិកម្មអំណោយផលដល់ជនក្រីក្រ

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ បណ្ឌិត ថេង វុទ្ធី[១] នៅក្នុងវគ្គទី ៣ក(១) នៃសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## និន្នាការទូទៅនៃកសិកម្មកម្ពុជា និង ផលប៉ះពាល់នៃវិបត្តិ

ក្នុងរយៈពេលបីឆ្នាំមុនពេលមានវិបត្តិហិរញ្ញវត្ថុសាកល សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងខ្លាំង ដោយមានកំណើន ផសស ជាមធ្យមប្រហែល ១១% ។ តួលេខសរុបលើម៉ាក្រូសេដ្ឋកិច្ចកម្ពុជា មានកំរិតខ្ពស់ទាំងអស់ ហើយកំណើនបានជាចំបងមកពីវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ ។ ខណៈដែលឧស្សាហូបីយកម្មសេដ្ឋកិច្ចបានជឿនលឿនទៅមុខយ៉ាងច្រើន កសិកម្មនៅតែជាវិស័យមួយសំខាន់ខ្លាំងណាស់ ។ យោងតាមរបាយការណ៍ថ្មីមួយរបស់ធនាគារពិភពលោក កសិកម្មចូលរួមចំណែក ២៩% នៃ ផសស (ក្រាហ្វិក ១) និងប្រើប្រាស់ ៥៩% នៃកំលាំងពលកម្មនៅឆ្នាំ២០០៧ (ក្រាហ្វិក ២) ។ ក្នុងមួយទសវត្សរ៍កន្លងមកនេះ វិស័យកសិកម្មមានកំណើន ៤,៤% ក្នុងមួយឆ្នាំ នៅកម្ពុជា ធៀបនឹង ៤% នៅវៀតណាម និង ៣,៩% នៅឡាវ ។ កំណើននេះបានមកពីការដាំដំណាំ (ជាពិសេស ស្រូវ) និងបន្ទាប់មក ការចិញ្ចឹមសត្វ និងត្រី ។

ថ្លៃអាហារខ្ពស់ បានផ្ដល់ជាគ្រឿងលើកទឹកចិត្តដល់អ្នកបង្កើតគោលនយោបាយ កសិករ និង វិនិយោគិន នៅក្នុងប្រទេសកំពុងអភិវឌ្ឍ ឱ្យបង្កើនផលិតភាពកសិកម្ម ។ នៅកម្ពុជា កសិករ និង វិនិយោគិនបរទេស បានឆក់យកឱកាសនេះ ដោយធ្វើពិពិធកម្ម និងពង្រីកផ្ទៃដីដាំដំណាំសំរាប់នាំចេញសំខាន់ៗផ្សេងទៀតបន្ថែមលើ ដំណាំស្រូវ ដូចជា ដំឡូងឈើ កៅស៊ូ ពោត និងសណ្ដែកសៀង ជាដើម ។ នៅឆ្នាំ២០០៨ ផ្ទៃដីសំរាប់ដាំដំណាំទាំងនេះ កើនដល់ ១៨០.០០០ហិកតា សំរាប់ដំឡូងឈើ ១០៨.៧០០ហិកតា សំរាប់កៅស៊ូ ១៥៦.៧៦០ហិកតា សំរាប់ពោត ៧១.៩៣០ហិកតា សំរាប់សណ្ដែកសៀង និង ២.៥៩៣.៤០០ហិកតា សំរាប់ស្រូវ ។

ស្រូវ និង ដំណាំផ្សេងៗទៀតសំរាប់នាំចេញ បានរួមចំណែក ៥២% នៃ ផសស របស់វិស័យកសិកម្ម និង ១៤% នៃ ផសស សរុប នៅឆ្នាំ២០០៧ ។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលកាន់តែធ្ងន់ធ្ងរ នៅឆមាសទី២ ឆ្នាំ២០០៨ បានធ្វើឱ្យទំនិញកសិកម្មធ្លាក់ថ្លៃ ។ កសិករនៅប្រទេសកំពុងអភិវឌ្ឍ ដែលបានយកប្រាក់ចំណេញទទួលបានពី ការឡើងថ្លៃផលិតផលកសិកម្មកាលពីមុនទៅវិនិយោគពង្រីកផលិតកម្ម ឥឡូវនេះទំនងមិនអាចសងបំណុលរបស់ខ្លួនបានទេ ដោយសារបរិមាណលក់ និងប្រាក់ចំណូល បានធ្លាក់ចុះ ។ ដោយហេតុថា កម្ពុជាពឹងផ្អែកលើ ទីផ្សារនាំចេញ និង វិនិយោគផ្ទាល់ពីបរទេស (FDI) ដូច្នេះ វិបត្តិសាកលអាចប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

វិបត្តិប៉ះពាល់សេដ្ឋកិច្ចកម្ពុជាធ្ងន់ធ្ងរដល់កំរិតណា គឺអាស្រ័យលើទំហំសមាហរណកម្មនៃវិស័យជំនួញ និងហិរញ្ញវត្ថុ របស់កម្ពុជាទៅក្នុងទីផ្សារពិភពលោក ។ ដោយហេតុថា ប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាបានធ្វើសមាហរណកម្មតិចតួចទៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក ដូច្នេះប្រទេសកម្ពុជាមិនបានទទួលរងការប៉ះទង្គិចដោយផ្ទាល់ពីវិបត្តិនេះទេ ។ វិស័យធនាគារនៅកម្ពុជានៅតែមានស្ថានភាពល្អ ដោយមានសាច់ប្រាក់ទំនេរ និងប្រាក់បញ្ញើសន្សំយ៉ាងច្រើន និង មានការទុកចិត្តពីសំណាក់ប្រជាជនទៀតផង ។ ផ្ទុយទៅវិញ វិស័យជំនួញបានធ្វើសមាហរណកម្មយ៉ាងច្រើនក្នុងទីផ្សារតំបន់ និងពិភពលោក ដូច្នេះហើយក៏រងឥទ្ធិពលដោយផ្ទាល់ពីការធ្លាក់ចុះ តំរូវការ និងកំរិតថ្លៃទំនិញ ។

វិនិយោគលើទំនិញសំរាប់នាំចេញ បានផ្ដល់ការងារជាច្រើនដល់គ្រួសារអ្នកគ្មានដី ។ ដូចនេះ ការធ្លាក់ចុះ តំរូវការ និងកំរិតថ្លៃទំនិញដោយសារវិបត្តិបានជះឥទ្ធិពលធ្ងន់ធ្ងរមិនត្រឹមតែលើ ប្រាក់ចំណូលរបស់ផលិតករ និង វិនិយោគិន ប៉ុណ្ណោះទេ ប៉ុន្តែលើប្រាក់ចំណូលរបស់កម្មករ និងរបស់រដ្ឋាភិបាលទៀតផង ។

ក្រាហ្វិក ១: ផសស របស់កម្ពុជា ឆ្នាំ២០០៧




*ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញក្នុងវេទិកាក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលើកទី២ ខែធ្នូ ឆ្នាំ២០០៨*

## ផលប៉ះពាល់លើពាណិជ្ជកម្មកសិកម្ម

ទំនិញនាំចូលសំខាន់ៗរបស់កម្ពុជា រួមមាន ប្រេងឥន្ធនៈ ម្ហូបអាហារ ភេសជ្ជៈ សម្ភារៈសំណង់ យានយន្ត ជីកសិកម្ម និង ថ្នាំពេទ្យ ។ នៅត្រីមាសទី២ ឆ្នាំ២០០៨ តំលៃនៃការនាំចូលបានកើនឡើង ដែលបង្ហាញពីតំរូវការខ្ពស់នូវធាតុចូលសំរាប់កសិកម្ម ដូចជា សាំង ជីកសិកម្ម និង សារធាតុគីមី ។ កំណើនវិនិយោគក្នុងវិស័យនេះ បណ្ដាលមកពីការវាយស្មានថា តំរូវការទំនិញកសិកម្ម នឹងបន្តកើនឡើង ជាពិសេស ដំឡូងឈើ និង ពោត សំរាប់ប្រើប្រាស់ក្នុងការផលិតអេតាណុល (ឥន្ធនៈអាចប្រើជំនួស ផលិតផលប្រេងកាតដែលឡើងថ្លៃខ្លាំងណាស់នៅ ទីផ្សារពិភពលោក) ។ តំលៃដ៏ខ្ពស់នៃទំនិញនាំចូលជាកត្តាចំបងមួយនៃកំណើនបន្ទុកចំណាយលើឥន្ធនៈ និងធាតុចូលដទៃទៀត (ក្រាហ្វិក ៣) ។

---

១ បណ្ឌិត ថេង វុទ្ធី ជាអ្នកសំរបសំរួលកម្មវិធីភាពក្រីក្រ កសិកម្ម និង អភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI ។

ក្រាហ្វិក ២: ចំណែកការងារ គិតជា %




*ប្រភព: ធនាគារពិភពលោក (២០០៩), ការរក្សាកំណើនលឿននៅក្នុងបរិយាកាសប្រឈម*

ក្រាហ្វិក ៣: ការនាំចេញនាំចូល (អត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព: ទីចាត់ការគយ និងរដ្ឋាករ ស្រង់ចេញដោយធនាគារជាតិនៃកម្ពុជា*

កំណើនតម្រូវការពីខាងក្រៅនូវផលិតផលកម្ពុជា នៅថេររហូតដល់អំឡុងខែមិថុនា ២០០៨ ទើបមានការធ្លាក់ចុះយ៉ាងខ្លាំង ។ ការនាំចេញផលិតផលកសិកម្មបានធ្លាក់ចុះ ដោយធ្លាក់ដល់កម្រិតទាបបំផុតក្នុង ២០ខែចុងក្រោយនេះ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។ ការធ្លាក់ចុះនូវតំលៃនៃការនាំចេញផលិតផលកសិកម្ម បណ្ដាលជាសំខាន់មកពី ទំនិញកសិកម្មដែលចុះថ្លៃដោយសារវិបត្តិ ។ ការប្រែប្រួលរហ័សនៃនិន្នាការអតិផរណាថ្លៃអាហារ និងឥន្ធនៈ ឆ្លុះបញ្ចាំងពីការធ្លាក់ចុះតម្រូវការពិភពលោក ។ ទោះយ៉ាងនេះក្ដី គេមិនមានភស្តុតាងគ្រប់គ្រាន់ទេសំរាប់បញ្ជាក់ថា វិបត្តិគឺជាមូលហេតុតែមួយដែលនាំឱ្យការនាំចេញទំនិញកសិកម្មធ្លាក់ចុះ ។ ជំលោះព្រំដែនរវាងកម្ពុជា-ថៃ នៅឆមាសទី២ ឆ្នាំ២០០៨ ក៏មានរួមចំណែកក្នុងការធ្លាក់ចុះការនាំចេញនេះដែរ ជាពិសេសការនាំចេញដំឡូងឈើ និង ពោត ដែលកសិករកម្ពុជាមួយចំនួនបានធ្វើកិច្ចសន្យាជាមួយពាណិជ្ជករថៃរួចហើយ ។

## ផលប៉ះពាល់លើចំណូល និងវិនិយោគក្នុងវិស័យកសិកម្ម

កំណើនតម្រូវការជីវឥន្ធនៈនៅប្រទេសអភិវឌ្ឍន៍ បានបង្កើនកម្រិតថ្លៃ និងតម្រូវការផលដំណាំដូចជា ដំឡូងឈើ និង ពោត ជាដើម ។ រឿងនេះ ផ្ដល់គ្រឿងលើកទឹកចិត្តដល់ម្ចាស់ដីតូចៗ និង វិនិយោគិន ឱ្យពង្រីកផលិតកម្ម ។ នៅកម្ពុជា ផលិតកម្មដំណាំអាហារទាំងនេះ កើនដល់ ៣,៩៧លានតោន នៅឆ្នាំ២០០៨ ធៀបនឹង ២,៨៨លានតោន នៅឆ្នាំ២០០៧ ។ ជាអកុសល ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បានបន្ទាបតម្រូវការ និងថ្លៃទំនិញនានា ។ ឧទាហរណ៍ ថ្លៃប្រេងនាពេលបច្ចុប្បន្ន ធ្លាក់ចុះលើសពី ៦០% បើធៀបនឹងកម្រិតថ្លៃខ្ពស់បំផុត នៅឆ្នាំ២០០៨ ។ ការធ្លាក់ថ្លៃនេះ បានកាត់បន្ថយតម្រូវការជីវឥន្ធនៈ និង សារធាតុសំរាប់លាយបន្ថែមជាមួយឥន្ធនៈ ដូចជា អេតាណុល ជាដើម ដែលនាំឱ្យផលដំណាំសំរាប់ផលិតជីវឥន្ធនៈ ធ្លាក់ថ្លៃយ៉ាងខ្លាំង ។ បើសិនគ្មានការធ្លាក់ថ្លៃនេះទេ នៅឆ្នាំ២០០៨ ផលិតករពោត និង ដំឡូងឈើ ប្រហែលអាចបង្កើនប្រាក់ចំណេញដុលបានដល់ ៨២% និង ១៧៦% បើធៀបនឹង ឆ្នាំ២០០៧ ហើយប្រាក់ចំណេញដុលសំរាប់សណ្ដែកសៀង ក៏ប្រហែលកើនឡើង ៤៦% ផងដែរ ។ ប៉ុន្តែដោយសារ ការធ្លាក់ថ្លៃយ៉ាងរហ័សនៃដំណាំទាំងនេះនៅឆមាសទី២ ឆ្នាំ២០០៨ ប្រាក់ចំណេញសរុបលើពោត សណ្ដែកសៀង និង ដំឡូងឈើ បានធ្លាក់ចុះអស់ ២៩% ៤៧% និង ១៦៦% ។ ចំណាយលើធាតុចូលសំរាប់ដំណាំទាំងនេះមានកម្រិតខ្ពស់ដដែល ពីព្រោះធាតុចូលត្រូវបានប្រើប្រាស់ នៅត្រីមាសទី២ និង ទី៣ ប៉ុន្តែ ផលិតផលបានធ្លាក់ថ្លៃខ្លាំង នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។

មុនពេលមានវិបត្តិ ផលិតកម្មដំណាំឧស្សាហកម្ម ដូចជា កៅស៊ូ ជាដើម បានផ្ដល់ផលចំណេញច្រើនណាស់ ដល់ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនឯកជន និង ម្ចាស់ដីតូចៗ ។ នៅខែតុលា ២០០៨ ថ្លៃកៅស៊ូនៅទីផ្សារពិភពលោក ឡើងដល់ ៣២០០ដុល្លារ/តោន ប៉ុន្តែធ្លាក់ចុះមកត្រឹម ១២០០-១៣០០ដុល្លារ នៅខែធ្នូ ២០០៨ ។ វិបត្តិ បានធ្វើឱ្យការនាំចេញធ្លាក់ចុះអស់ ១៥,២% ។ នៅឆ្នាំ២០០៨ ប្រាក់ចំណេញពីដំណាំកៅស៊ូ ស្ទើរតែគ្មានសោះ ពីព្រោះផលិតកម្ម កៅស៊ូត្រូវការចំណាយ ៨០០ដុល្លារ/តោន (គ្មានបូកបញ្ចូលការប្រាក់លើកំចី ពន្ធ និង ចំណាយពាក់ព័ន្ធផ្សេងទៀត) ហើយថ្លៃកៅស៊ូនៅកម្ពុជា វាទាបជាងកម្រិតថ្លៃនៅទីផ្សារពិភពលោក ប្រហែល ១៥% ។ រដ្ឋាភិបាល និងដៃគូផ្នែកឯកជន បានជួបពិភាក្សាពីការធ្លាក់ថ្លៃយ៉ាងខ្លាំងនៃជ័រកៅស៊ូ និងស្ថានភាពគួរឱ្យបារម្ភនៃផលិតកម្មកៅស៊ូ ព្រមទាំងបានពិគ្រោះពីសំណើកាត់បន្ថយប្រាក់កំរៃលើការនាំចេញ ។ ទោះយ៉ាងនេះក្ដី ឯកឧត្តម បណ្ឌិត ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ផលិតកម្មកៅស៊ូ នៅតែអាចរកចំណេញបាន ពី ២% ទៅ ៣% ដែរ នៅពេលដែលរដ្ឋាភិបាល មិនទាន់បានឆ្លើយតបនឹង សំណើកាត់បន្ថយប្រាក់កំរៃលើការនាំចេញនេះ ។

ខុសប្លែកពី កៅស៊ូ ពោត និងដំឡូងឈើ ដំណាំស្រូវមិនបានរងឥទ្ធិពលខ្លាំងពីវិបត្តិទេ ។ នៅឆ្នាំ២០០៨ វិនិយោគិន លើដំណាំស្រូវប្រាំង អាចបង្កើនប្រាក់ចំណូលបាន ៣៣% បើធៀបនឹងឆ្នាំ២០០៧ ។ ប៉ុន្តែក្នុងឆ្នាំដូចគ្នា ប្រាក់ចំណូលរបស់វិនិយោគិនលើស្រូវវស្សា បានធ្លាក់ចុះ ១១% ដែលមិនមែនដោយសារស្រូវវស្សាធ្លាក់ថ្លៃនោះទេ ព្រោះវាមានថ្លៃខ្ពស់ជាងកាលពីឆ្នាំ ២០០៧ ទៅទៀត ប៉ុន្តែដោយសារ ការចំណាយខ្ពស់ជាងមុនលើធាតុចូល ។

## ផលប៉ះពាល់លើពលកម្ម

ថ្លៃទាបនៃទំនិញសំរាប់នាំចេញមួយចំនួន អាចបង្កឱ្យមានការកាត់បន្ថយវិនិយោគ និងការធ្លាក់ចុះតម្រូវការពលកម្ម ។ ដូច្នេះ គ្រួសារដែលមិនមានដីធ្លី និងដែលពឹងផ្អែកខ្លាំងលើប្រាក់ឈ្នួលបានពីពលករចំណាកស្រុកខាងកសិកម្ម ទំនងត្រូវប្រឈមមុខនឹងការលំបាក ។ ពួកគេជាជនក្រីក្របំផុត ហើយវិបត្តិនឹងរុញច្រានពួកគេឱ្យធ្លាក់ខ្លួនក្រកាន់តែខ្លាំងទៀត ប្រសិនបើមិនមានការដាក់អនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមប្រកបដោយប្រសិទ្ធភាពនោះទេ ។

## កាលានុវត្តភាព និង បញ្ហាប្រឈមចំពោះកំណើនកសិកម្មអំណោយផលដល់ជនក្រីក្រ

បច្ចុប្បន្ននៅមានឱកាសល្អជាច្រើន ដែលអាចបន្តជួយលើកស្ទួយវិស័យកសិកម្មនៅកម្ពុជា ។ ឱកាសល្អទី១ និងសំខាន់ជាងគេ គឺតម្រូវការដែលរំពឹងថានឹងនៅតែមានច្រើន ដោយគេគិតថា តម្រូវការពីប្រទេសចិន ឥណ្ឌា អាហ្វ្រិក និង តំបន់មជ្ឈិមបូព៌ា នឹងកើនឡើងយ៉ាងលឿន ហើយការធ្លាក់ចុះកម្រិតថ្លៃទំនិញនាពេលថ្មីៗអាចមានរយៈពេលមិនយូរទេ ។ ដោយមូលហេតុនេះ រួមនឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងវិស័យកសិកម្ម (ដីធ្លីសំបូរ ពលកម្មថោក និងសក្ដានុពលក្នុងការបង្កើនវិនិយោគខាងកសិកម្ម) រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា មានទំនុកចិត្តថា កសិកម្មអាចជាកត្តាគន្លឹះសំរាប់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព នៅក្នុងពេលដ៏លំបាកនេះ ។

ដោយសារវិបត្តិបានប៉ះពាល់ធ្ងន់ធ្ងរដល់ឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ កម្មករជាច្រើនបានបាត់បង់ការងារ ហើយត្រូវបង្ខំចិត្តត្រឡប់ទៅធ្វើស្រែចំការនៅភូមិកំណើតវិញបើសិនមានលទ្ធភាព ។ តាមនេះ គេអាចឃើញច្បាស់ពីសារៈសំខាន់នៃវិស័យកសិកម្ម ក្នុងការផ្ដល់ការងារ និងជួយទ្រទ្រង់សេដ្ឋកិច្ច នៅពេលដែល វិស័យឯទៀតស្រុតចុះ ។ សក្ដានុពលមានយ៉ាងច្រើនក្នុងវិស័យកសិកម្ម ហើយដើម្បីឱ្យវាក្លាយជាការពិត គេគួរបង្កើនវិនិយោគជាសំខាន់ ។ កម្ពុជាមានលទ្ធភាពបង្កើនទិន្នផលស្រូវឱ្យស្មើគ្នានឹងប្រទេសជិតខាងបាន ប្រសិនបើកម្ពុជាមានហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាសមស្រប ។ ប៉ុន្តែទន្ទឹមគ្នានឹងសក្ដានុពល ក៏មានបញ្ហាប្រឈមធំៗមួយចំនួនដែរ (សូមមើលក្នុងប្រអប់ខាងក្រោម) ដែលត្រូវដោះស្រាយ ដើម្បីសំរេចបានកំណើនកសិកម្មអំណោយផលដល់ជនក្រីក្រ និងការកាត់បន្ថយភាពក្រីក្រ ៕

**ប្រអប់: បញ្ហាប្រឈមសំរាប់វិស័យកសិកម្ម***

| | |
|---|---|
| **កំណែទំរង់ការគ្រប់គ្រង និង ប្រើប្រាស់ដី** | ផ្ទៃដីធំៗសំរាប់សម្បទានដីសេដ្ឋកិច្ច គួរផ្ដល់នៅកន្លែងដែលសំបូរគ្រួសារគ្មានដីធ្លី ដើម្បីបង្កើតការងារសំរាប់សមាជិកគ្រួសារទាំងនោះ ។ រដ្ឋាភិបាល គួរផ្ដោតលើគោលនយោបាយដ៏ប្រសើរមួយដើម្បីបែងចែកដីសាជាថ្មី ដល់គ្រួសារអ្នកគ្មានដីធ្លី ព្រោះអ្នកកាន់កាប់ដីតូចៗមានផលិតភាពខ្ពស់ជាងក្នុងការដាំដុះមុខដំណាំជាច្រើន ហើយគោលនយោបាយនេះមានឥទ្ធិពលខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច ។ បញ្ហាធំមួយទៀតនៅពេលនេះ គឺ ការចុះបញ្ជីដីធ្លី ព្រោះការទន្ទ្រានយកដីកាន់កាប់ បាននិងកំពុងគំរាមកំហែង ដល់កសិករក្រីក្រជាច្រើន ។ យុទ្ធសាស្ត្រដោះស្រាយបញ្ហានេះរួមមាន ការពង្រឹងដល់ការគោរពកម្មសិទ្ធិអចលនទ្រព្យរបស់អ្នកក្រ ការធ្វើនិត្យានុកូលកម្មការដោះដូរដែលជាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិ និង ការជំរុញគោលនយោបាយប្រើប្រាស់ដី ឱ្យមានប្រយោជន៍ និងមានសមធម៌សំរាប់ជនគ្រប់រូប ។ |
| **ការកសាង ហេដ្ឋារចនាសម្ព័ន្ធ** | របាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០០៩ បានឱ្យដឹងថា វិនិយោគលើធារាសាស្ត្របានផ្ដល់ផលត្រឡប់យ៉ាងច្រើន : អនុបាតចំណេញ-ចំណាយ (ចំណូលបន្ថែមក្នុងមួយហិកតាផ្ទៃដីមានប្រព័ន្ធធារាសាស្ត្រ ចែកនឹងចំណាយឯកតាលើការផ្ដល់ធារាសាស្ត្រ) មានចាប់ពី ១.៥ នៅតំបន់ទន្លេសាប រហូតដល់ ១.៩ នៅតំបន់វាលទំនាប នៅឆ្នាំ២០០៤ និងកើនលើសពី ២ នៅឆ្នាំ២០០៧ ។ ដូច្នេះការកែលំអគំរោងធារាសាស្ត្រដែលមានស្រាប់ ឬ ការវិនិយោគលើធារាសាស្ត្រ វាជួយបង្កើនផលិតភាព និងចំរុះកម្ម ដំណាំដាំដុះ ។ ហេដ្ឋារចនាសម្ព័ន្ធជនបទគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ក៏ជួយកាត់បន្ថយចំណាយផលិតកម្ម និងបង្កើនកំរិតថ្លៃនៅកសិដ្ឋានដែរ ។ ហេដ្ឋារចនាសម្ព័ន្ធជនបទនៅកម្ពុជា ច្រើនជួបបញ្ហាដូចជា ផ្លូវថ្នល់មិនគ្រប់គ្រាន់ និង កង្វះការថែទាំផ្លូវ ជាដើម ។ បន្ទុកចំណាយក្នុងផ្នែកនេះ កាន់តែធ្ងន់ធ្ងរឡើងទៀត ដោយសារការបង់ប្រាក់កំរៃក្រៅផ្លូវការនៅពេលដឹកជញ្ជូនទំនិញ ។ |
| **ការបង្កើនហិរញ្ញប្បទាន** | ការបង្កើនកំចីកសិកម្ម គឺជាកិច្ចខំប្រឹងប្រែងមួយដើម្បីសំរាលផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។ កំចី ជួយផ្ដល់ប្រាក់បន្ថែមសំរាប់ការពង្រីកកសិកម្ម ។ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឱ្យ ក្រសួងហិរញ្ញវត្ថុ ធ្វើការលើកទឹកចិត្តធនាគារពាណិជ្ជ ក្នុងការប្រើកំចីដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ តបនឹងសំណើរបស់រដ្ឋាភិបាល ធនាគារអេស៊ីលីដា បានបញ្ជាក់ថា នឹងបង្កើនកំចីចំពោះវិស័យកសិកម្មដល់ទៅ ១១៤លានដុល្លារ នៅឆ្នាំ២០០៩ ធៀបនឹង ៥៦,៥លានដុល្លារ នៅឆ្នាំ២០០៨ ។ |
| **ការពង្រីក ការស្រាវជ្រាវ និងអភិវឌ្ឍន៍** | របាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០០៩ បានឱ្យដឹងថា តាមបទពិសោធន៍កន្លងមក វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម និងលើផ្លូវជនបទ មានអត្រាផ្ដល់ផលត្រឡប់ខ្ពស់បំផុត សំរាប់ការកាត់បន្ថយភាពក្រីក្រ ។ នៅប្រទេសចិន ការបង្កើនចំណាយ ១% ទៅលើការស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម នឹងបង្កើន ផសស វិស័យកសិកម្មបាន ០.០៨៥% ក្នុងមនុស្សម្នាក់ៗ ។ កំណើន ផសស វិស័យកសិកម្ម នេះ នឹងកាត់បន្ថយចំនួនជនក្រីក្របាន ០.១% ។ |
| **ការបង្កើន ផលិតភាព និងប្រសិទ្ធភាព នៃការប្រើប្រាស់ធាតុចូល** | របាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ២០០៩ បានបង្ហាញថា ដីខ្វះជីជាតិ គឺជាឧបសគ្គចំបងដល់ផលិតកម្មនៅតំបន់វាលទំនាបភាគច្រើន ហើយបញ្ហានេះអាចដោះស្រាយបានដោយការប្រើបច្ចេកវិទ្យាគ្រប់គ្រងជី និងជីដ៏សមស្រប ។ ការប្រើប្រាស់ជីកសិកម្មនៅកម្ពុជា មានកំរិតទាប និងមិនសូវមានប្រសិទ្ធភាពទេ បើធៀបនឹងប្រទេសជិតខាង ។ ការប្រើប្រាស់ជីកសិកម្ម អាចបង្កើនទិន្នផលស្រូវបានយ៉ាងច្រើនទៀត ។ កំណើនការប្រើប្រាស់ជីកសិកម្ម ១% អាចបង្កើនទិន្នផលស្រូវប្រាំងបាន ០,២២% និងស្រូវវស្សា ០,២៧% ។ |
| **គ្រឿងលើកទឹកចិត្តទីផ្សារ** | កម្ពុជា ជាប្រទេសផលិត និងនាំចេញស្រូវដ៏សំខាន់មួយនៅក្នុងតំបន់ ហើយអ្នកនាំចូលស្រូវចំបងៗគឺមាន ប្រទេសនៅតំបន់មជ្ឈឹមបូព៌ា និង ប្រទេសនៅអាហ្វ្រិកមួយចំនួនក្នុងតំបន់ខាងត្បូងវាលខ្សាច់សាហារ៉ា ។ កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីរវាងអ្នកនាំចេញ និងអ្នកនាំចូល អាចជាមធ្យោបាយជឿនលឿនមួយសំរាប់កាត់បន្ថយភាពមិនប្រាកដប្រជា ក្នុងពាណិជ្ជកម្មអន្តរជាតិនៃស្រូវអង្ករ ។ កម្ពុជា ក៏គួរផ្ដោតផងដែរ លើការធ្វើចំរុះកម្មច្រកទីផ្សារចូលទៅតំបន់អាស៊ីបូព៌ា ដែលជាទីផ្សារដ៏ធំសំរាប់ដំណាំឧស្សាហកម្ម ដូចជា កៅស៊ូ ដំឡូងឈើ និង ពោត ជាដើម ។ ម្យ៉ាងទៀត ផលិតផលកសិកម្មភាគច្រើន បាននាំចេញពីកម្ពុជាក្នុងលក្ខណៈជាទំនិញគ្មានកែច្នៃ ។ ដូច្នេះ ដើម្បីបន្ថែមតំលៃលើទំនិញកសិកម្ម រដ្ឋាភិបាលគួរតំរង់ទិស វិនិយោគទៅខាងបច្ចេកវិទ្យាក្រោយការប្រមូលផល ដូចជា ប្រព័ន្ធសំរាប់កិន កែច្នៃ និង ស្តុកទុក ជាដើម ។ |
| **ការកែលំអបរិយាកាស វិនិយោគ និងពាណិជ្ជកម្ម** | ដើម្បីកែលំអបរិយាកាសពាណិជ្ជកម្ម និងអាជីវកម្ម វិនិយោគិនទាំងអស់ក្នុងកសិអាជីវកម្ម គួររួមគ្នាជាក្រុម និងធ្វើការជាមួយរដ្ឋាភិបាល ជាពិសេស ក្រសួងពាណិជ្ជកម្ម ។ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា គឺជាគំរូដ៏ល្អមួយ ។ វិមជ្ឈការ និង ការផ្ដល់អំណាចដល់អាជ្ញាធរមូលដ្ឋាន និងតំបន់ គឺគួរធ្វើឡើង ដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងតំបន់ ។ ការអនុម័ត និងអនុវត្តច្បាប់រៀបចំអង្គការ អាចជាជំហានមួយដ៏សំខាន់សំដៅកាត់បន្ថយបន្ទុកចំណាយខាងរដ្ឋបាល និងការិយាល័យធិបតេយ្យ ដែលប្រជាជនកំពុងប្រឈមមុខ ជាពិសេសអ្នកនៅជនបទ ។ |

** ប្រភព: របាយការណ៍របស់ ធនាគារពិភពលោក (២០០៩) ស្ដីពី ការរក្សាកំណើនលឿន នៅក្នុងបរិយាកាសប្រឈម (ឯកសារជំនួញស្មារតីស្ដីពីសេដ្ឋកិច្ចប្រទេសកម្ពុជា)*

# ការកសាងប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគតការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ: ទេសចរណ៍

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ ឯកឧត្តម ទិត ចន្ថា, លោក Jean-Daniel Gardère និង លោក ហូ វណ្ណី[1] នៅក្នុងវគ្គទី៣ក (២) នៃសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## វិស័យទេសចរណ៍នៅកម្ពុជា: កំណើន និងការរួមចំណែកក្នុងសេដ្ឋកិច្ច

ទេសចរណ៍ គឺជាវិស័យគន្លឹះសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។ ចំពោះកម្ពុជា វិស័យនេះ គឺជាស្ដាបចក្រមួយក្នុងចំណោមស្ដាបចក្រទាំងបួននៃកំណើន ។ តាមការសិក្សាមួយរបស់ធនាគារពិភពលោក វិស័យទេសចរណ៍រួមចំណែក ០,៥%នៃកំណើន ផសស ក្នុងអំឡុងឆ្នាំ១៩៩៨-២០០៧ ។ នៅឆ្នាំ២០០៧ វាមានចំណែក ៤% ក្នុង ផសស ។ ទេសចរណ៍ ក៏ជាវិស័យបង្កើតចំណូលដ៏ចំបងមួយសំរាប់សេដ្ឋកិច្ចជាតិដែរ ហើយវាដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់ការងារ ការបង្កើតប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រ ។ វិស័យនេះ ជួយលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំង ពង្រឹងការអភិរក្សវប្បធម៌ និងធនធានធម្មជាតិ ។

ការរីកលូតលាស់យ៉ាងលឿននៃវិស័យទេសចរណ៍នៅកម្ពុជា អាចបានមកពីកត្តាជាច្រើន ក្នុងនេះកត្តាដ៏សំខាន់មួយ គឺ ឧត្តមភាពប្រកួតប្រជែងមានស្រាប់ ពោលគឺ ប្រាសាទអង្គរវត្ត ។ ក្រៅពីសម្បត្តិដ៏វិសេសនេះ កម្ពុជានៅមានកេរ្តិ៍ដំណែលវប្បធម៌ និងសម្បត្តិធម្មជាតិជាច្រើន មានទីតាំងដ៏ល្អនៅក្នុងតំបន់ ព្រមទាំង គោលនយោបាយបើកចំហជើងមេឃ ដែលបានជួយសម្រួល និងពង្រឹងដល់កំណើនទេសចរណ៍នេះ ។ ការកសាងបានសន្តិភាព និងស្ថិរភាព គឺជាមូលហេតុមួយទៀត នៃកំណើនលំហូរចូលភ្ញៀវទេសចរ ។

វិស័យទេសចរណ៍មានចំណុចខ្សោយពីកំណើតមួយ ភាពងាយរងគ្រោះខ្លាំងដោយសារការវិវត្តមិនអំណោយផលខាង បរិស្ថាន សង្គមកិច្ច-វប្បធម៌ សេដ្ឋកិច្ច ឬ នយោបាយ ។ ចំណុចនេះមានន័យថា គេត្រូវគ្រប់គ្រងលើវិស័យទេសចរណ៍ដោយប្រុងប្រយ័ត្ន និងមានចីរភាព កុំឱ្យវាបំផ្លាញខ្លួនវាបាន ។

## ផលប៉ះពាល់នៃវិបត្តិលើទេសចរណ៍ក្នុងស្រុក និងសាកលលោក

ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បង្ហាញពីភាពងាយរងគ្រោះជៀសមិនរួចនៃវិស័យទេសចរណ៍ ចំពោះការវិវត្តនៅខាងក្រៅ ។ នៅឆ្នាំ២០០៨ វិស័យទេសចរណ៍ពិភពលោក ស្ទើរតែគ្មានលូតលាស់សោះ ដោយកើនឡើងតាមអត្រាប៉ាន់ស្មានត្រឹម ២% ប៉ុណ្ណោះ សំរាប់ភ្ញៀវទេសចរសរុប ៩២៤លាននាក់ ។ វិស័យទេសចរណ៍នៅសហភាពអឺរ៉ុប កើនតែ ០,១% ប៉ុណ្ណោះ ដោយមានភ្ញៀវទេសចរមកដល់ ៤៨៨លាននាក់ រីឯ នៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក វាកើន ១,៦% ដោយមានទេសចរមកដល់ប្រហែល ១៨៨លាននាក់ ។ឥទ្ធិពលនៃវិបត្តិនេះ ក៏ធ្លាក់មកលើកម្ពុជាដែរ ។ នៅឆ្នាំ២០០៨ ភ្ញៀវទេសចរមកដល់កម្ពុជា កើន ៥,៥% ( ក្រាហ្វិក ១) ដែលមានភាពអាប់អួរជាងមុន បើធៀបនឹងកំណើនប្រចាំឆ្នាំជាមធ្យម ២៥% ក្នុងពេលកន្លងមក ។ នៅខែមីនា ២០០៨ កំណើនភ្ញៀវទេសចរ បានចាប់ផ្ដើមធ្លាក់ចុះគួរឱ្យកត់សំគាល់ ហើយសមាសភាព និងរបៀបមកដល់នៃភ្ញៀវទេសចរ ក៏ផ្លាស់ប្ដូរខ្លះដែរ ។ ចំនួនភ្ញៀវទេសចរជនជាតិកូរ៉េ ធ្លាក់ចុះអស់ ១៩% ដោយសារសេដ្ឋកិច្ចប្រទេសកូរ៉េកាន់តែរួមចុះខ្លាំងឡើង ។ ការធ្លាក់ចុះទេសចរកូរ៉េនេះ ត្រូវបានប៉ះប៉ូវវិញដោយកំណើនភ្ញៀវទេសចរមកពីសហភាពអឺរ៉ុប និងតំបន់អាស៊ាន ។ កាលពីឆ្នាំមុន ភ្ញៀវទេសចរមកដល់តាមផ្លូវអាកាស ថយចុះ ៤,៤% ហើយអាកាសយានដ្ឋានសៀមរាបមានការធ្លាក់ចុះអ្នកដំណើរអស់ ១២% ។ ការធ្លាក់ចុះចំនួនមកដល់តាមផ្លូវអាកាស ត្រូវបានប៉ះប៉ូវវិញ ដោយកំណើនភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក ។

ផ្អែកលើទិន្នន័យជាដំបូងៗ ភ្ញៀវទេសចរមកដល់ បន្តថយចុះអស់ ២% ទៀតនៅខែមករា ២០០៩ ។ ជារួម គេបានទស្សទាយថា វិស័យទេសចរណ៍នឹងជួបការលំបាកតឹងតែងក្នុងឆ្នាំ២០០៩ នេះ ហើយតាមការព្យាករណ៍មួយ ចំនួនភ្ញៀវទេសចរមកដល់កម្ពុជា នឹងធ្លាក់ចុះអស់ ៣% ដោយមានការបាត់បង់ទេសចរអស់ប្រហែល ៦៣.០០០នាក់ ប្រាក់ចំណូល ៥៣លានដុល្លារ និង ១០.០០០ការងារដែលទាក់ទងផ្ទាល់នឹងទេសចរណ៍ ។ ការប៉ាន់ស្មានមួយទៀត បានអះអាងថា សកម្មភាពទេសចរណ៍នៅរដូវមមាញឹក នឹងធ្លាក់ចុះអស់ ១៥% ក្នុងឆ្នាំ២០០៨-២០០៩ ។ ទីភ្នាក់ងារទេសចរណ៍ និងម្ចាស់សណ្ឋាគារជាច្រើន បានសម្ដែងការព្រួយបារម្ភរួចហើយពីការថយចុះយ៉ាងច្រើននៃភ្ញៀវទេសចរដែលទាក់ទងសាកសួរព័ត៌មាន និងកក់កន្លែងទុក នៅឆ្នាំនេះ ។ទោះយ៉ាងនេះក្ដី ដៃគូសហការណ៍មួយចំនួន នៅតែមានគំនិតសុទិដ្ឋិនិយមដដែល ហើយរដ្ឋាភិបាលបានព្យាករណ៍ថា វិស័យទេសចរណ៍នឹងបន្តរីកលូតលាស់នៅឆ្នាំនេះ ។ ក្រុមអ្នកវិភាគពីទេសចរណ៍មួយចំនួន បានយល់ស្របថានឹងមានការធ្លាក់ចុះ ប៉ុន្តែក្នុងកំរិតមិនគួរបារម្ភពេកទេ ។ បញ្ហាប្រឈមនៅឆ្នាំនេះមានធំៗណាស់ ប៉ុន្តែមិនមែនពុះពារមិនបាននោះទេ ។ ពិតហើយ ឱកាសល្អនៅមានច្រើនដែលអាចកែប្រែស្ថានភាពអាប់អួរឱ្យប្រសើរឡើងវិញ ដូចជា ជនជាតិអាមេរិក ជប៉ុន និងអឺរ៉ុប ប្រហែលកើនទឹកចិត្តធ្វើដំណើរកំសាន្ត ពីព្រោះប្រាក់ដុល្លារ ប្រាក់យេន និងប្រាក់អឺរ៉ូ បានឡើងថ្លៃ ។ ការធ្វើដំណើរចេញពីប្រទេសចិន និងឥណ្ឌា ក៏រំពឹងថាបន្តកើនឡើងដែរ ដោយសារសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ នៅតែមានកំណើន ។ គេរំពឹងទុកថា ការធ្វើដំណើរកំសាន្តក្នុងស្រុក និងក្រៅស្រុកក្នុងរយៈពេលខ្លី នឹងកើនឡើង ដោយហេតុថាមានប្រជាជនជាច្រើនចង់ធ្វើដំណើរទៅតំបន់មិនឆ្ងាយពីផ្ទះ ដូច្នេះដំណើរក្នុងស្រុក ឬទៅអន្តរជាតិក្នុង រយៈពេលខ្លី រំពឹងថានឹងកើនឡើង ។ ដោយមូលហេតុនេះ វិបត្តិទំនងមិនប៉ះពាល់ស្មើៗគ្នាទៅគ្រប់កន្លែងនោះទេ ។ វាជះឥទ្ធិពលខ្លាំងជាងគេទៅលើកញ្ចប់ទស្សនកិច្ចប្រណិត រីឯខ្សែទស្សនកិច្ចដែលផ្ដល់សេវាមិនសូវថ្លៃវិញ គេរំពឹងថាអាចទ្រាំទ្រនឹងវិបត្តិបានប្រសើរជាងច្រើន ។

## ការធ្លាក់ចុះនៃវិស័យទេសចរណ៍ក្នុងស្រុក: កត្តាផ្សេងៗ

វិបត្តិសាកល ដែលបានកាត់បន្ថយទ្រព្យធន ប្រាក់ចំណូល និងទំនុកចិត្ត គឺជាកត្តាចំបងនៃការធ្លាក់ចុះវិស័យទេសចរណ៍កម្ពុជា ។ នៅមានកត្តាផ្សេងៗជាច្រើនទៀតដែលបានរួមចំណែកក្នុងការធ្លាក់ចុះនេះដែរ ដូចជា ជំលោះ

[1] ឯកឧត្តម ទិត ចន្ថា ជាអគ្គនាយកទេសចរណ៍នៃក្រសួងទេសចរណ៍, លោក Jean-Daniel Gardère ជាទីប្រឹក្សាជាន់ខ្ពស់ ហើយ លោក ហូ វណ្ណី ជាសហប្រធានក្រុមការងារវិស័យឯកជន ស្ដីពីវិស័យទេសចរណ៍ និងជានាយកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ World Express Tours and Travel Co.Ltd.

ក្រាហ្វិក ២: ភ្ញៀវទេសចរមកដល់កម្ពុជា ១៩៩៣-២០០៨




ព្រំដែន កម្ពុជា-ថៃ ដែលបានជះឥទ្ធិពលដល់ពាណិជ្ជកម្មឆ្លងដែនរវាងប្រទេសទាំងពីរ ។ កត្តាមួយទៀត គឺជំលោះផ្ទៃក្នុងនយោបាយប្រទេសថៃ ដែលបណ្តាលឱ្យអាកាសយានដ្ឋានធំមួយនៅថៃត្រូវបិទទ្វារមិនដំណើរការ កាលពីឆ្នាំកន្លងទៅ ។ ដោយសារថៃ ជាច្រកចូលដ៏សំខាន់មួយសំរាប់ទេសចរមកកាន់ប្រទេសកម្ពុជា ដូច្នេះជំលោះនយោបាយនៅថៃមានផលប៉ះពាល់អវិជ្ជមានមកលើទេសចរណ៍កម្ពុជា ។

សំខាន់ជាងនេះទៀត មានការវិភាគស៊ីជម្រៅមួយបង្ហាញថា ការរីកលូតលាស់យ៉ាងលឿននៃទេសចរណ៍ក្នុងពេលកន្លងមក ពិតជាមិនអាចមានចីរភាពទេ ។ ទោះជាមាន ឬមិនមានវិបត្តិក្តី ការរលំរលាយនៃកំណើនទេសចរណ៍ ត្រូវតែកើតមានឡើងក្នុងរយៈពេល២-៣ឆ្នាំបន្ទាប់មក ។ ប្រាសាទអង្គរវត្ត ពិតជាបានរួមចំណែកមួយផ្នែក នៅក្នុងកង្វះចីរភាពទេសចរណ៍នេះ ។ អង្គរវត្តអាចជាចំនុចខ្លាំងជាងគេនៃទេសចរណ៍កម្ពុជា ប៉ុន្តែក៏បានក្លាយជាប្រភពចំបងមួយនៃភាពទន់ខ្សោយរបស់ទេសចរណ៍ដែរ ពីព្រោះមកទល់ពេលនេះ ប្រាសាទអង្គរវត្តបានទាក់ទាញ ស្ទើរតែផ្តាច់មុខនូវចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរ ដូច្នេះហើយក៏បានប៉ះពាល់ដល់កន្លែងទេសចរណ៍ឯទៀត ។ មូលហេតុមួយផ្សេងទៀតនៃកង្វះចីរភាពទេសចរណ៍ គឺ ការប្រឹងជំរុញតែទេសចរណ៍ទ្រង់ទ្រាយធំ ជាជាងខំបង្កើនតំលៃបន្ថែមនៃសេវាកម្ម និងផលិតផលក្នុងវិស័យនេះ ។

## ចក្ខុវិស័យ និងគោលនយោបាយគួរអនុវត្តផ្សេងៗ

គេទស្សទាយថា វិស័យទេសចរណ៍នឹងរើបឡើងវិញនៅឆ្នាំ២០១០ ទោះបីមានឧបសគ្គជាច្រើនក៏ដោយ ។ គេត្រូវអនុវត្តតាមជំហានមួយចំនួនដើម្បីជួយទ្រទ្រង់ដល់ការរើបឡើងវិញនេះ និងមានជំហានជាច្រើនទៀតដើម្បីដោះស្រាយបញ្ហាចីរភាព ។ រដ្ឋាភិបាល និងដៃគូនានាខាងទេសចរណ៍ មានជំរើសគោលនយោបាយមួយចំនួន សំរាប់ដោះស្រាយបញ្ហាចីរភាពនេះ (ក្រាហ្វិក ២) ដែលឈរលើគោលគំនិតពីរជាសំខាន់ ។ ទីមួយ ត្រូវចងចាំថា ទ្រព្យសម្បត្តិដ៏ល្អឯកដូចជាអង្គរវត្តជាដើម ងាយទទួលរងការខូចខាតណាស់ ដូច្នេះត្រូវគ្រប់គ្រងទ្រព្យទាំងនេះ ដោយយកចិត្តទុកដាក់បំផុតតាមរយៈការលើកកំពស់គុណភាព និងភាពខុសប្លែកពីគេ ដើម្បីរក្សាកំលាំងប្រកួតប្រជែងរបស់ប្រាសាទឱ្យបានគង់វង្សយូរអង្វែង ។ ទីពីរ ត្រូវកត់សំគាល់ជាសំខាន់ថា ភ្ញៀវទេសចរច្រើនពេក ធ្វើឱ្យវិស័យទេសចរណ៍ស្លាប់ នៅស្ពឹកទ្រឹង ឬធ្លាក់ចុះវិញ ជាពិសេសនៅតាមកន្លែងដែលមិនសមស្របសំរាប់ទទួលមនុស្សច្រើនៗ ឬទទួលសកម្មភាពលំហែកំសាន្តបែបស្តង់ដារ និងទ្រង់ទ្រាយធំ ។ ទេសចរណ៍ទ្រង់ទ្រាយធំ មិនមែនចេះតែធ្វើបានគ្រប់ពេលវេលានោះទេ ហើយការជំរុញសកម្មភាពនេះឱ្យខាងតែបាន អាចធ្វើឱ្យខូចខាត ជាជាងផ្តល់ផលចំណេញដល់វិស័យទេសចរណ៍ ។ ការកាត់បន្ថយកំរៃទេសចរណ៍ និងចំណាយផ្សេងៗដើម្បីទាក់ទាញ ភ្ញៀវទេសចរ ក៏គួរគិតគូរឡើងវិញដែរ ព្រោះមានការវាយតំលៃថា យុទ្ធសាស្ត្រនេះប្រហែលមិនផ្តល់ ផលចំណេញអ្វីជាដុំកំភួនទេ ដោយសារហេតុផលជាច្រើន ។ ទីមួយ កំរៃ ពន្ធ និងចំណាយផ្សេងៗនៅក្នុងទេសចរណ៍កម្ពុជា មានកំរិតមិនខ្ពស់ទេ បើធៀបនឹងស្តង់ដារអន្តរជាតិ ។ លើសពីនេះទៀត ភ្ញៀវទេសចរមកពីបស្ចឹមប្រទេស និងតំបន់អាស៊ី ដែលស្ថិតក្នុងទីផ្សារទេសចរណ៍ថ្នាក់កណ្តាល និងថ្នាក់ខ្ពស់ និងដែលកម្ពុជាកំពុងចង់បានខ្លាំង ពួកគេពេញចិត្តបង់ថ្លៃខ្ពស់ថែមទៀត ឱ្យតែបានសេវាកម្មទេសចរណ៍មានគុណភាពល្អ ។ សុវត្ថិភាព ភាពស្អាតល្អមានអនាម័យ និងការចាត់ចែងទិដ្ឋាការបានលឿន គឺជាកត្តាមួយចំនួនទៀត ដែលទាក់ទាញភ្ញៀវទេសចរឱ្យចូលមកជាច្រើនដង ។ ដូច្នេះគេត្រូវតែប្រយ័ត្នប្រយែងចំពោះការអំពាវនាវឱ្យកាត់បន្ថយកំរៃទេសចរណ៍នេះ ពីព្រោះវាអាចនាំឱ្យមានការថយចុះថវិកាសំរាប់ចំណាយលើការថែទាំ និងការអនុវត្តគំនិតថ្មីៗ ហើយរឿងនេះអាចប៉ះពាល់ដល់គុណភាពនៃសម្បត្តិទេសចរណ៍ ។

ដូចអាចមើលឃើញក្នុងក្រាហ្វិក២ យុទ្ធសាស្ត្រគួរអនុវត្តមួយ គឺ ការជំរុញអេកូទេសចរណ៍ ប៉ុន្តែដើម្បីឱ្យវាមានប្រសិទ្ធភាពនៅកម្ពុជា គេមិនត្រូវមានមហិច្ឆតាខ្ពស់ពេកទេ ។ គោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់អេកូទេសចរណ៍ ទាមទារជាចាំបាច់នូវធនធានច្រើនណាស់ ដែលកម្ពុជាមិនមានទេ ព្រមទាំង រុក្ខជាតិ និងសត្វដ៏សំបូរដែលកម្ពុជាបានបាត់បង់អស់មួយភាគធំ ហើយក្នុងអំឡុងពេលមានសង្គ្រាម ។ ដើម្បីធ្វើការទាក់ទាញ ខាងអេកូឡូស៊ី រដ្ឋាភិបាលគួរផ្តួចផ្តើមគោលនយោបាយមួយផ្តោតលើបុគ្គល និងក្រុមតូចៗ ។ ការអភិវឌ្ឍបន្ថែមនូវត្រីកោណ ក្រុងព្រះសីហនុ-ក្រុងភ្នំពេញ-ក្រុងសៀមរាប គឺជាវិធានការមួយទៀតដែលមានបង្ហាញក្នុង ក្រាហ្វិក២ ដែរ ។ ក្រុងព្រះសីហនុ ទាមទារការយកចិត្តទុកដាក់ច្រើនជាងគេ ពីព្រោះបានលូតលាស់យឺតជាងគោលដៅទេសចរណ៍ពីរទៀត ។ ដំណឹងល្អមួយគឺ ឥឡូវនេះអាកាសយានដ្ឋានក្រុងព្រះសីហនុដំណើរការបានហើយ ប៉ុន្តែដំណឹងមិនល្អ គឺ បញ្ហាផ្សេងៗដូចជា ការលុបចោលជើងហោះហើរតភ្ជាប់ ជាដើម គេមិនទាន់បានដោះស្រាយនៅឡើយទេ ។ ការអភិវឌ្ឍក្រុងព្រះសីហនុ ពិតជានឹងផ្តល់ផលចំណេញយ៉ាងច្រើន ។ គេប៉ាន់ស្មានថា ការផ្តល់ការស្នាក់នៅក្នុងតំបន់ក្រុងព្រះសីហនុនេះ អាចនាំឱ្យភ្ញៀវទេសចរបង្កើនរយៈពេលស្នាក់នៅប្រទេសកម្ពុជា បានពី ២ ទៅ ៤ ថ្ងៃ ។ តាមនេះយើងអាចសំរេចបាននូវ កំណើនតំលៃ និងសកម្មភាពទេសចរណ៍ ពី ១៥% ទៅ ២៥% ក្នុង ៥ឆ្នាំ ខាងមុខ ទោះបីជាចំនួនភ្ញៀវទេសចរមកដល់កម្ពុជា មិនកើនឡើងក្តី ។

ប្រាសាទអង្គរវត្តល្អត្រចះខ្លាំងណាស់ សមជាកម្មវត្ថុនៃមោទនភាពរបស់ប្រជាជនកម្ពុជាមែន ។ ប៉ុន្តែ អង្គរវត្តដ៏ល្អត្រចះ ក៏ដូចជា ទេសចរណ៍កម្ពុជាទាំងមូល អាចមានចីរភាពទៅបាន លុះត្រាតែគេកាត់បន្ថយភាពពឹងពាក់ទៅលើប្រាសាទនេះ និងបង្កើនភាពប្លែកពីគេរបស់អង្គរវត្ត ។ ជាការពិតណាស់ កម្ពុជា គឺជា រាជាណាចក្រអច្ឆរិយ សំបូរទៅដោយសម្បត្តិ-ធនធានទាក់ទាញចិត្ត ដែលរង់ចាំតែការយកចិត្តទុកដាក់ និងទទួលស្គាល់តំលៃតែប៉ុណ្ណោះ ៕

## ក្រាហ្វិក ២: យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយបានលើកឡើង ដើម្បីធ្វើឱ្យវិស័យទេសចរណ៍មានចីរភាព

**ការធ្វើឱ្យកំណើនទេសចរណ៍មានចីរភាព**

**គោលការណ៍ចំនួនពីរ**

- សញ្ញាសំគាល់ និងភាពវិសេសតែមួយក្នុងពិភពលោក ងាយខូចខាតណាស់
- បើអនុវត្តមិនសមស្របទេ ទេសចរណ៍ទ្រង់ទ្រាយធំ អាចធ្វើឱ្យខូចខាតដល់វិស័យទេសចរណ៍

| យុទ្ធសាស្ត្រទូទៅ | យុទ្ធសាស្ត្រជាក់លាក់ | |
|---|---|---|
| ការគ្រប់គ្រងប្រាសាទអង្គរវត្ត និងតំបន់ជុំវិញប្រកបដោយចីរភាព | ធ្វើចំរុះកម្មសកម្មភាពទេសចរណ៍ - ផ្តល់មូលនិធិអភិវឌ្ឍន៍ពិសេសមួយសំរាប់គោលបំណងនេះ | កែលំអផែនការរៀបចំទីក្រុង ភាពស្អាត និងការគ្រប់គ្រងទឹក |
| | ធ្វើឱ្យទស្សនកិច្ចដំណើរការ បានល្អបំផុត - កែលំអសេវាកម្មនៅសួនកំសាន្ត - ពង្រីកបញ្ជីជំរើស តាមគោលការណ៍ខាងលើ | ដំណើរទេសចរណ៍តាមការបញ្ជាទិញ - បើកដល់យប់ជ្រៅ - ប្តូរចុះឡើងនូវផ្លូវធ្វើដំណើរកំសាន្ត - សំបុត្រចូលទស្សនា រយៈពេល កន្លះថ្ងៃ - សំបុត្រចូលទស្សនា រយៈពេល ៧-១៤ ថ្ងៃ |
| | ដោះស្រាយបញ្ហាទំនើបភាវូបនីយកម្ម - អនុវត្តប្រើប្រព័ន្ធអតិពលកម្ម និងបរិក្ខារមានលក្ខណៈងាយស្រួល សំរាប់ អ្នកប្រើប្រាស់ (ឧ. ការដឹកជញ្ជូន ការដាក់ភ្លើងបំភ្លឺ ការបំរើម្ហូបអាហារ និងភេសជ្ជៈនៅកន្លែងទេសចរណ៍មគ្គុទេសក៍ស្វ័យប្រវត្តិ) | |
| ធ្វើពិពិធកម្មទីផ្សារ និងផលិតផល | ទេសចរណ៍ធំជាងមុន : តំបន់អាស៊ាន អាស៊ាន + ៣ និង ឥណ្ឌា រុស្ស៊ី តំបន់មជ្ឈឹមបូពា និងអឺរ៉ុប | ធ្វើការបញ្ចុះបញ្ចូលដល់ប្រជាជនកម្ពុជាដែលរស់នៅក្នុងស្រុក និងនៅឯបរទេស ឱ្យធ្វើដំណើរកំសាន្តក្នុងប្រទេសកម្ពុជាញឹកញាប់ជាងមុន |
| សម្រួលដល់ការធ្វើដំណើរ | ជំរុញល្បឿនការផ្តល់ ទិដ្ឋាការចេញ-ចូលបានច្រើនដង | បើកដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរជាតិ |
| | ភាពបត់បែនបានលើរយៈពេលអនុញ្ញាតអោយស្នាក់នៅ | បើកដំណើរការនូវកន្លែងត្រួតពិនិត្យតាមព្រំដែនបន្ថែមទៀត |
| | ចរចារពីកិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែនបន្ថែមទៀត | ពង្រឹងទំនាក់ទំនងផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក ក្នុងតំបន់ |
| បង្កើនកំលាំងប្រកួតប្រជែងដោយលើកស្ទួយរូបភាព ភាពទាក់ទាញ ភាពវិសេសខុសគេ និងច្រកចូលទៅដល់ | ពង្រឹងការអនុវត្តផែនការ រៀបចំទីក្រុង និងស្តង់ដារសាងសង់ | ភាពបត់បែនបានជាងមុន នូវសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយជនបរទេស |
| | អនុវត្តការបែងចែកតំបន់ និងបទបញ្ញត្តិការពារតំបន់ទេសចរណ៍ និងសញ្ញាសំគាល់ | បង្កើតមូលនិធិសំរាប់ការសាងសង់ និងការពារផ្លូវថ្នល់ និងផ្លូវលំ ដែលអាចប្រើសំរាប់ដំណើរកំសាន្តខ្លីៗ ដំណើរតាមផ្លូវជើង និងតំបន់អេកូទេសចរណ៍ខ្នាតតូច |
| ជំរុញអេកូទេសចរណ៍ | ទីផ្សារគោលដៅ គួរមានទំហំតូច (បុគ្គល និងក្រុមតូចៗ) | អភិវឌ្ឍព័ត៌មានចាំបាច់ (ឧ. ផែនទីប្រាប់ផ្លូវថ្មីៗ) និង សម្ភារៈជួយសម្រួលផ្សេងៗ |
| | ជំរុញអេកូទេសចរណ៍នៅតំបន់ភ្នំក្រវាញ-កោះកុង និងតំបន់ទេសចរណ៍ល្អៗនៅកោះក្បែរៗនោះ | |
| ជំរុញ និងអភិវឌ្ឍបន្ថែមនូវតំបន់ត្រីកោណទេសចរណ៍ សៀមរាប-ភ្នំពេញ-ក្រុងព្រះសីហនុ | បង្កើន និងកែលំអគុណភាពកន្លែងស្នាក់នៅ ជាពិសេសនៅក្រុងព្រះសីហនុ | កែលំអសេវាអាកាសចរ និង ដោះស្រាយបញ្ហា ដូចជា ការលុបចោលជើងហោះហើរតភ្ជាប់ ជាដើម |
| កែលំអ និងបង្កើនការធ្វើម៉ាឃីធីង | អនុម័តប្រើចំណងជើងពិរោះ ទាក់ទាញចិត្តសំរាប់យុទ្ធនាការ ឃោសនា (ឧ. កម្ពុជា-រាជាណាចក្រអច្ឆរិយ) | ធ្វើការផ្សព្វផ្សាយនៅក្នុងបណ្តាញព័ត៌មាន CNN, National Geographic និងប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសជាគោលដៅ |
| កសាងក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា (សូមមើលសេចក្តីសង្ខេបនៃអត្ថបទរបស់ លោក ហូ វណ្ណី ស្តីពីមុខងារដែលបានលើកឡើង) | | |

# ការគ្រប់គ្រងវិបត្តិសាកល — ទេសចរណ៍នៅប្រទេសកម្ពុជា និងក្នុងតំបន់

*អត្ថបទនេះ សង្ខេបពីបទបង្ហាញរបស់ លោក ហូ វណ្ណី[១] នៅក្នុងសន្និសីទស្ដីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

កម្ពុជា ជាប្រទេសគោលដៅទស្សនកិច្ចបេតិកភ័ណ្ឌវប្បធម៌ដ៏សំខាន់មួយ ។ នៅមុនពេលមានវិបត្តិ កម្ពុជាមានការរីកលូតលាស់ខាងទេសចរណ៍គួរឱ្យភ្ញាក់ផ្អើល ដោយសារសម្បត្តិវប្បធម៌ជាកេរ្ដិ៍តំណែលនៃប្រវត្តិសាស្ត្រដ៏រុងរឿងរបស់ប្រទេសនេះ ក៏ដូចជា សម្បត្តិធម្មជាតិដ៏សំបូរ ព្រមទាំងទីតាំងជាយុទ្ធសាស្ត្រនៅក្នុងតំបន់មួយដែលកំពុងមានសន្ទុះ ។ការរីកលូតលាស់នេះ ផ្អែកលើស្ថិរភាពដែលកម្ពុជាទទួលបានបន្ទាប់ពីមានសង្គ្រាមរ៉ាំរ៉ៃអស់ជាច្រើនទសវត្សរ៍ គួបផ្សំនឹងគោលនយោបាយរបស់រដ្ឋាភិបាល ដូចជា គោលនយោបាយបើកចំហជើងមេឃជាដើម ។ ភ្ញៀវទេសចរមកដល់កម្ពុជា បានកើនឡើងពី ២១៩.០០០នាក់ នៅឆ្នាំ១៩៩៧ រហូតដល់ជាង ២,១លាននាក់ នៅឆ្នាំ២០០៨ ដោយមានរយៈពេលស្នាក់នៅជាមធ្យម ៦,៥ថ្ងៃ និងផ្ដល់ប្រាក់ចំណូលប្រហែល ១៥៩៥លានដុល្លារ ។

## ផលប៉ះពាល់នៃវិបត្តិនៅលើទេសចរណ៍ក្នុងស្រុក និងលើពិភពលោក

ការធ្លាក់ចុះសេដ្ឋកិច្ចជាសាកល ធ្វើឱ្យសកម្មភាពទេសចរណ៍នៅកម្ពុជា និងតំបន់ ឯទៀតក្នុងពិភពលោក ថយចុះ ។វិស័យទេសចរណ៍ ងាយរងគ្រោះបំផុតនៅចំពោះមុខភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច ដោយសារហេតុផល ដ៏សាមញ្ញមួយ គឺ នៅពេលសេដ្ឋកិច្ចតានតឹងយ៉ាប់យ៉ឺន មនុស្សទូទៅតែងរក្សាទុកប្រាក់កាសរបស់ពួកគេ សំរាប់ដោះស្រាយតំរូវការចាំបាច់ និងលាក់ទុកខ្លះទៀត "នៅក្រោមកន្ទេល" ។ទង្វើបែបនេះ មិនបានបញ្ឈប់ ការធ្វើដំណើរទាំងស្រុងទេ ពីព្រោះមនុស្សនៅតែត្រូវធ្វើដំណើរទៅធ្វើជំនួញ និងចូលរួមក្នុងព្រឹត្តិការណ៍សង្គមសំខាន់ៗ មួយចំនួន ។ ទោះយ៉ាងនេះក្ដី ចាប់តាំងពីឆមាសទី២ ឆ្នាំ២០០៨ មក វិបត្តិបានធ្វើឱ្យកំណើនទេសចរណ៍ពិភពលោក ធ្លាក់ចុះរហូតដល់កំរិតសូន្យតែម្ដង ។ កត្តាផ្សេងៗទៀតដែលរួមចំណែកបង្កការធ្លាក់ចុះរួមមាន ការឡើងថ្លៃខ្ពស់នៃប្រេងសាំង និងទំនិញប្រើប្រាស់ ការឡើងចុះយ៉ាងរហ័សនៃអត្រាប្ដូរប្រាក់ និងការថយចុះទំនុកចិត្តរបស់អតិថិជន និងអាជីវករ ។ យោងតាមទិន្នន័យរបស់ អង្គការទេសចរណ៍ពិភពលោក នៃសហប្រជាជាតិ (UNWTO) ចំនួនភ្ញៀវទេសចរអន្តរជាតិសរុប នៅឆ្នាំ២០០៨ មាន ៩២៤លាននាក់ ឬកើនបានតែ ២% ប៉ុណ្ណោះ ធៀបនឹងឆ្នាំមុន ។ កំណើនទេសចរណ៍នៅកម្ពុជា ក៏បានរួមចុះធ្ងន់ធ្ងរបែបនេះដែរ ។ ធៀបនឹងឆ្នាំ២០០៧ ចំនួនភ្ញៀវទេសចរនៅឆ្នាំ២០០៨ កើនបាន ៥,៥% គឺទាបជខ្លាំង ធៀបនឹងកំណើនលេខពីរខ្ទង់ដែលកម្ពុជាធ្លាប់ទទួលបានពីមុន ។ អត្រាស្នាក់នៅសណ្ឋាគារថ្នាក់ខ្ពស់នៅខេត្តសៀមរាប និងតំបន់ជុំវិញ បានធ្លាក់ចុះប្រហែល ២០-៤០% នៅចុងឆ្នាំ២០០៨ ។

## ចក្ខុវិស័យ ភាពនុវត្តភាព និងបញ្ហាប្រឈម

ចក្ខុវិស័យសំរាប់វិស័យទេសចរណ៍ ឆ្នាំ២០០៩ មានលក្ខណៈតឹងខ្លាំងណាស់ ប៉ុន្តែមិនដល់ថ្នាក់ដោះស្រាយមិនបាននោះទេ ។ អង្គការ UNWTO បានស្មានទុកថា ទេសចរណ៍ពិភពលោកនឹងបន្តនៅស្ពឹកទ្រឹង ដោយសារលក្ខខណ្ឌដែលបង្កការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោកនៅឆ្នាំ២០០៨ នឹងប្រែប្រួលកាន់តែអាក្រក់ឡើង ឬនៅតែគ្រប់គ្រងមិនទាន់បាន ។ គេគិតថា នៅឆ្នាំ២០០៩នេះ ចំនួនអ្នកដំណើរជាជនជាតិអាមេរិក នឹងធ្លាក់ចុះយ៉ាងច្រើន ហើយប្រជាជននៅចក្រភពអង់គ្លេស ប្រហែលនឹងជ្រើសយកដំណើរកំសាន្តក្នុងស្រុក ជាជាងដំណើរកំសាន្តជាលក្ខណៈអន្តរជាតិ ។ នៅឆ្នាំ២០០៨ ប្រជាជនប្រទេសអាល្លឺម៉ង់ប្រហែលជា ៣០% ចូលចិត្តធ្វើដំណើរកំសាន្តនៅក្នុងប្រទេសរបស់ពួកគេ ដោយសារភាពតានតឹងខាងថវិកា ហើយត្រឹមខែកុម្ភៈ ២០០៩ នៅមានប្រជាជន ៤០% ទៀតដែលមិនទាន់សំរេចចិត្តថា នឹងធ្វើដំណើរទៅជិតៗផ្ទះ ឬយ៉ាងណា ។ ម្យ៉ាងទៀត ដោយសារក្រុមហ៊ុនជាច្រើនក្នុងពិភពលោកកំពុងប្រឈមមុខនឹងស្ថានភាពតានតឹង ដូចនេះ ចំណាយរបស់ក្រុមហ៊ុនលើការធ្វើដំណើរ ក៏រំពឹងថានឹងថយចុះដែរ ដោយមានការប៉ាន់ស្មានមួយថា ការធ្វើដំណើរក្នុងការងារក្រុមហ៊ុន នឹងថយចុះដល់ទៅ ៨០% ។ យោងតាមសមាគមអ្នកដឹកនាំគោចររបស់ក្រុមហ៊ុន (Association of Corporate Travel Executives) ៧១% នៃក្រុមហ៊ុនដែលជាសមាជិករបស់ខ្លួន មានគំរោងថវិកាសំរាប់ការធ្វើដំណើរក្នុងឆ្នាំ២០០៩នេះ តិចជាងកាលពីឆ្នាំ២០០៧ ហើយអ្នកដែលធ្វើដំណើរក៏ត្រូវកាត់បន្ថយ ចំណាយផ្សេងៗដែរ ។ ដោយសារហេតុការណ៍ទាំងអស់នេះ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលនៅឆ្នាំ២០០៩ ក្រុមហ៊ុនបំរើសេវាធ្វើដំណើរ នឹងត្រូវប្រឈមនឹងស្ថានការណ៍កាន់តែលំបាកជាងឆ្នាំមុនទៀត ហើយមួយចំនួន អាចនឹងដួលរលំ ជាពិសេសក្រុមហ៊ុនដែលអនុវត្តអត្រាយកចំណេញកំរិតទាប ។ ម្យ៉ាងទៀត សុវត្ថិភាពការងាររបស់អ្នកបំរើការក្នុងផ្នែកនេះ ក៏ជួបគ្រោះថ្នាក់ដែរ ។ ដោយឡែក ក្រុមហ៊ុនបំរើសេវាធ្វើដំណើរធំៗមួយចំនួន បាននិងកំពុងកាត់បន្ថយបុគ្គលិករួចជាស្រេច ហើយយោងតាមស្ថានការណ៍កាន់តែលំបាកឡើង អាចមានការបញ្ឈប់បុគ្គលិកថែមទៀត ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

សំរាប់វិស័យទេសចរណ៍នៅកម្ពុជា មានការវាយតម្លៃទូទៅថា នឹងត្រូវធ្លាក់កំណើនថែមទៀត ប៉ុន្តែពុំមានការមូលមតិគ្នាអំពីទំហំនៃការធ្លាក់ចុះនេះទេ ។ ក្រសួងទេសចរណ៍បានព្យាករណ៍ថា វិស័យទេសចរណ៍ នឹងបន្តកើនឡើងនៅឆ្នាំនេះ ហើយនៅឆ្នាំ២០១០ ភ្ញៀវទេសចរមកកម្ពុជានឹងកើនដល់ ៣លាននាក់ ។ ការព្យាករណ៍សុទិដ្ឋិនិយមនេះ វាផ្ទុយគ្នានឹងការទស្សទាយគួរឱ្យបារម្ភមួយថា នៅឆ្នាំ២០០៩ វិស័យទេសចរណ៍ នឹងធ្លាក់ចុះអស់ដល់ទៅ ៣% ។ ម្ចាស់សណ្ឋាគារ និងទីភ្នាក់ងារទេសចរណ៍មួយចំនួនបានរាយការណ៍មកហើយ ពីការថយចុះការកក់សេវា និងការសាកសួរព័ត៌មានផ្សេងៗពីសំណាក់ភ្ញៀវទេសចរ សំរាប់ឆ្នាំ២០០៩ ។ ប៉ុន្តែ ទីប្រឹក្សាទេសចរណ៍ឯករាជ្យមួយចំនួន មិនបានគិតថា ការលំបាកទាំងនេះវាធ្ងន់ធ្ងរខ្លាំងនោះទេ បើទោះជាពួកគេ បានដាស់តឿនថា ភ្ញៀវទេសចរដែលមកកំសាន្ត អាចកាត់បន្ថយការចំណាយខ្លះក៏ដោយ ។ ភាពទ្រឹងនៃកំណើន មានផលប៉ះពាល់មិនស្មើគ្នាគ្រប់កន្លែងទេ ។ ក្រុមហ៊ុនដែលបំរើទីផ្សារទេសចរណ៍បែបប្រណីត

---

១ លោក ហូ វណ្ណី ជាសហប្រធានក្រុមការងារវិស័យឯកជន ស្ដីពីវិស័យទេសចរណ៍ និងជានាយកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ World Express Tours and Travel Co.Ltd ។

ទំនងត្រូវជួបការលំបាក ច្រើនជាងក្រុមហ៊ុនដែលបំរើសេវាបែបសាមញ្ញដល់អ្នកដំណើរ ។ ដោយសារភាពតានតឹងនៃថវិកា ដូច្នេះតំរូវការផលិតផល និងសេវាមានតំលៃទាប នឹងត្រូវកើនឡើង ហើយគេអាចឃើញមានការផ្លាស់ប្តូរខ្លះៗនៅក្នុង សមាសភាពនៃទីផ្សារនៅឆ្នាំនេះ ។ ទេសចរបរទេសជាច្រើនក្នុងចំណោមភ្ញៀវ ២លាននាក់ ដែលចូលមកកម្ពុជា ក្នុងឆ្នាំ២០០៨ បានធ្វើដំណើរមកពីសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និង កូរ៉េខាងត្បូង ពោលគឺប្រទេសទាំង៣ ដែលប៉ះពាល់ខ្លាំងជាងគេដោយសារវិបត្តិសេដ្ឋកិច្ចសព្វថ្ងៃ ។

កម្ពុជា នៅមានឱកាសល្អមួយចំនួន ដែលអាចជួយលើកស្ទួយវិស័យទេសចរណ៏ឡើងវិញ ។ ទីមួយ ការឡើងថ្លៃប្រាក់ដុល្លារ និងប្រាក់អឺរ៉ូ អាចជំរុញឱ្យប្រជាជនអាមេរិក អឺរ៉ុប និងជប៉ុន បន្តធ្វើដំណើរទៅក្រៅប្រទេស ។ ម្យ៉ាងវិញទៀត ដោយសារសេដ្ឋកិច្ចរបស់ចិន និងឥណ្ឌា នៅតែមានកំណើននោះ ដូច្នេះ ការធ្វើដំណើរចេញពីប្រទេសទាំងពីរ នឹងនៅតែកើនឡើងទោះបីយឺតៗជាងមុនក្តី ។ ការធ្វើដំណើរក្នុងស្រុក និងការធ្វើដំណើរខ្លីៗទៅក្រៅប្រទេស ទំនងជានឹងកើនឡើងច្រើនគួរសម ពីព្រោះប្រជាជនចូលចិត្តធ្វើដំណើរ ទៅកន្លែងនៅជិតៗស្រុកទេសរបស់ពួកគេ ។

ការវិភាគលំអិតបង្ហាញថា ការធ្លាក់ចុះនៃវិស័យទេសចរណ៏ មិនមែនសុទ្ធតែដោយសារការប៉ះទង្គិចពីខាងក្រៅនោះទេ ប៉ុន្តែក៏ដោយសារចំនុចខ្សោយផ្ទៃក្នុងផងដែរ ។ កម្ពុជានៅតែជាជំរើសគោលដៅទេសចរណ៏នៅក្រោយគេឆ្ងាយណាស់ក្នុងពិភពលោក ទោះបីជាមានទីតាំងល្អ មានកេរ្តិ៍ដំណែលវប្បធម៌ដ៏សំបូរ និងចំរុះបែបពីប្រវត្តិសាស្ត្រដ៏យូរលង់ និងមានការរីកចំរើនខាងទេសចរណ៏ល្អវិសេសក្នុងពេលកន្លងទៅនេះ ក៏ដោយ ។ លទ្ធផលនៅទាប គឺបង្កឡើងដោយហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ កន្លែងស្នាក់នៅមិនគ្រប់គ្រាន់ កង្វះបុគ្គលិកមានគុណភាព និង សមត្ថភាពតិចក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស ក៏ដូចជាបណ្តាញដឹកជញ្ជូន នៅខ្វះខាត ។

## គោលនយោបាយគួរអនុវត្ត

ឆ្នាំ២០០៩ រំពឹងថានឹងលំបាកតឹងតែងសំរាប់វិស័យទេសចរណ៏នៅកម្ពុជា ។ ប៉ុន្តែមានហេតុផលជាច្រើនធ្វើឱ្យគេ មានសុទិដ្ឋិនិយមថា វាពិតជាអាចឆ្លងផុតពីវិបត្តិនេះ គឺដូចជាការធ្លាប់ជំនះបានលើបញ្ហាប្រឈមជាច្រើនហើយ តាំងពីពេលចូលដល់សតវត្សរ៏ទី២១ រហូតមក ។ ក្នុងនេះគេចាំបាច់ត្រូវដាក់អនុវត្តគោលនយោបាយមួយចំនួន សំរាប់ដោះស្រាយភាពងាយរងគ្រោះ ដែលបង្កឡើងដោយវិបត្តិ ។ ប៉ុន្តែដើម្បីឱ្យដំណោះស្រាយមានចីរភាពល្អ គេត្រូវលុបបំបាត់ចំណុចខ្វះខាតខាងរចនាសម្ព័ន្ធ ដែលរារាំងដល់ការរីកលូតលាស់វិស័យទេសចរណ៏ ។

គេមាន វិធានការសំរាប់ដោះស្រាយមួយចំនួនដែរ (ប្រអប់ ១) ។ គេត្រូវសង្កត់ធ្ងន់ជាពិសេស លើការចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយទីផ្សារដ៏ទាក់ទាញមួយ ដោយត្រូវអនុម័តប្រើប្រធានបទដ៏គួរឱ្យចាប់ចិត្ត ដូចជា "កម្ពុជា-រាជាណាចក្រអច្ឆរិយ" ដែលប្រកួតប្រជែងបានជាមួយយុទ្ធនាការផ្សព្វផ្សាយនាពេលបច្ចុប្បន្នរបស់បណ្តាប្រទេសក្នុងតំបន់ ដូចជា "ថៃ ទេសចរណ៏នៃស្នាមញញឹមជាថ្មី" "វៀតណាមគួរឱ្យស្ញប់ស្ញែង" និង "ឡាវដ៏សាមញ្ញ" ។ កម្ពុជាអាចធ្វើយុទ្ធនាការផ្សព្វផ្សាយតូចៗតាមរយៈ ប៉ុស្តិ៍ CNN Discovery Channel និង នៅតាមប្រទេសគោលដៅមួយចំនួន ។ ផលប្រយោជន៏អាចទទួលបាន ប្រហែលជួយជំរុញរដ្ឋាភិបាលឱ្យផ្តោតការយកចិត្តទុកដាក់ភ្លាមៗទៅលើសំណើផ្សព្វផ្សាយទីផ្សារនេះ ។ នៅក្នុងកាលៈទេសៈពិសេសនាពេលសព្វថ្ងៃ វិស័យទេសចរណ៏គួរមានប្រើវិធីសាស្ត្រជំរុញការលក់កញ្ចប់ដំណើរកំសាន្ត ។ ការសំរួលបទបញ្ញត្តិផ្តល់ទិដ្ឋាការ និងការបង្កើនល្បឿនការងារត្រួតពិនិត្យ-ផ្តល់ទិដ្ឋាការ អាចបង្កើនចំណូលទេសចរណ៏បានពី ១0% ទៅ ២0% ។ យុទ្ធសាស្ត្ររយៈពេលវែងដទៃទៀត រួមមានការបង្កើតក្រុមហ៊ុនអាកាសចរណ៏ជាតិ និង ក្រុមប្រឹក្សាទេសចរណ៏ជាតិកម្ពុជា ។ អវត្តមាននៃក្រុមហ៊ុនអាកាសចរណ៏ជាតិ គឺជាឧបសគ្គធំបំផុតដល់ការរៀបចំប្រទេសកម្ពុជាឱ្យក្លាយជាគោលដៅទេសចរណ៏ ដ៏សំខាន់ក្នុងពិភពលោក ។ កង្វះការត្រួតពិនិត្យក្នុងវិស័យទេសចរណ៏ គឺជាឧបសគ្គចំបងមួយទៀតដែលត្រូវដោះស្រាយ ។ ឥឡូវនេះដល់ពេលវេលាណាស់ហើយ ដែលត្រូវបង្កើតក្រុមប្រឹក្សាទេសចរណ៏ជាតិកម្ពុជា (ប្រអប់ ២) ។

ភាគីទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យទេសចរណ៏ គួររួបរួមគ្នាឡើង ។ ចូរយើងខំកសាងប្រទេសកម្ពុជា ទាំងអស់គ្នា!

### ប្រអប់ ១: យុទ្ធសាស្ត្រព្រោះព្រំវិស័យទេសចរណ៍ ឡើងវិញ

ជំរើស ១: សម្រួលបទបញ្ញត្តិផ្តល់ទិដ្ឋាការ និង បង្កើនល្បឿនដំណើរការធ្វើទិដ្ឋាការ តាមរយៈការបំពេញសំនុំបែបបទតាមអ៊ីនធឺណេត ការផ្តល់ទិដ្ឋាការឱ្យនៅពេលមកដល់ និងឈប់ប្រមូល ឬបញ្ចុះថ្លៃទិដ្ឋាការ ក្នុងអំឡុងពេលមានវិបត្តិសេដ្ឋកិច្ចសាកលនេះ ។

ជំរើស ២: បង្កើតកញ្ចប់ដំណើរកំសាន្តពិសេសៗ ។

ជំរើស ៣: ស្វែងរកទីផ្សារថ្មីៗនៅអាស៊ី និងជំរុញបន្ថែមការធ្វើដំណើរក្នុងស្រុក។

ជំរើស ៤: ពង្រឹងទំនាក់ទំនងរឹងមាំ និងកសាងផែនការ ផ្ទៃក្នុងតំបន់ (កម្ពុជា-ឡាវ-វៀតណាម + ថៃ) សំរាប់ការផ្សព្វផ្សាយ និងធ្វើម៉ាឃីធីង។

ជំរើស ៥: គិតគូរបង្កើត ក្រុមហ៊ុនអាកាសចរជាតិ ឡើងវិញ។

ជំរើស ៦: ពង្រឹងការធ្វើម៉ាឃីធីងតាមយុទ្ធវិធីផ្សេងៗ ដូចជា យុទ្ធនាការពិសេសៗ ជាដើម

ជំរើស ៧: វិនិយោគបន្ថែមទៅលើផលិតផល និងសេវាទេសចរណ៏អាចប្រកួតប្រជែងបាន ដូចជា សេវាស្ប៉ា និងសេវាជម្រះអារម្មណ៏ ជាដើម ។

ជំរើស ៨: បង្កើតក្រុមប្រឹក្សាទេសចរណ៏ជាតិកម្ពុជា ។

### ប្រអប់ ២: ក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា ទំនួលខុសត្រូវ និងតួនាទីដែលបានស្នើឡើង

- បង្កើតយុទ្ធសាស្ត្រទេសចរណ៍ជាតិសំរាប់ឆ្នាំ២០០៩ និងតទៅមុខទៀត
- បង្កើតគោលនយោបាយ ច្បាប់ ក្រឹត្យ វិធាន និងបទបញ្ជាផ្សេងៗ ស្តីពីការធ្វើដំណើរ និងទេសចរណ៍
- ធ្វើសកម្មភាពខាងទីផ្សារផ្សេងៗ ដើម្បីជំរុញទេសចរណ៍
- ជំរុញការអភិវឌ្ឍធនធានមនុស្សសំរាប់ទេសចរណ៍ និងពង្រឹងការកសាងសមត្ថភាព
- ប្រើប្រាស់ និងត្រួតពិនិត្យលើមូលនិធិផ្សព្វផ្សាយ និងអភិវឌ្ឍន៍ទេសចរណ៍
- សម្របសម្រួល និងសហការណ៍ជាមួយភ្នាក់ងារពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអភិវឌ្ឍ និងកែលំអភាពទាក់ទាញភ្ញៀវទេសចរ លើកកំពស់ប្រពៃណី និងវប្បធម៌កម្ពុជា ក៏ដូចជា អភិរក្ស និងការពារបេតិកភ័ណ្ឌ និងការប្រើប្រាស់ផលិតផលក្នុងស្រុក
- ណែនាំ ត្រួតពិនិត្យ និងសម្របសម្រួលជាមួយ សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា សមាគមសណ្ឋាគារកម្ពុជា និងសមាគមភោជនីយដ្ឋានកម្ពុជា ។
- សហការណ៍ជាមួយអង្គការទេសចរណ៍ថ្នាក់អនុតំបន់ និងអន្តរជាតិ ក៏ដូចជា បណ្តាអង្គការអន្តរជាតិដែលពាក់ព័ន្ធ នឹងទេសចរណ៍
- ចាត់ចែង តាមដាន និងត្រួតពិនិត្យ ការអនុវត្តផែនការទេសចរណ៍
- ជំរុញទេសចរណ៍ និងអាជីវកម្មខាងទេសចរណ៍ ដើម្បីលើកកំពស់ជីវភាពរបស់ប្រជាជន និងជំរុញការដាក់បញ្ចូល ប្រើប្រាស់ផលិតផលក្នុងមូលដ្ឋាន
- លើកកំពស់សិល្បៈ វប្បធម៌ និងប្រពៃណីកម្ពុជា និង ការពារបូជនីយដ្ឋានប្រវត្តិសាស្ត្រ និងបុរាណវត្ថុ ដើម្បីទាក់ទាញភ្ញៀវទេសចរបរទេសឱ្យចូលមកទស្សនា
- ផ្តល់ការងារថ្មីៗ និងបង្កើតឱកាសរកប្រាក់ចំណូលប្រសើរជាងមុនសំរាប់ជនជាតិភាគតិច
- ពង្រីកចំណងមិត្តភាព និងសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល ។

### តើអ្នកដឹងទេថា

... នៅឆ្នាំមុន មានការព្យាយាមម្តងទៀត ដើម្បីបង្កើតក្រុមហ៊ុនអាកាសចរជាតិថ្មីមួយ? នៅខែមេសា ២០០៨ រដ្ឋាភិបាលកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Rajawali ឥណ្ឌូនេស៊ី លើការដេញថ្លៃការចាប់ដំណើរការក្រុមហ៊ុនអាកាសចរជាតិឡើងវិញ ។ តាមកិច្ចព្រមព្រៀង កម្ពុជានឹងទទួលបានភាគហ៊ុន ៥១% ក្នុងគំរោងថ្មី ។ ប៉ុន្តែគួរឱ្យស្តាយ ដោយសារមូលហេតុផ្សេងៗ ដូចជា វិបត្តិកាន់តែធ្ងន់ធ្ងរ និងការលំបាកក្នុងកិច្ចចរចារវាងគូភាគី ផែនការនេះក៏ត្រូវផ្អាកទៅវិញ ។ អាកាសចរភូមិន្ទកម្ពុជា គឺជាក្រុមហ៊ុនអាកាសចរណ៍ជាតិដំបូង របស់កម្ពុជា ដែលបានដំណើរការនៅពាក់កណ្តាលទសវត្សរ៍១៩៩០ ប៉ុន្តែត្រូវដួលរលំទៅវិញ ។

*ប្រភព : សារព័ត៌មាន Reuters (2008) និង សារពត៌មានភ្នំពេញប៉ុស្តិ៍ (២០០៨)*

# ការកសាងប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ: ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល ដើម្បីជួយទ្រទ្រង់មូលដ្ឋានផលិតកម្មកម្ពុជា

*អត្ថបទនេះ សង្ខេបបទបង្ហាញរបស់ ឯកឧត្តម បណ្ឌិត ទី នរិន្ទ និង លោក Stephen Higgins[១] នៅវគ្គទី ៣ខ (១) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

ការជំរុញឧស្សាហូបនីយកម្ម គឺជាយុទ្ធសាស្ត្រធ្លាប់អនុវត្តបានសក្តិសិទ្ធិហើយ ដើម្បីជួយសំរួលដល់វឌ្ឍនភាពជាតិ និងការអភិវឌ្ឍ ។ វាជាមាគ៌ាដែលប្រទេសមានសេដ្ឋកិច្ចកំពុងរីកចំរើនជាច្រើន ធ្លាប់ប្រើប្រាស់បានជោគជ័យ ដូចជាប្រទេសថៃ ជាដើម ។ ថៃបានចាប់ផ្តើមធ្វើទំនើបភាវូបនីយកម្មតាំងពីចុងទសវត្សរ៍១៩៥០ ដែលបានជួយបង្កើនចំណូលក្នុងមនុស្សម្នាក់ពី ១០០ដុល្លារ រហូតដល់ប្រហែល ៣០០០ដុល្លារនាពេលបច្ចុប្បន្ន ។ កត្តាស្នូលនៃដំណើរការនេះ គឺ ការពង្រីកកម្មន្តសាលកម្ម ដែលធ្វើឱ្យចំណែកនៃផ្នែកនេះនៅក្នុង ផសស កើនឡើងមួយជាបី ។ ដូចគ្នានឹងប្រទេសផ្សេងទៀតដែរ កម្មន្តសាលកម្មនៅថៃផ្តើមចេញពីឧស្សាហកម្មអតិពលកម្ម ហើយបន្ទាប់មកបានឆ្លងផុតដំណាក់កាលនេះ ដោយការជំរុញ និងទាក់ទាញកម្មន្តសាលកម្មធុនស្រាល ។ កត្តាដែលជួយបង្កើនល្បឿននៃការផ្លាស់ប្តូរនេះ គឺកំណើនប្រាក់ចំណូល និងតំរូវការរបស់អ្នកប្រើប្រាស់ ។

ផ្អែកលើបទពិសោធន៍នៅប្រទេសដទៃទៀត ឧស្សាហូបនីយកម្ម គឺជាគន្លឹះនៃការផ្លាស់ប្តូរសេដ្ឋកិច្ចកម្ពុជា ។ វិស័យឧស្សាហកម្ម បានជួយទ្រទ្រង់ខ្លាំងដល់កំណើនល្អវិសេសរបស់កម្ពុជា ហើយចំណែកនៃវិស័យនេះ ក្នុង ផសស កើនឡើងស្ទើរមួយជាពីរ ក្នុងទសវត្សរ៍កន្លងទៅ ។ ប៉ុន្តែចំណែកនេះមានកំរិតទាបនៅឡើយ បើធៀបនឹងថៃ ឬ វៀតណាម (ក្រាហ្វិក ១) ។

នៅកម្ពុជា សកម្មភាពឈានមុខគេក្នុងការពង្រីកវិស័យឧស្សាហកម្ម គឺផ្នែកកម្មន្តសាលកម្ម និងសំណង់ ហើយកំណើនកម្មន្តសាលកម្ម គឺផ្អែកលើសកម្មភាពកាត់ដេរ ។ សំលៀកបំពាក់តំណាងឱ្យប្រហែលពាក់កណ្តាល នៃផលិតផលឧស្សាហកម្មកម្ពុជានាពេលបច្ចុប្បន្ន និងជាទំនិញនាំចេញចំបងគេ ។ សមត្ថភាពភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេរ ត្រូវបានកែលំអដោយសារកំណើនផលិតភាពពលករក្នុងវិស័យនេះដល់កំរិតមួយស្មើគ្នានឹងប្រទេសវៀតណាម ។ វិស័យកាត់ដេរផ្តល់ការងារបានតែ ១៣% ប៉ុណ្ណោះ ដល់កម្លាំងពលកម្មក្នុងស្រុក ដែលជាតួលេខដ៏ទាប បើធៀបនឹងអត្រា ៥៩% នៃវិស័យកសិកម្ម (តួលេខសំរាប់ឆ្នាំ២០០៧) ។ ចំពោះសកម្មភាពផលិតកម្មផ្សេងៗទៀតនៅកម្ពុជា វានៅតូចនៅឡើយ បើធៀបនឹងវិស័យកាត់ដេរ ។ ឧទាហរណ៍ដូចជា ផលិតកម្មម្ហូបអាហារ តំណាងឱ្យមិនដល់ ១០% នៃផលិតផលឧស្សាហកម្មសរុបទេ ។

ក្រាហ្វិក ១: ចំណែកឧស្សាហកម្មក្នុង ផសស




*ប្រភព: ធនាគារពិភពលោក Breisinger និង Diao*

ឧបសគ្គធំបំផុតដល់ការពង្រីកកម្មន្តសាលកម្មថែមទៀត គឺ ហេដ្ឋារចនាសម្ព័ន្ធមិនទាន់អភិវឌ្ឍបានគ្រប់គ្រាន់ ជាពិសេស បណ្តាញផ្លូវថ្នល់ និងការផ្គត់ផ្គង់អគ្គិសនី ។

គេប៉ាន់ស្មានថា សហគ្រាសនានានៅកម្ពុជាផលិតបាន ៣៦% នៃតំរូវការអគ្គិសនីរបស់ខ្លួនដោយប្រើម៉ាស៊ីនភ្លើង ។គេប៉ាន់ស្មានទៀតថា ម៉ាស៊ូតតំណាងឱ្យជាង ២០% នៃចំណាយប្រតិបត្តិការរបស់ សណ្ឋាគារមួយចំនួន ។ តួលេខទាំងនេះ គូសបញ្ជាក់ពី បញ្ហាចោទធ្ងន់ធ្ងរក្នុងការផ្គត់ផ្គង់អគ្គិសនី (ប្រអប់ ១) ។

ស្ថានភាពខ្សត់ខ្សោយនៃការដឹកជញ្ជូន អាចមើលឃើញយ៉ាងច្បាស់តាមរយៈចំណាយខ្ពស់ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម ។ របាយការណ៍ថ្មីៗមួយរបស់ធនាគារពិភពលោក បានលើកថា នៅកម្ពុជា ការដឹកជញ្ជូនផលិតផលកសិកម្ម ក្នុងមួយតោនក្នុងចំងាយ ១០០គីឡូម៉ែត្រ ត្រូវចំណាយអស់ ១៥ដុល្លារ ដែលខ្ពស់ជាងវៀតណាម (៧,៥ដុល្លារ) និង ថៃ (៤ដុល្លារ) ។ ស្ថានភាពនេះហាក់ដូចជាគ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេ ពីព្រោះនៅកម្ពុជា ផ្លូវចាក់កៅស៊ូ មានត្រឹម ៦,៣% ប៉ុណ្ណោះ ធៀបនឹង ២៥% នៅវៀតណាម និង ៩៨% នៅថៃ (ក្រាហ្វិក ៣) ។

---

[១] ឯកឧត្តម បណ្ឌិត ទី នរិន្ទ ជាប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ។ លោក Stephen Higgins ជាអគ្គនាយក នៃធនាគារ ANZ Royal ។

រដ្ឋាភិបាលបានដឹងច្បាស់ ពីតំរូវការចាំបាច់នៃការកសាងហេដ្ឋារចនាសម្ព័ន្ធ ។ ផែនការទ្រង់ទ្រាយធំ សំរាប់កែលំអទាំងការផ្គត់ផ្គង់អគ្គិសនី និងបណ្តាញដឹកជញ្ជូន កំពុងតែអនុវត្តហើយ ។ គម្រោងដ៏លេចធ្លោមួយ គឺ "ប្រព័ន្ធអភិវឌ្ឍន៏អគ្គិសនីកម្ពុជា ឆ្នាំ២០១៣-២០១៨" ដែលសំដៅអភិវឌ្ឍប្រព័ន្ធចែកចាយអគ្គិសនី ។ ផ្អែកតាមផែនការនេះ បណ្តាញអគ្គិសនីថ្នាក់ជាតិដែលមានកំរិតវ៉ុលខ្ពស់ នឹងត្រូវបង្កើតឡើង ដោយផ្តើមចេញពី រាជធានីភ្នំពេញ និងសំដៅតភ្ជាប់ទៅទីផ្សារទាំងអស់ ។ បណ្តាញនេះក៏នឹងត្រូវភ្ជាប់ជាមួយទំនប់វារីអគ្គិសនី ដែលមានស្រាប់ និងដែលត្រូវកសាងទៅអនាគតផងដែរ ។ ក្នុងដំណាក់កាលបន្ទាប់ គម្រោងនេះផ្តោតលើការនាំចូលអគ្គិសនីពីវៀតណាម និងថៃ ។ ក្នុងពេលសព្វថ្ងៃ មានគម្រោងវារីអគ្គិសនីចំនួន ៣ ដែលកំពុងសាងសង់ ។

ប្រព័ន្ធផ្លូវជាតិបានកែលំអជិតរួចរាល់ហើយ ចំណែកឯប្រព័ន្ធផ្លូវខេត្តកំពុងបន្តចាក់កៅស៊ូ ។

នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ ភាពជាដៃគូរវាងរដ្ឋ-ឯកជន ត្រូវបង្កើនឡើងទាំងលើចំនួន និងវិសាលភាព ដើម្បីញ៉ាំងឱ្យមានការចែករំលែកបានកាន់តែច្រើននូវបន្ទុកចំណាយ ។ ដោយសារធនធានមានកំណត់ រដ្ឋាភិបាលត្រូវបន្តចរចាសុំការគាំទ្រកាន់តែច្រើនពីម្ចាស់ជំនួយ សំរាប់អគ្គិសនីកម្ពុជា ។ បន្ថែមលើនេះទៀត ប្រព័ន្ធអភិវឌ្ឍន៍អគ្គិសនីកម្ពុជា ដែលជាផែនការដ៏ល្អមួយ ក៏ត្រូវសម្រេចឱ្យបានដែរ ដើម្បីបង្កើនស្ថិរភាព និងកែលំអការផ្គត់ផ្គង់ ក៏ដូចជា បញ្ចុះតំលៃអគ្គិសនី ។ គេរំពឹងថា នៅពីរបីឆ្នាំខាងមុខ បណ្តាញអគ្គិសនីថ្នាក់ជាតិ នឹងត្រូវតភ្ជាប់ទៅនឹងស្ថានីយវារីអគ្គិសនីទាំងអស់ដែលបានអភិវឌ្ឍរួចហើយ ។ សមត្ថភាពផ្គត់ផ្គង់អគ្គិសនី ក៏រំពឹងថានឹងកើនឡើងគួរឱ្យកត់សម្គាល់ នៅតាមតំបន់ដែលទទួលការផ្គត់ផ្គង់ពីអនុស្ថានីយនៃបណ្តាញអគ្គិសនី ។ ឧស្សាហកម្មសំខាន់ៗ និងតំបន់សេដ្ឋកិច្ចពិសេសៗ ក្នុងរង្វង់ចំងាយ ១០គីឡូម៉ែត្រពីអនុស្ថានីយ អាចទទួលបានអគ្គិសនីដែលផ្គត់ផ្គង់តាមខ្សែកាបតចូលផ្ទាល់ និងមានថ្លៃទាប ។ឧស្សាហកម្មដែលផលិតអគ្គិសនីខ្លួនឯង ដោយប្រើម៉ាស៊ីនភ្លើងចាក់ម៉ាស៊ូត ក៏អាចតភ្ជាប់នឹងបណ្តាញផ្គត់ផ្គង់អគ្គិសនីមានតំលៃថោកដែរ ។ វិធានការផ្សេងទៀតដើម្បីកាត់បន្ថយថ្លៃអគ្គិសនី មានដូចជា ការអភិវឌ្ឍប្រភពថាមពលផ្សេងៗដែលមានតម្លៃថោក និងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការដែលតម្រូវឱ្យ

## ប្រអប់ ១: ការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា — បញ្ហាចំបងៗ

**បញ្ហាទី ១: ការផ្គត់ផ្គង់មិនគ្រប់គ្រាន់**

ការផ្គត់ផ្គង់ នៅខ្វះខាតខ្លាំងណាស់ ។ គេប៉ាន់ស្មានថា តំរូវការអគ្គិសនីបានកើនឡើងពី ២០% ទៅ ២៦% ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយសមត្ថភាពផលិតអគ្គិសនីនៅពេលបច្ចុប្បន្នមិនអាចឆ្លើយតបទៅនឹងតំរូវការបានទេ ។ ភាពពឹងផ្អែកយ៉ាងខ្លាំងលើឥន្ធនៈនាំចូលសំរាប់ការផលិតថាមពលក៏នាំឱ្យការផ្គត់ផ្គង់មានលក្ខណៈមិនប្រាកដប្រជា និងបន្ទុកចំណាយខ្ពស់ទៀតផង ។ ប្រទេសកម្ពុជាមានសក្តានុពលខាងវារីអគ្គិសនី ប៉ុន្តែសក្តានុពលនេះមិនអាចជឿទុកចិត្តទាំងស្រុងបានទេ ដោយសារភ្លៀងមិនទៀងទាត់ និងទឹកមានតិចនៅរដូវប្រាំង ហើយប្រទេសកម្ពុជាក៏ខ្វះខាតប្រភពថាមពលដទៃទៀតដូចជា ធ្យូងថ្ម និងឧស្ម័ន ជាដើម ។

**បញ្ហាទី ២: ភាពមិនអាចបានប្រើប្រាស់ និងភាពមិនអាចជឿទុកចិត្តបាននៃការផ្គត់ផ្គង់**

បញ្ហានេះ កើតឡើងដោយសារប្រព័ន្ធចែកចាយ និងបញ្ជូនអគ្គិសនី មានលក្ខណៈអន់ខ្សោយ ។ ការកែលំអ និងថែទាំប្រព័ន្ធទាំងនេះ ត្រូវធ្វើឡើងជាចាំបាច់ដើម្បីធានាថា អគ្គិសនីបានទៅដល់កន្លែងប្រើប្រាស់ ហើយការផ្គត់ផ្គង់មានស្ថិរភាព ។ ទោះជាយ៉ាងនេះក្តី ដើម្បីសំរេចគោលបំណងនេះបាន ត្រូវមានហិរញ្ញប្បទានយ៉ាងច្រើន ។

**បញ្ហាទី ៣: ចំណាយខ្ពស់**

ឧបសគ្គចំបងមួយចំពោះកំណើន គឺ តំលៃអគ្គិសនីខ្ពស់ពេក ( ក្រាហ្វិក ២) ។ផ្អែកតាមធនាគារពិភពលោក នៅកម្ពុជា តំលៃអគ្គិសនីមានកំរិតពី ០,១៨ដុល្លារនៅតំបន់ទីប្រជុំជន និង ០,៣០-០,៩០ដុល្លារ នៅជនបទ ។តំលៃនេះខ្ពស់ណាស់ បើធៀបនឹងប្រទេសជិតខាង ដែលសុទ្ធតែមានតំលៃទាបជាង ០,១០ដុល្លារ ។ ក្រៅពីចំណាយខ្ពស់លើធាតុចូល និងការផលិតថាមពលមានលក្ខណៈដាច់ដោយដុំ កត្តាបង្កើនតំលៃអគ្គិសនីមួយទៀត គឺ កង្វះប្រសិទ្ធភាពនៃប្រតិបត្តិការនាំឱ្យមានការបាត់បង់អគ្គិសនីយ៉ាងច្រើននៅពេលបញ្ជូន និងចែកចាយ ។ គេប៉ាន់ស្មានថា ពីឆ្នាំ ១៩៩៨ ដល់ ២០០៨ អគ្គិសនីប្រហែល ១០,៧% បានបាត់បង់ ហើយការបាត់បង់នៅឆ្នាំមុនៗនោះទៀត មានរហូតដល់ ២៨-៣០% ។

**បញ្ហាទី ៤: កង្វះហិរញ្ញប្បទាន**

ត្រូវមានវិនិយោគច្រើនណាស់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់គម្រោងខ្នាតធំៗ ដើម្បីដោះស្រាយបញ្ហាដូចខាងលើ ។ នាពេលបច្ចុប្បន្ន រដ្ឋាភិបាលមិនមានសមត្ថភាពខាងហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើវិនិយោគទេ ដូច្នេះត្រូវមានកិច្ចសហប្រតិបត្តិកាន់តែខ្លាំងក្លាជាមួយដៃគូអភិវឌ្ឍន៏នានា ។

*ប្រភព : ធនាគារពិភពលោក ការរក្សាកំណើនលឿន នៅក្នុងបរិយាកាសដ៏លំបាក ( ឯកសារជំនួយស្មារតីស្តីពី សេដ្ឋកិច្ចកម្ពុជា) ២០០៩*

ក្រាហ្វិក ២: តំលៃអគ្គិសនីក្នុងមួយគីឡូវ៉ាត់ម៉ោង (គិតជាសេន)




ក្រាហ្វិក ៣: ភាគរយនៃផ្លូវចាក់កៅស៊ូ




ដោះស្រាយ បញ្ហាពិបាកៗមួយចំនួនទាក់ទងនឹងអភិបាលកិច្ច សេរីភាវូបនីយកម្មទីផ្សារ ការប្រកួតប្រជែងដោយយុត្តិធម៌ និងការកសាងបទបញ្ញត្តិគ្រប់គ្រងដោយឯករាជ្យ ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជួយបង្កើនសមត្ថភាពរបស់ប្រទេសក្នុងការទាញយកផលពីសក្តានុពល នៃឧស្សាហកម្មកម្មន្តសាលរបស់ខ្លួន ។ ការអង្កេតមួយពីកាលានុវត្តភាពផ្សេងៗនាបច្ចុប្បន្ន និងទៅអនាគត បានបង្ហាញថា វិស័យនេះផ្តល់ក្តីសង្ឃឹមច្រើន ។ ដោយឡែកកាលានុវត្តភាពមួយដែលបានអង្កេតឃើញ គឺ ទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជា ។ ការកសាងផ្លូវដែកតភ្ជាប់ក្នុងតំបន់ នឹងបើកចំហទីផ្សារកាន់តែធំសំរាប់ការផ្លាស់ប្តូរជំនាញចំណេះដឹង និងផលិតផល ។ កាលានុវត្តភាពមួយទៀត ទាក់ទងនឹងការផ្លាស់ប្តូរនៅក្នុងទីផ្សារពលកម្ម ។ ឧទាហរណ៍ គេបានទស្សទាយថា នឹងមានពលករខាងកសិកម្មកាន់តែច្រើន ដែលចង់ចូលទៅបំរើការក្នុងឧស្សាហកម្មកម្មន្តសាលវិញ នៅពេលពួកគេបានរៀនទូវជំនាញដ៏ចាំបាច់រួចហើយ ។ ស្ថានភាពនេះនឹងបង្កើនសំពាធឱ្យខំពង្រីកកម្មន្តសាលកម្ម ។

ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ មិនមែនជាបញ្ហាតែមួយដែលវិស័យកម្មន្តសាលត្រូវប្រឈមនោះទេ ។ វិបត្តិបានបង្ខំឱ្យមានការយកចិត្តទុកដាក់លើបញ្ហាមានយូរមកហើយមួយ គឺ កង្វះការធ្វើចំរុះកម្ម ។ ការពឹងផ្អែកខ្លាំងលើផ្នែកកាត់ដេរ បានធ្វើឱ្យវិស័យឧស្សាហកម្មមិនអាចបំបែកនិងពង្រាយហានិភ័យកើត ហើយក៏មិនអាចគេចផុតពី ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសាកល ។ គោលនយោបាយខាងឧស្សាហកម្មមួយដែលផ្អែកលើបទពិសោធន៍រៀនសូត្របានពីវិបត្តិ គឺ ការផ្តល់អាទិភាពលើការធ្វើចំរុះកម្ម ។ ដូចបានលើកឡើងរួចហើយ ផលិតកម្មម្ហូបអាហារ មានចំណែកត្រឹមតែ ១០% ប៉ុណ្ណោះនៅក្នុងផលិតកម្មឧស្សាហកម្ម ។ ផ្នែកនេះអាចកែលំអទៀតបាន ជាពិសេសឈរលើការពិតដែល ផលិតផលនាំចូលជាច្រើន ផលិតចេញពីវត្ថុធាតុដើមដែលកកើតឡើងនៅកម្ពុជា ។

ឧបសគ្គមួយទៀតចំពោះកំណើនកម្មន្តសាលកម្ម គឺ ស្ថានភាពអភិបាលកិច្ចខាងផ្លូវច្បាប់ដែលមានបញ្ហា ។ គេមិនគួរមើលស្រាលពីសារៈសំខាន់នៃការពង្រឹងអនុវត្តកិច្ចសន្យា សំរាប់វិនិយោគិន និងធនាគារឡើយ ។ ការបង្កើតតុលាការពាណិជ្ជកម្មឯករាជ្យមួយដែលមានចៅក្រមប្រកបដោយគុណភាពក៏សំខាន់ណាស់ដែរ ។

គេមិនអាចគេចផុតពីការចោទសួរថា តើដុល្លារូបនីយកម្មកំរិតខ្ពស់នៅតែមានប្រយោជន៍សំរាប់ប្រទេសកម្ពុជា ឬយ៉ាងណានោះទេ ។ ផលចំណេញ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម ត្រូវតែយកមកពិនិត្យឡើងវិញ ។ ផលចំណេញមួយ គឺ វិនិយោគិនបរទេសនិយមធ្វើជំនួញជាប្រាក់ដុល្លារ ចំណែកឯគុណវិបត្តិវិញ គឺ វាលុបបំបាត់លទ្ធភាពប្រើប្រាស់ការបញ្ចុះតំលៃរូបិយវត្ថុដើម្បីបង្កើនភាពប្រកួតប្រជែង ។

សកម្មភាពផ្សេងទៀតដែលអាចជំរុញការអភិវឌ្ឍកម្មន្តសាលកម្ម គឺ ការបង្កើនវិនិយោគលើការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជ្រើសរើសប្រើគ្រឿងលើកទឹកចិត្តខាងពន្ធដារ និង ការកាត់បន្ថយចំណាយក្រៅផ្លូវការលើវិនិយោគ ។ ការអង្កេតថ្មីៗមួយបានរកឃើញថា មានសហគ្រាសចំនួន ៥២% បានកំណត់អំពើពុករលួយជាកត្តារាំងស្ទះយ៉ាងធំសំរាប់វិនិយោគ ។ រឿងនេះក៏បានដាក់បញ្ចូលការងារដោះស្រាយអំពើពុករលួយទៅក្នុងរបៀបវារៈ ។

ឧស្សាហូបនីយកម្ម បានជួយសំរួលដល់ការអភិវឌ្ឍនៅប្រទេសជាច្រើន ។ នេះជាមាគ៌ាដែលបើកចំហសំរាប់កម្ពុជាដែរ ប៉ុន្តែការធ្វើដំណើរមិនមែនងាយស្រួលទេ ។ ដើម្បីសំរេចគោលដៅនេះ ត្រូវមានសកម្មភាពស៊ីចង្វាក់គ្នារវាងរដ្ឋាភិបាល នឹងដៃគូអភិវឌ្ឍន៍នានា ៕

## តើអ្នកបានដឹងទេថា

**... កម្ពុជា កំពុងស្ថិតក្នុងដំណើរការបង្កើត "ទំនប់វារីអគ្គិសនីទន្លេឆាងជាង" របស់ខ្លួនមួយ?** ទំនប់កំចាយក្នុងខេត្តកំពត ដែលប្រៀបដូច ទំនប់វារីអគ្គិសនីទន្លេឆាងជាងរបស់ចិន ដោយសារទំហំដ៏ធំ របស់វាក្នុងបរិបទកម្ពុជានោះ កំពុងតែសាងសង់ឡើង ។ គម្រោងវារីអគ្គិសនីជាច្រើនទៀតដែលជំរុញឡើងជាសំខាន់ដោយសារវិនិយោគរបស់ប្រទេសចិន កំពុងដំណើរការសាងសង់ ឬនឹងត្រូវសាងសង់ ។ គម្រោងទាំងនេះ រួមមានទាំង ទំនប់នានានៅជុំវិញតំបន់ភ្នំក្រវាញផង ។ គោលបំណងដែលប្រកាសចេញលើការអភិវឌ្ឍទំនប់វារីអគ្គិសនីទាំងនេះ គឺសមរម្យគួរឱ្យកោតសរសើរ ប៉ុន្តែក៏នៅតែមានមតិរិះគន់ពី កង្វះតម្លាភាពក្នុងកិច្ចចរចា និងការយល់ឃើញថាពុំមានការគិតគូរពីផលប៉ះពាល់នៃគម្រោងទៅលើបរិស្ថាន ។ នៅឆ្នាំ២០០៨ របាយការណ៍រួមគ្នាមួយរវាងអង្គការមិនមែនរដ្ឋាភិបាល International Rivers (ទន្លេអន្តរជាតិ) និង Rivers Coalition in Cambodia (សហព័ន្ធទន្លេនៅកម្ពុជា) បានអះអាងថា "ការអភិវឌ្ឍវារីអគ្គិសនីនៅកម្ពុជា បានធ្វើឡើងដោយមិនមានការពិគ្រោះយោបល់គ្រប់គ្រាន់ជាសាធារណៈ និងកង្វះជាទូទៅនូវតម្លាភាពក្នុងដំណើរការធ្វើសេចក្តីសំរេច ។" ម្យ៉ាងទៀត រដ្ឋសភាក៏បានអនុម័ត ច្បាប់មួយដែលដាក់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើការ ខាតបង់ផ្នែកហិរញ្ញវត្ថុដែលអាចកើតមានឡើង ចំពោះគម្រោងវារីអគ្គិសនីពីររបស់ចិន ក្នុងករណីមានអស្ថិរភាពនយោបាយ ។

*ប្រភព : អង្គការទន្លេអន្តរជាតិ និង សហព័ន្ធទន្លេនៅកម្ពុជា ២០០៨ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ២០០៩, IRIN ២០០៩*




របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩ ផ្តល់ការវិភាគលំអិតលើផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារ និងបញ្ហាចោទខាងគោលនយោបាយ ការពិនិត្យជាលក្ខណៈមីក្រូពីផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារនៅកំរិតភូមិ ផ្តល់លទ្ធផលរកឃើញមួយចំនួន ក្នុងការស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ស្តីពីការដឹកនាំនៅថ្នាក់ភូមិ និងការពិនិត្យត្រួសៗពីផលប៉ះពាល់ដែលវិបត្តិហិរញ្ញវត្ថុសាកល អាចបង្កចំពោះតំបន់អាស៊ី ប្រទេសកម្ពុជា និងជាពិសេសចំពោះជនក្រីក្រ និងជនងាយរងគ្រោះ ។ របាយការណ៍ក៏ពិនិត្យផងដែរពីបញ្ហាផ្សេងៗ ទាក់ទិននឹងការអភិវឌ្ឍចំការកៅស៊ូនៅកម្ពុជា ទំនាក់ទំនងរវាងចំនួនម៉ោងធ្វើការ និងសុខភាពកុមារនៅតាមបណ្តាសហគមន៍ធ្វើកសិកម្មនៅជនបទ ។

# ការកសាងប្រទេសកម្ពុជាឱ្យឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗ ដើម្បីកំណើននៅអនាគត ការអភិវឌ្ឍ និងការកាត់បន្ថយ ភាពក្រីក្រ: អចលនទ្រព្យ និងសំណង់

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ឯកឧត្តម ងី តាយី លោក Sung Bonna និងលោក Anthony Galliano[១] នៅអំឡុងវគ្គទី ៣ខ (២) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## វិស័យអចលនទ្រព្យនៅកម្ពុជា: ពីការរីកដុះដាលលឿន (boom) ទៅជាការរលំរលាយ (bust)

វិស័យអចលនទ្រព្យកម្ពុជា បានចាប់ផ្តើមធ្លាក់ចុះបន្ទាប់ពីមានកំណើនលឿននៅក្នុងឆ្នាំ២០០៧ ។ នៅឆ្នាំ២០០៧ ដីធ្លីនៅរាជធានីភ្នំពេញបានឡើងថ្លៃ ៨០% ។ វិនិយោគបានហូរចូលមកក្នុងប្រទេស ជាពិសេសពីកូរ៉េខាងត្បូង ហើយគម្រោងខ្នាតធំមួយចំនួន កំពុងស្ថិតក្នុងដំណាក់កាលសាងសង់ ។ ស្ថានភាពទាំងនេះ បានបង្កើនការរំពឹងទុក ភាពប្រថុយប្រថាននឹងហានិភ័យ និងការឆក់ឱកាស ។ វិស័យអចលនទ្រព្យ បានរីកដុះដាលលឿនៗ ដោយសារមនុស្សមើលឃើញនូវកំណើនផលចំណេញពីវិនិយោគក្នុងវិស័យនេះ ។ ជាទូទៅ គេយល់ឃើញថា ដីធ្លី និងអាគារសង់ថ្មី នៅតែមានតម្រូវការខ្ពស់ ដូច្នេះអាចលក់ចេញយ៉ាងស្រួល និងបានចំណេញច្រើន ។ ប្រជាជនទូទៅ ក៏មានសុទិដ្ឋិនិយមខ្លាំង និងលែងប្រុងប្រយ័ត្ន លើភាពរឹងមាំនៃលំហូរចូលវិនិយោគបរទេស ។ ដោយសារសំណង់ភាគច្រើនសំរាប់ប្រើជាលំនៅដ្ឋាន និងអាគារពាណិជ្ជកម្ម ដូច្នេះទស្សនៈសុទិដ្ឋិនិយមនេះ ក៏រីករាលដាលទៅដល់វិស័យសំណង់ ។

នៅទីបំផុត វិបត្តិដែលជាលទ្ធផលផង និងជាមូលហេតុផងនៃការបាក់ស្រុតវិស័យអចលនទ្រព្យក្នុងសាកលលោក បានធ្វើឱ្យការរីកដុះដាលវិស័យអចលនទ្រព្យនៅកម្ពុជាត្រូវបាក់ស្រុតដែរ ។ នៅឆ្នាំ២០០៨ គេឃើញមានសញ្ញាជាច្រើន នៃការរីកដុះដាលផ្នែកអចលនទ្រព្យលឿនពេក ដូចជាពលកម្ម និងសម្ភារ:សំណង់ ឡើងថ្លៃខ្ពស់ជាដើម ។ អចលនទ្រព្យបន្តឡើងថ្លៃរហូតដល់ពាក់កណ្តាលឆ្នាំ២០០៨ ជួនកាលដល់ ១០០% ខ្ពស់ជាងកាលពីមួយឆ្នាំកន្លងទៅ ។ ប៉ុន្តែដោយសារវិបត្តិកាន់តែធ្ងន់ធ្ងរឡើងនៅពីរត្រីមាសចុងក្រោយ ទើបការរីកដុះដាលមិនអាចស្ថិតស្ថេរបាន ដោយវាប្រឈមមុខនឹងស្ថានភាពឥណទានរឹតតែខ្វះខាត ការផ្តល់កម្ចីពីធនាគារកាន់តែតឹងតែង ទុនវិនិយោគដែលរត់ចេញទៅវិញ និង កំណើនការប្រុងប្រយ័ត្ននៃវិនិយោគិន និងអ្នកប្រើប្រាស់ ។

វិបត្តិសាកល បានធ្វើឱ្យការជឿជាក់លើវិស័យអចលនទ្រព្យរលាយបាត់អស់ ។ លើផ្នែកផ្គត់ផ្គង់ គេបាន និយាយថា វិបត្តិបានបង្កើនចំនួនអ្នកផ្គត់ផ្គង់ដល់ ៤៥% ដោយសារប្រជាពលរដ្ឋកាន់តែច្រើន ចង់លក់ចេញនូវអចលនទ្រព្យ

ក្រាហ្វិក ១: វិនិយោគផ្ទាល់ពីបរទេស (គិតជាលានដុល្លារUS)




*ប្រភព: អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ២០០៩*

ដែលមានថ្លៃទាបក្នុងស្ថានភាពសេដ្ឋកិច្ចដ៏យ៉ាប់យ៉ឺន ។ ចំណែកឯតម្រូវការវិញ វាទៅថេរ ឬ ធ្លាក់ចុះប្រហែល ៥% ។ ជាលទ្ធផល ក៏រឹតថ្លៃបានធ្លាក់ចុះ ៣០% ទៅ ៤០% ហើយសកម្មភាពលក់បានស្រុតចុះយ៉ាងលឿនអស់ពី ៥០% ទៅ ៨០% ។ គេវាយតម្លៃថា នៅឆ្នាំ២០០៨ វិស័យសំណង់រួមចុះវិញ បន្ទាប់ពីកើនឡើងបាន ៦,៧% នៅឆ្នាំ២០០៧ ។

ការវិវត្តទាំងនេះ នាំឱ្យបាត់បង់ចំណូលពន្ធរដ្ឋ និងជះឥទ្ធិពលអាក្រក់ដល់ស្ថានភាពការងារ ។ អត្រាបញ្ជប់ពីការងារជាបណ្តោះអាសន្ន និងភាពគ្មានការងារធ្វើ បានកើនឡើង ដោយសារក្រុមហ៊ុននានា កាត់បន្ថយចំណាយប្រតិបត្តិការ ឬបិទទ្វារតែម្តង ។ គេបានប៉ាន់ស្មានថា មកដល់ពាក់កណ្តាលឆ្នាំ២០០៨ ការងារសំណង់ប្រហែល ១៥.០០០ការងារ ត្រូវបានបាត់បង់ ។ ការព្យាករណ៍មួយទៀតរឹតតែអវិជ្ជមានខ្លាំង ដោយបានបញ្ជាក់ថា ប្រហែល ៣០% នៃកម្មករសំណង់ទាំងអស់នៅកម្ពុជា បានបាត់បង់ការងារ ដោយសារគំរោងសាងសង់មួយចំនួនបានបញ្ឈប់ ឬផ្អាកដំណើរការ ។ វិបត្តិមិនមែនជះឥទ្ធិពលចំពោះតែកម្មករសំណង់ ប៉ុណ្ណោះទេ ។ ឈ្មួញកណ្តាលស្ថាបត្យករ និងនិយោជិតមានជំនាញខ្ពស់ដទៃទៀតក្នុងវិស័យអចលនទ្រព្យ និងសំណង់ ក៏ទំនងជាបានបាត់បង់ការងារ ឬជួបស្ថានភាពមានការងារធ្វើមិនពេញលេញដែរ ។

នាពេលបច្ចុប្បន្ន វិស័យអចលនទ្រព្យ និងវិស័យសំណង់ កំពុងដំណើរការក្នុងបរិយាកាស មិនប្រាកដប្រជា និងមានហានិភ័យខ្ពស់ ដោយសារផលវិបាកនៃវិបត្តិ ។ អ្នកទិញ ឈ្មួញ និងអ្នកវិនិយោគក្នុងវិស័យនេះ បានសំដែងការព្រួយបារម្ភជាខ្លាំងចំពោះការធ្លាក់ចុះយ៉ាងលឿនបែបនេះ ដែលអាចបណ្តាលមួយភាគធំមកពី ការថយចុះវិនិយោគពីបរទេស និងការថយចុះនៃទ្រព្យធន ។ លក្ខខណ្ឌហិរញ្ញប្បទានកាន់តែតានតឹង និងការប្រមើលពីកំណើនកាន់តែអាប់អួរ បានបង្កការផ្អាកដំណើរការ ឬ ការកាត់បន្ថយផែនការវិនិយោគ ។ ដោយសារសេដ្ឋកិច្ចកូរ៉េខាងត្បូងរងការប៉ះទង្គិចពីវិបត្តិ ដែលធ្វើឱ្យខ្សត់ឥណទាន និងមានការរឹតបន្តឹងកម្ចីធនាគារ វិនិយោគិនកូរ៉េ

[១] ឯកឧត្តម ងី តាយី ជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោក Sung Bonna ជាអគ្គនាយកនៃ ក្រុមហ៊ុន Bonna Realty Group និងលោក Anthony Galliano ជានាយកផ្នែកសាជីវកម្ម ស្ថាប័ន និងទំនាក់ទំនងធនាគារនៃធនាគារ ANZ Royal ។

ក្រាហ្វិក ២: តម្លៃគំរោងសាងសង់នៅភ្នំពេញ (ផ្អែកលើ អនុមតិគំរោង គិតជា លានដុល្លារUS)




*ប្រភព: សាលារាជធានីភ្នំពេញ*

ត្រូវបង្ខំចិត្តធ្វើការរឹតត្បិតលើវិនិយោគរបស់ខ្លួន ។ យោងតាមទិន្នន័យរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ គេបានប៉ាន់ស្មានថា នៅឆ្នាំ២០០៨ វិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា បានធ្លាក់ចុះមកត្រឹម ៧៨៥លានដុល្លារ ធៀបនឹង ៨៦៦លានដុល្លារ កាលពីឆ្នាំ២០០៧ ។ ដោយដឹងថា កម្ចីសំរាប់វិស័យអចលនទ្រព្យមានហានិភ័យខ្ពស់ ធនាគារនៅកម្ពុជាក៏បានដាក់កំហិតខ្លាំងចំពោះកម្ចីដល់វិស័យនេះ ។ វិបត្តិបានកាត់បន្ថយទ្រព្យធន ប្រាក់ចំណូល និងទំនុកចិត្តរបស់ប្រជាជន ធ្វើឱ្យពួកគេប្រុងប្រយ័ត្នខ្ពស់លើ ការចំណាយ ។ កត្តាដែលរឹតតែធ្ងន់ធ្ងរ គឺ ក្របខណ្ឌច្បាប់គ្រប់គ្រងវិស័យអចលនទ្រព្យក្នុងស្រុកនៅមានលក្ខណៈទន់ខ្សោយ និងមិនពេញលេញ ។ ប្រសិនបើមានក្របខណ្ឌច្បាប់ប្រសើរជាងនេះ ការធ្លាក់ចុះក៏មិនសូវធ្ងន់ធ្ងរដែរ ។

## ការឆ្លើយតបនឹងវិបត្តិ: គោលនយោបាយ និងបញ្ហា

ដើម្បីសំរាលការធ្លាក់ចុះកំណើនក្នុងវិស័យអចលនទ្រព្យ និងសំណង់ រដ្ឋាភិបាលបានអនុវត្តវិធានការ ដូចជា ការលុបចោលក៏រិតអតិបរមា ១៥% លើកំចីធនាគារសំរាប់ផ្អែកអចលនទ្រព្យ ជាដើម ។ គេមិនទាន់មើលឃើញទេថាតើវិធានការនេះ អាចធ្វើឱ្យធនាគារព្រមផ្តល់កម្ចីដល់វិស័យអចលនទ្រព្យ ឬទេ នៅពេលដែលហានិភ័យកំពុងកើតមានបន្តទៀត ។ វិធានការមួយទៀតរបស់រដ្ឋាភិបាលដែលចំរូងចំរាសខ្លាំង គឺការដាក់ចេញនូវបទបញ្ញត្តិច្បាប់បង្កើនការត្រួតពិនិត្យរបស់រដ្ឋាភិបាលក្នុងវិស័យនេះ ។ គោលដៅមួយទៀតនៃបទបញ្ញត្តិទាំងនេះ គឺផ្តល់កិច្ចការពារកាន់តែប្រសើរដល់អ្នកទិញអចលនទ្រព្យ ពីអ្នកអភិវឌ្ឍដែលមិនមានមូលធនគ្រប់គ្រាន់ ។ បទបញ្ញត្តិទាំងនោះរួមមាន ការបង្កើតស្ថាប័នអន្តរក្រសួងសំរាប់ត្រួតពិនិត្យវិស័យនេះ ការគ្រប់គ្រង និងត្រួតពិនិត្យលើការចេញអាជ្ញាប័ណ្ណ និងការតំរូវឱ្យប្រើគណនីបិទការដកប្រាក់ (locked account) សំរាប់ដាក់ប្រាក់កក់អតិថិជន ។ ក្រុមខ្លះជំទាស់ជាខ្លាំងនឹងបទបញ្ញត្តិទាំងនេះ ហើយទាមទារឱ្យលុបចោល ឬពន្យារពេលការដាក់អនុវត្ត ដោយពួកគេយល់ថា បទបញ្ញត្តិទាំងនេះនឹងរាំងស្ទះកាន់តែខ្លាំងដល់វិនិយោគក្នុងពេលដែលវិស័យអចលនទ្រព្យកំពុងមានវិបត្តិ ។ ក្រុមអ្នកគាំទ្របទបញ្ញត្តិបានឆ្លើយតបវិញថា មិនគួរពន្យាពេលដាក់អនុវត្តទេ ពីព្រោះកិច្ចការពារទប់ទល់នឹងពួកអ្នកអភិវឌ្ឍមិនត្រឹមត្រូវ គឺរឹតតែសំខាន់ជាងទៀតក្នុងអំឡុងពេលនេះ ។

គេព្យាករណ៍ថា នៅឆ្នាំ២០០៩ វិស័យអចលនទ្រព្យនៅកម្ពុជា នៅតែស្រពិចស្រពិល និងមានហានិភ័យ ។ ស្ថានភាពនេះនឹងប៉ះពាល់ដោយផ្ទាល់ទៅលើឧស្សាហកម្មសំណង់ ដែលស្ថិតក្នុងចំណោមវិស័យចំបងទាំងបួនដែលជំរុញកំណើននៅក្នុងប្រទេស ។ គេប៉ាន់ស្មានថា នៅឆ្នាំនេះ ឧស្សាហកម្មសំណង់នឹងបន្តថយកំណើនមកត្រឹម ៥,៧% ហើយការងារខាងសាងសង់ដូចជា កម្មករសំណង់ ឈ្មួញកណ្តាល វិស្វករ និងការងារពាក់ព័ន្ធផ្សេងៗ អាចបាត់បង់អស់ប្រហែលពី ១០០.០០០-១៥០.០០០ការងារ ។

ដោយយល់ឃើញថា រដ្ឋាភិបាលបានយកចិត្តទុកដាក់ច្រើនជាងលើការកាត់បន្ថយផលប៉ះពាល់នៃវិបត្តិទៅលើវិស័យឯទៀតៗ ដូច្នេះ ពួកអ្នកអភិវឌ្ឍអចលនទ្រព្យឯកជន បានអំពាវនាវសុំការយកចិត្តទុកដាក់បន្ថែមពីអាជ្ញាធរ ។ ក្នុងចំណោមគោលនយោបាយដែលស្នើឡើង គោលនយោបាយចំបងមួយគឺការអភិវឌ្ឍក្របខណ្ឌច្បាប់ពាក់ព័ន្ធ ។ គេត្រូវបង្កើតស្តង់ដារលើការកំណត់តម្លៃ ថ្លៃឈ្នួល កម្រៃជើងសារ និងប្រតិបត្តិការនៃទីភ្នាក់ងារអចលនទ្រព្យ ហើយក៏គួរមានការអនុម័តនូវច្បាប់ស្តីពីការអភិវឌ្ឍលំនៅដ្ឋាន ព្រមទាំងក្រមសីលធម៌សំរាប់អ្នកអភិវឌ្ឍ ។ អនុសាសន៍ផ្សេងទៀត រួមមាន ការដាក់បញ្ចូលសមាគមអ្នកកំណត់តម្លៃថ្នាក់ជាតិរបស់កម្ពុជា ជាសមាជិកសមាគមអ្នកកំណត់តម្លៃរបស់អាស៊ាន ការបង្កើតវិទ្យាស្ថានសំរាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអចលនទ្រព្យ ការបង្កើតសមាគមអ្នកអភិវឌ្ឍលំនៅដ្ឋាន ការទាក់ទាញវិនិយោគកាន់តែច្រើន តាមរយៈការផ្សព្វផ្សាយឯកសារជាប់ទាក់ទងនឹងអចលនទ្រព្យដល់វិនិយោគិន និងការកាត់បន្ថយបែបបទការិយាធិបតេយ្យ ការពង្រឹងអនុវត្តន៍ច្បាប់ការពារវិនិយោគិន ការបញ្ចុះអត្រាការប្រាក់កម្ចីធនាគារសំរាប់អចលនទ្រព្យ និង ការផ្សព្វផ្សាយកាន់តែធំទូលាយនូវព័ត៌មានស្តីពីថ្លៃដីធ្លីនៅក្នុងប្រទេស ។ ដើម្បីកុំឱ្យមានការរលំរលាយវិស័យអចលនទ្រព្យម្តងទៀត ចាំបាច់ត្រូវបំពេញការខ្វះចន្លោះផ្សេងៗនៅក្នុងការត្រួតពិនិត្យ និងបទបញ្ញត្តិ ។ ប៉ុន្តែបញ្ហាលំបាក គឺការមូលមតិគ្នាលើចំណុចនៅខ្វះចន្លោះ និងលក្ខណៈលំអិតនៃបទបញ្ញត្តិដែលគួរដាក់ចេញ ៕

## តើអ្នកបានដឹងទេថា

... វិបត្តិនៃកម្ចីលេខ២មានអ៊ីប៉ូតែក (subprime mortgage) ដែលជាដើមចមនៃការដួលរលំសេដ្ឋកិច្ចសាកល គឺបង្កឡើងពីការរលំរលាយវិស័យអចលនទ្រព្យនៅសហរដ្ឋអាមេរិក? ការរីបអូសទ្រព្យច្រើនជាខ្លាំង ជាងការរំពឹងទុក និងការធ្លាក់ថ្លៃទាបបំផុតនៃអចលនទ្រព្យនៅឆ្នាំ២០០៦ នៅសហរដ្ឋអាមេរិក បានធ្វើឱ្យទ្រព្យអ៊ីប៉ូតែកធ្លាក់ថ្លៃយ៉ាងលឿន ។ រឿងនេះបានបន្ទាបគុណភាពឥណទានលើទ្រព្យដទៃ និងបណ្តាលឱ្យ គ្រឹះស្ថានហិរញ្ញវត្ថុធំៗជាច្រើនទទួលរងការខាតបង់ធ្ងន់ធ្ងរ ឈានទៅដល់ការដួលរលំ ។ ការរីកដុះដាលលឿនៗនៃវិស័យអចលនទ្រព្យ គឺពិបាកនឹងស្មានដឹងច្បាស់ជាមុនណាស់ ប៉ុន្តែមានសូចនាករមួយចំនួនដែលអាចប្រើបានសំរាប់វាស់វែងពី វត្តមានរបស់វា ដូចជា អនុបាតថ្លៃ-ចំណូល និង អនុបាតសេវាសងបំណុល ។

*ប្រភព : ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៨ និង Wikipedia*

... គម្រោងសាងសង់ធំៗសំបើមនៅរាជធានីភ្នំពេញ កំពុងបន្តដំណើរការ ទោះបីមានការធ្លាក់ចុះសេដ្ឋកិច្ច និងទោះបីមានការពន្យាពេលខ្លះក្តី? គម្រោងសាងសង់ធំៗទាំងនេះ រួមមាន បុរីកាំកូ បុរីអន្តរជាតិភ្នំពេញថ្មី និង បុរីកោះពេជ្រ ។ ក្នុងករណី បុរីអន្តរជាតិភ្នំពេញថ្មី មានរបាយការណ៍ថា កាលបរិច្ឆេទបង្ហើយគំរោងសាងសង់ ត្រូវពន្យារពេលប្រហែលមួយឆ្នាំ ។

*ប្រភព : សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ២០០៩*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីស្ថានការណ៍សេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនជាងគេមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៅអាស៊ីខាងកើត នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៤ ឆ្នាំ២០០៨ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅសហរដ្ឋអាមេរិក រួមចុះ ៦,៣% ។ ការធ្លាក់ចុះនេះបណ្តាលជាសំខាន់ពីការរួមចំនែកអវិជ្ជមាននៃ ការនាំចេញ ចំនាយប្រើប្រាស់ផ្ទាល់ខ្លួន វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងលើគ្រឿងបរិក្ខារនិងសូហ្វវែរ ប៉ុន្តែវាមានការប៉ះប៉ូវមួយផ្នែកវិញដោយ ការរួមចំនែកវិជ្ជមាននៃចំណាយរបស់រដ្ឋាភិបាល ។ ក្នុងត្រីមាសនេះដែរ សេដ្ឋកិច្ចនៅតំបន់អឺរ៉ូ ធ្លាក់ចុះយ៉ាងខ្លាំង ដោយកំណើន ផសស ពិត ធ្លាក់ដល់ -១,៣% ហើយមូលហេតុចំបង គឺ ការថយចុះយ៉ាងខ្លាំងនូវតំរូវការទំនិញសំរាប់នាំចេញ និងការថយចុះគួរឱ្យកត់សំគាល់នៃចំណាយប្រើប្រាស់របស់វិស័យឯកជន និងរដ្ឋាភិបាល ។ ផសស ពិតនៅជប៉ុន រួមចុះ ៤,៦% ដោយសារជាសំខាន់ ការថយចុះតំរូវការនៅក្រៅប្រទេស និង ការធ្លាក់ចុះខ្លាំងនូវវិនិយោគលើរោងចក្រថ្មីៗ និងសំភារៈបរិក្ខារ ក្នុងវិស័យឯកជន ។

សម័យកាលកំណើនលេខពីរខ្ទង់របស់ប្រទេសចិន ទំនងជាឈានដល់ទីបញ្ចប់ហើយ ដោយគេសង្កេតឃើញ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំបន្តធ្លាក់ចុះមកត្រឹម ៦,៨% នៅត្រីមាសទី៤ ឆ្នាំ២០០៨ ។ មូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺ ការថយចុះផលិតផលឧស្សាហកម្មសំរាប់នាំចេញ និង ការរួមចុះវិស័យអចលនទ្រព្យ ។ នៅត្រីមាសនេះដែរ ផសស ពិត នៅកូរ៉េខាងត្បូង រួមចុះជាខ្លាំង គឺ ៣,៦% ដោយសារការធ្លាក់ចុះនៃចំណាយរបស់វិស័យឯកជន វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងការនាំចេញទំនិញនិងសេវាកម្ម ។ ហុងកុង និង តៃវ៉ាន់ ក៏ធ្លាក់ចុះសេដ្ឋកិច្ចធ្ងន់ធ្ងរដែរ ដោយ ផសស ពិត ធ្លាក់ចុះអស់ ២,៥% និង ៨,៤% ។ ការធ្លាក់ចុះ ផសស នៅហុងកុង បណ្តាលមកពី ការធ្លាក់ចុះខ្លាំងនៃ ចំណាយប្រើប្រាស់ឯកជន (៣,២%) និង ការកាត់បន្ថយនូវការបង្កើតទ្រព្យមូលធនក្នុងស្រុកដុល (១៧,៣%) ហើយការធ្លាក់ចុះនៅតៃវ៉ាន់ បណ្តាលមកពីការធ្លាក់ចុះយ៉ាងខ្លាំងនៃការនាំចេញទំនិញ និងសេវាកម្ម (១៩,៧៥%) និង ការធ្លាក់ចុះចំណាយប្រើប្រាស់ឯកជន និងការបង្កើតទ្រព្យមូលធនជាប់លាប់ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅម៉ាឡេស៊ី បន្តធ្លាក់ចុះមកត្រឹម ០,១% ។ កត្តាដែលបង្កការធ្លាក់ចុះនេះ គឺ ការរួមចុះយ៉ាងរហ័សនៃផលិតកម្ម និងការបង្កើតទ្រព្យមូលធនជាប់លាប់ដុល ។ កំនើន ផសស ពិត នៅសិង្ហបុរី ក៏ធ្លាក់ចុះដែរ ដោយសារការស្រុតចុះយ៉ាងឆាប់រហ័សនៃផលិតកម្ម ។ កំនើន ផសស ពិតនៅថៃ រួមចុះយ៉ាងខ្លាំង គឺ ៤,៣% ដោយសារ ការនាំចេញសុទ្ធធ្លាក់ចុះអស់ ៣៨,២% ហើយចំណាយវិនិយោគឯកជន ធ្លាក់ចុះអស់ ១០,២% ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ ឆ្នាំ២០០៨ អតិផរណាថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក ធ្លាក់ចុះមកត្រឹម ១,៥% ធៀបនឹង ៥,៣% នៅត្រីមាសមុន ។ ការចុះខ្សោយនៃសំពាធអតិផរណានេះ បណ្តាលមកពីការធ្លាក់ថ្លៃខ្លាំងនៃ ប្រេង និងទំនិញប្រើប្រាស់ផ្សេងទៀត ការចុះថ្លៃជាបន្តបន្ទាប់នៃផ្ទះ និង ការបាក់ស្រុតនូវតំរូវការរបស់អ្នកប្រើប្រាស់ ។ នៅត្រីមាសនេះដែរ អតិផរណារយៈពេល ១២ខែ នៅតំបន់អឺរ៉ូ ធ្លាក់ចុះមកត្រឹម ២,៣% ធៀបនឹង ៣,៨% នៅត្រីមាសមុន ។ អតិផរណានេះ រងឥទ្ធិពលពី ថ្លៃថាមពល និង ការឡើងថ្លៃយឺតជាងមុននៃ ម្ហូបអាហារ ភេសជ្ជៈ ផ្ទះ និង សំលៀកបំពាក់ ។ ថ្លៃទំនិញប្រើប្រាស់សរុបនៅជប៉ុន កើនឡើង ១% ធៀបនឹងកំណើន ២,២% នៅត្រីមាសមុន ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ ដុល្លារUS នៅថេរធៀបនឹងប្រាក់យ៉ុនចិន ប៉ុន្តែវាធ្លាក់ថ្លៃទល់នឹង ដុល្លារហុងកុង និង ប្រាក់យ៉េនជប៉ុន ដោយប្តូរបាន ៧,៧៥ដុល្លារហុងកុង/ដុល្លារUS និង ៩៦,១យ៉េន/ដុល្លារUS ។ ដុល្លារUS ឡើងថ្លៃទល់នឹង ប្រាក់អឺរ៉ូ ប្រាក់វ៉ុនកូរ៉េខាងត្បូង និង ដុល្លារតៃវ៉ាន់ ដោយប្តូរបាន ១,៣២អឺរ៉ូ/ដុល្លារUS ១៣៦៧,២វ៉ុន/ដុល្លារUS និង ៣៣,០ដុល្លារតៃវ៉ាន់/ដុល្លារUS ។ ការឡើងថ្លៃប្រាក់ដុល្លារUS អាចធ្វើឱ្យស្ថានភាពប្រកួតប្រជែងរបស់ប្រទេសចុះខ្សោយ ដោយសារការនាំចេញមានតំលៃថ្លៃជាងមុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

ដោយសារសេដ្ឋកិច្ចពិភពលោកនៅតែបន្តធ្លាក់កំណើន វិស័យកសិកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ទំនងជាមានស្ថានភាពមិនល្អទេ នៅក្នុងរយៈពេលខ្លី ។ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ផលិតផលកសិកម្មចំបងៗបាន ធ្លាក់ថ្លៃគួរឱ្យកត់សំគាល់ ។ បើធៀបនឹងត្រីមាសមុន ពោត (US លេខ២) ធ្លាក់ថ្លៃអស់ ២៨,៩%, ប្រេងឆា (នៅអឺរ៉ុបខាងពាយព្យ) ធ្លាក់ថ្លៃអស់ ៤០,៥%, អង្ករ (Thai 100% B) អស់ ២១,០% និង សណ្តែកសៀង (US លេខ១) អស់ ២៧,៧% ។ នៅត្រីមាសនេះដែរ ប្រេងឆៅ សាំង និង ម៉ាស៊ូត សុទ្ធតែធ្លាក់ថ្លៃ ដោយប្រេងឆៅ លក់ថ្លៃ ៥៩,២២ដុល្លារUS/ធុង, សាំង លក់ថ្លៃ ៣៤,៥២សេន/លីត្រ និង ម៉ាស៊ូត ៤៦,៩៨សេន/លីត្រ ៕

*រៀបរៀងដោយ*
*សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | 13.6 | - | - | - | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | 6.5 | 6.3 | 6.4 | 6.1 | 5.2 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 7.3 | 7.1 | 6.3 | 4.7 | 0.1 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 6.0 | 7.2 | 1.9 | -0.6 | -4.2 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 5.7 | 6.0 | 5.3 | 3.9 | -4.3 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.2 | 10.6 | 10.1 | 9.0 | 6.8 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 6.7 | 6.8 | 4.2 | 1.7 | -2.5 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 5.7 | 5.7 | 4.8 | 3.8 | -3.6 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 6.4 | 6.4 | 4.3 | -1.0 | -8.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 2.2 | 2.2 | 1.4 | 0.6 | -1.3 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 2.0 | 1.3 | 1.0 | -0.5 | -4.6 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 2.5 | 2.5 | 2.8 | -0.5 | -6.3 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 9.6 | 16.5 | 24.9 | 21.7 | 15.7 |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.7 | 7.6 | 10.1 | 11.9 | 11.4 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 2.2 | 2.6 | 4.8 | 8.4 | 5.9 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 4.1 | 6.6 | 7.5 | 6.5 | 5.5 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 2.9 | 5.0 | 7.7 | 7.2 | 2.2 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 10.7 | 16.4 | 24.4 | 29.0 | 23.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 6.6 | 8.0 | 7.8 | 5.3 | 2.5 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 3.5 | 4.6 | 5.7 | 4.6 | 2.3 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 3.3 | 3.7 | 4.8 | 5.5 | 4.5 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 4.5 | 2.3 | 4.2 | 4.5 | 1.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 2.9 | 3.4 | 3.8 | 3.8 | 2.3 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | 0.5 | 1.0 | 1.4 | 2.2 | 1.0 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 3.9 | 4.1 | 4.4 | 5.3 | 1.5 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4026 | 3995.3 | 4030.3 | 4117.4 | 4089.8 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9246.3 | 9248.2 | 9265.3 | 9216.3 | 11,060 |
| ម៉ាឡេស៊ី ( រីងហ្គិត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.35 | 3.22 | 3.21 | 3.37 | 3.56 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.45 | 1.41 | 1.37 | 1.43 | 1.49 |
| ថៃ ( បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 33.87 | 32.37 | 32.25 | 34.0 | 34.83 |
| វៀតណាម ( ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,084 | 15,896 | 16,881 | 16,517 | 16,537 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ុន) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.43 | 7.16 | 6.96 | 6.82 | 6.83 |
| ហុងកុង ( ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.77 | 7.79 | 7.80 | 7.77 | 7.75 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 921.23 | 955.89 | 1018.84 | 1207.0 | 1,367.2 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.4 | 31.52 | 30.45 | 31.20 | 33 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.69 | 0.7 | 0.64 | 0.71 | 1.32 |
| ជប៉ុន ( យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 113.07 | 105.2 | 104.53 | 104.03 | 96.1 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 156.9 | 198.39 | 238.03 | 254.99 | 181.22 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 841.39 | 1048.49 | 1086.89 | 949.03 | 564.50 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 323.92 | 444.43 | 839.58 | 657.88 | 519.41 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 366.59 | 449.64 | 479.97 | 529.30 | 382.72 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 82.88 | 93.77 | 117.48 | 115.30 | 55.23 |
| សាំង - US Gulf Coast ( សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 59.48 | 64.21 | 80.90 | 81.27 | 34.52 |
| ម៉ាស៊ូត ( ស្ពាន់ធ័រតិច លេខ២) - US Gulf Coast ( សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 66.54 | 73.99 | 95.37 | 88.46 | 46.98 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី ៤ ឆ្នាំ២០០៨ អនុមតិគម្រោងវិនិយោគសរុប ថយចុះ ៦៥% មកត្រឹម ១.៥៨០,៣លានដុល្លារ ។ ធៀបនឹងត្រីមាសមុន អនុមតិគម្រោងក្នុងវិស័យកសិកម្ម ធ្លាក់ចុះ ៧៦% មកត្រឹម ៤,៤លានដុល្លារ ចំណែកឯក្នុងវិស័យសេវាកម្ម ក៏ថយចុះ ៧០%មកត្រឹម ១.៣៣៥,៦លានដុល្លារ ។ អនុមតិគម្រោងក្នុងវិស័យឧស្សាហកម្ម កើនឡើង មួយជាបួន ដល់ ៤៨៥,៤លានដុល្លារ ដោយសារជាសំខាន់ អនុមតិគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីស្ទឹងអាតៃ នៅខេត្តពោធិ៍សាត់ ដែលមានតម្លៃដល់ ៤០៨,៣លានដុល្លារ បើទោះបីជាអនុមតិគម្រោងក្នុងវិស័យកាត់ដេរ ធ្លាក់ចុះមកត្រឹម ២១,៤លានដុល្លារក្តី ។ ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជាបានឱ្យដឹងថា ការធ្លាក់ចុះក្នុងអនុវិស័យកាត់ដេរ បណ្តាលឡើងមួយផ្នែកមកពីការធ្លាក់ចុះកំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក ដែលជាទីផ្សារសំរាប់ការលក់ចេញប្រហែលជិត ៧០%នៃផលិតផលកាត់ដេររបស់កម្ពុជា ។ ក្នុងអនុមតិគម្រោងសេវាកម្មសរុប គម្រោងខាងទេសចរណ៍ មាន ៦៣% និងសណ្ឋាគារ ២៤% និងមានគម្រោងមួយចំនួនតូចទៀតសំរាប់ ការតំឡើងប្រព័ន្ធទូរគមនាគមន៍ និងសេវាសាងសង់ ។ អនុមតិគម្រោងគិតជាទ្រព្យសកម្មជាប់លាប់ខាងទេសចរណ៍ មួយភាគធំជាគម្រោងអភិវឌ្ឍកោះនៅខេត្តព្រះសីហនុ និងកោះកុង ដែលភាគច្រើនជាវិនិយោគរបស់ប្រជាពលរដ្ឋកម្ពុជា ។ គម្រោងវិនិយោគ បើអនុវត្តបានទាំងអស់ អាចផ្តល់រហូតដល់ ៣២.៣៨០ការងារ ក្នុងនេះ វិស័យឧស្សាហកម្មមាន ១៥.៤៥៦ការងារ វិស័យសេវាកម្ម មាន ១៥.៦៦៦ការងារ និងវិស័យកសិកម្ម មាន ១.២៥៨ការងារ ។

នៅរាជធានីភ្នំពេញ គម្រោងសាងសង់ចំនួន ៨៧ ដែលមានតម្លៃ ៣៥១,៩លានដុល្លារ ត្រូវបានអនុម័ត នៅត្រីមាសទី៤ ឆ្នាំ២០០៨ ក្នុងនេះ សំរាប់ប្រភេទផ្ទះល្វែង មាន ៣៨គម្រោង (៩៤៧ផ្ទះល្វែង) តម្លៃ ៦០លានដុល្លារ និងសំរាប់ភូមិគ្រឹះនិងផ្ទះ មាន ២៨គម្រោង តម្លៃ ៣៩,៧លានដុល្លារ ។ ធៀបនឹងត្រីមាសមុន តម្លៃសរុបនៃ អនុមតិគម្រោងសាងសង់ ធ្លាក់ចុះ ២៨% ក្នុងនេះ ខាងសំណង់ផ្ទះល្វែង ធ្លាក់ចុះ ៨,៥% រីឯខាងភូមិគ្រឹះនិងផ្ទះ ធ្លាក់ចុះ ២៤% ។ ទោះយ៉ាងនេះក្តី អនុមតិគម្រោងសាងសង់សរុប កើនឡើង ១០៤% ធៀបនឹងត្រីមាសដូចគ្នា ក្នុងឆ្នាំ២០០៧ ក្នុងនេះ សំណង់ផ្ទះល្វែង កើន ៤,២% ហើយសំណង់ភូមិគ្រឹះនិងផ្ទះ កើនយ៉ាងខ្លាំង ដល់ ៩៧% ។

នៅត្រីមាសទី ៤ ការនាំចេញសរុប ធ្លាក់ចុះ ២២% រីឯការនាំចូលសរុប ថយចុះ ១១% បើធៀបនឹងត្រីមាសមុន ។ ដូច្នេះ ឱនភាពពាណិជ្ជកម្ម មានស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងដោយកើនដល់ ១៨៧,៧លានដុល្លារ ធៀបនឹង ៩៨,៤លានដុល្លារនៅត្រីមាសមុន ។ ការស្រុតចុះនៃការនាំចេញ បណ្តាលមកពីការនាំចេញសំលៀកបំពាក់ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៥៦% មកត្រឹម ៦៧៨,៨លានដុល្លារ និងការនាំចេញកៅស៊ូដែលថយចុះ ៥៥% មកត្រឹម ៥,២លានដុល្លារ ។ ការនាំចេញត្រី ពុំមានការប្រែប្រួលទេ ។

ការនាំចូលសរុបបានធ្លាក់ចុះ ដោយសារការនាំចូលផលិតផលប្រេងកាត ថយចុះ ៧,៨% មកត្រឹម ៦២,៩លានដុល្លារ និង សម្ភារៈសំណង់ ថយចុះ ១៦% មកត្រឹម ២៩,៩លានដុល្លារ ក្នុងនេះ ស៊ីម៉ងត៍ ធ្លាក់ចុះ ៧,៨% មកត្រឹម ១០,៥លានដុល្លារ ដែកថែប ធ្លាក់ចុះ ៤,៩% មកត្រឹម ៩,៨លានដុល្លារ និង បរិក្ខារសំណង់ ធ្លាក់ចុះ ៣១% មកត្រឹម ៩,៦លានដុល្លារ ។ ការនាំចូលបារី ធ្លាក់ចុះ ១៤% មកត្រឹម ៣២,៨លានដុល្លារ និងយានយន្ត (រួមទាំងគ្រឿងបន្លាស់) ថយចុះ ១៥% មកត្រឹម ៨៤,៣លានដុល្លារ ។ ចំណែកឯការនាំចូលគ្រឿងស្លៀកពាក់ រួមមានសំលៀកបំពាក់ និងក្រណាត់ កើនឡើង ១២% ដល់ ១៤,៩លានដុល្លារ ។

បន្ទាប់ពីបានធ្លាក់ចុះអស់ ២ត្រីមាសកន្លងមក ចំនួនភ្ញៀវមកដល់កម្ពុជា បានកើនឡើងវិញ ។ នៅត្រីមាសទី៤ ឆ្នាំ២០០៨ ភ្ញៀវមកដល់សរុប មាន ៥៧៧.៥៣៦នាក់ ឬ កើន ៣០% ធៀបនឹងត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ២២% ដល់ ៣១៦.១៦៩នាក់ ដែលក្នុងនោះ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបាន ៤៦% និង អាកាសយានដ្ឋានសៀមរាប ទទួលបាន ៥៤% ។ ភ្ញៀវមកដល់តាមផ្លូវគោក មាន ២៤២.០៥៣នាក់ ឬ កើន ៤១% រីឯភ្ញៀវមកដល់តាមផ្លូវទឹក មាន ១៩.៣១៤នាក់ ឬកើន ៣៦% ។ ភ្ញៀវមកសំរាកលំហែ កើន ១៨% ដល់ ៤៦២.៣៩៩នាក់ ប៉ុន្តែភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ០,៤% ។ កូរ៉េខាងត្បូង ជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៥០.០៩៤នាក់) ហើយបន្ទាប់មក គឺ វៀតណាម (៤៩.៣៨៥នាក់) និង ជប៉ុន (៤២.៨៣៦នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថវិការដ្ឋមានអតិរេក ប៉ុន្តែតពីនោះមក តុល្យភាពថវិកាកាន់តែយ៉ាប់យ៉ឺនឡើងអស់ពេញមួយឆ្នាំ ។ នៅត្រីមាសទី៤ ឱនភាពសរុប មាន ៤៩៥,៩ពាន់លានរៀល ធៀបនឹង ៣៦៥,៨ពាន់លានរៀល នៅត្រីមាសមុន ។ ការប្រមូលប្រាក់ចំណូល និងការចំណាយ បានកើនឡើងដូចគ្នា ។ ការប្រមូលប្រាក់ចំណូល កើន ៣% ដល់ ១៣៣៥,៣ពាន់លានរៀល ក្នុងនោះ ចំណូលពន្ធកើន ៣,២% ដល់ ១១០៥,៧ពាន់លានរៀល ។ ពន្ធក្នុងស្រុកប្រមូលបាន ៧៩៦,៣ពាន់លានរៀល ក្នុងនោះ ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ និង ពន្ធលើតំលៃលើស មាន ១៤៦,៣ពាន់លានរៀល ឬកើន ១១% ។ អាករពិសេសលើទំនិញ កើន ៥,២% ដល់ ២១៨,០ពាន់លានរៀល និង អាករពិសេសលើសេវា កើន ១,៤% ដល់ ៣៤,១ពាន់លានរៀល ចំណែកឯពន្ធទូទៅលើទំនិញនិងសេវា ធ្លាក់ចុះ ១,៤% មកដល់ ៣៩១,០ពាន់លានរៀល ។ ក្នុងការប្រមូលពន្ធទូទៅ ពន្ធលើតម្លៃបន្ថែម មាន ៣៨៦,១ពាន់លានរៀល ឬ ថយចុះ ១,៦% ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ កើន ៥,១% ដល់ ៣០៩,៤ពាន់លានរៀល ដែលក្នុងនោះ ពន្ធលើការនាំចូល កើន ១៤% ដល់ ២៩៤,៧ពាន់លានរៀល ប៉ុន្តែពន្ធលើការនាំចេញ ធ្លាក់ចុះ ៥៩% មកត្រឹម ១៤,៨ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១៧% មកត្រឹម ៣០៩,៤ពាន់លានរៀល ដែលក្នុងនោះ ប្រាក់ចំណូលពីការជួលដីធ្លី និងសហគ្រាសសាធារណៈ ធ្លាក់ចុះ ៧,៦% មកត្រឹម ១០,២ពាន់លានរៀល ។ ចំណូលពីការលក់ទំនិញ និងសេវា រួមទាំងកំរៃរដ្ឋបាល និងចំណូលពីការជួលទ្រព្យវិនិយោគ កើន ១០% ដល់ ១០៩,៨ពាន់លានរៀល ។ ចំណូលមូលធន កើនលើសពីមួយជាបួន រហូតដល់ ៤៩,៣ពាន់លានរៀល ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅត្រីមាសទី៤ ចំណាយសរុប មាន ១៨៣១,២ពាន់លានរៀល ឬកើន ១០% ធៀបនឹងត្រីមាសមុន ។ ជាទូទៅ ចំណាយលើប្រាក់បៀវត្សរ៍ ដែលតាមធម្មតាមានច្រើនបំផុតនៅត្រីមាសទី៤នៃឆ្នាំនីមួយៗ មានចំនួន ៤១៥,៧ពាន់លានរៀល ឬ កើន ១៤% ធៀបនឹងត្រីមាសមុន ។ ឧបត្ថម្ភធនខាងសង្គមកិច្ច និងអំណោយផ្សេងៗ កើនច្រើនជាងមួយជាពីរ ដល់ ៣៨៥,២ពាន់លានរៀល ។ ចំណាយមូលធន កើន ៣៦% ដល់ ៨៧៤,០ពាន់លានរៀល ដោយសាររដ្ឋាភិបាលបង្កើនចំណាយលើការទិញទ្រព្យរូបី និងដីធ្លី ។ ក្នុងចំណាយមូលធនសរុប មាន ១៩% ទទួលបានហិរញ្ញប្បទានពីប្រភពទុនក្នុងស្រុក និង ៨១%ទៀត ពីប្រភពទុនក្រៅប្រទេស ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៤ អតិផរណាពីមួយឆ្នាំទៅមួយឆ្នាំ មានកំរិត ១៥,៨% ធៀបនឹង ២១,៧% នៅត្រីមាសមុន ។ ម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ឡើងថ្លៃ ២៦,១% ។ ការថែទាំសុខភាព ឡើងថ្លៃ ១០,៨% តែចុះទាបជាងត្រីមាសមុន ២,២% ។ អតិផរណាថ្លៃទឹកភ្លើងរបស់គ្រួសារ មានអត្រា ៦,៧% រីទាបជាងត្រីមាសមុន ១,២% ។ ចំណាយប្រចាំថ្ងៃរបស់គ្រួសារ មានអត្រាអតិផរណា ២៦% រីទាបជាងត្រីមាសមុន ១,៤% ។ អត្រាអតិផរណាសំរាប់ការដឹកជញ្ជូន និងទូរគមនាគមន៍ គឺ ៨,០% ធៀបនឹង ២៥,៤%នៅត្រីមាសមុន ។ ក្រសួងផែនការបានឱ្យដឹងថា អតិផរណាបានធ្លាក់ចុះ ដោយសារប្រេងកាតចុះថ្លៃ ហើយការប្រមូលផលកសិកម្ម និងការនេសាទត្រី បានលទ្ធផលល្អ ។

នៅត្រីមាសទី៤ ឆ្នាំ២០០៨ ប្រាក់រៀលឡើងថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារUS បើធៀបនឹងត្រីមាសមុន ដោយប្តូរបាន ៤០៨៩,៨រៀល/ដុល្លារUS ប៉ុន្តែបានធ្លាក់ថ្លៃ ១,៥% បើធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ។ ប្រាក់រៀលឡើងថ្លៃ ៣,៤% និង ១,៨% ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ដោយប្តូរបាន ១១៧,៧រៀល/បាត និង ២៤,៣រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែធ្នូ ២០០៨ ទ្រព្យសកម្មបរទេសសុទ្ធ មាន ១០.៣៤៥,៦ពាន់លានរៀល ឬ ធ្លាក់ចុះ ៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ឥណទានក្នុងស្រុក កើនដល់ ៦៩០៧,១ពាន់លានរៀល ដែលក្នុងនោះ បំណុលរបស់រដ្ឋាភិបាល ធ្លាក់ចុះ ៨,៩% មកត្រឹម ២៧០,៥ពាន់លានរៀល ។ ប្រាក់បញ្ញើរដ្ឋាភិបាល កើនដល់ ៣២៥៧,៥ពាន់លានរៀល ចំណែកឯ ឥណទានដល់វិស័យឯកជន កើន ៥៥% ដល់ ៩៨៩៤,១ពាន់លានរៀល ។

រូបិយវត្ថុទូទៅ (M2) កើនដល់ ១១.៨៥៨,៩ពាន់លានរៀល ធៀបនឹង ១១.៣១០,៧ពាន់លានរៀល នៅខែដូចគ្នា ឆ្នាំមុន ។ ប្រាក់រៀលចរាចរ កើន ១៥% ដល់ ២២៩៤,៨ពាន់លានរៀល ហើយ ប្រាក់បញ្ញើជារៀល កើន ៥៨% ដល់ ២៨៩,៦ពាន់លានរៀល ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើនតិចតួចដល់ត្រឹម ៩២៧៤,៥ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

នៅខែកុម្ភៈ ២០០៩ ក្នុងចំណោមជនងាយរងគ្រោះទាំង ១០ក្រុម មាន ៧ក្រុមមានប្រាក់ចំណូលប្រចាំថ្ងៃពិត ធ្លាក់ចុះ ធៀបនឹងខែវិច្ឆិកា ២០០៨ ។ តាមរយៈលទ្ធផលអង្កេត ក្រុមអ្នកឆ្លើយសម្ភាសន៍នានាយល់ឃើញថា ការធ្លាក់ចុះប្រាក់ចំណូលប្រចាំថ្ងៃពិត បណ្តាលឡើងមួយផ្នែកមកពី វិបត្តិសេដ្ឋកិច្ចសាកល ។

នៅខែកុម្ភៈ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ថយចុះ ៣៤% មកត្រឹម ៨៣៦៦រៀល ធៀបនឹង ១២.៦២៨រៀលនៅខែវិច្ឆិកា ២០០៨ ។ ក្នុងចំនោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ មាន៥០% បាននិយាយថា ប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ ដោយសារចំនួនអ្នកធាក់ស៊ីក្លូកើនឡើង ។ ពួកគាត់ភាគច្រើននិយាយថា ប្រាក់ចំណូលរបស់គាត់ មិនទ្បេងទាត់ឡើយ ហើយបានត្រឹមតែសំរាប់ចិញ្ចឹមជីវិតពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ។ ម្យ៉ាងទៀត មាន ៨២% បញ្ជាក់ថា ពួកគាត់ត្រូវបង់ថ្លៃជួលស៊ីក្លូពី ២០០០ ទៅ ២៥០០រៀលក្នុងមួយថ្ងៃ ទោះបីជាថ្ងៃខ្លះ ពួកគាត់រកប្រាក់សឹងតែមិនបានសោះក្តី ។

ក្នុងចំណោមអ្នករត់ម៉ូតូឌុបដែលឆ្លើយសម្ភាសន៍ មាន ៧៥%មកពីខេត្តផ្សេងៗ ហើយ ៦០% ស្នាក់នៅតាមផ្ទះជួល ។ ពួកគាត់រាយការណ៍ថា ប្រាក់ចំណូលបានធ្លាក់ចុះ ២៧% ធៀបនឹងខែវិច្ឆិកា ២០០៨ ហើយមាន ៧៧,៥% និយាយថា ពួកគាត់មិនអាចសន្សំលុយបានទេ ដោយសារប្រាក់ចំណូលបានធ្លាក់ចុះ ។ ពួកគាត់ត្អូញត្អែរថា ថ្មីៗនេះ មានពេលខ្លះពួកគាត់ស្ទើរតែរកប្រាក់ទិញអាហារមិនបានផង ។

នៅខែកុម្ភៈ ប្រាក់ចំណូលរបស់កម្មករសំណង់មានជំនាញ ថយចុះ ៩% ធៀបនឹងខែវិច្ឆិកា ឆ្នាំមុន ។ ក្នុងចំនោមកម្មករសំណង់មានជំនាញដែលផ្តល់បទសម្ភាសន៍ មាន ៣២,៥% បញ្ជាក់ថា ការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះជាបណ្តោះអាសន្ននៃគម្រោងសាងសង់ និងមាន ៦០% ប្រាប់ថា មានការកាត់បន្ថយចំនួនកម្មករនៅការដ្ឋានមួយចំនួន ដោយសារមានគម្រោងសាងសង់តិច ។ ប្រាក់ចំណូលរបស់ កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៣២% មកត្រឹម ៥៩៩៥រៀល/ថ្ងៃ ធៀបនឹងកាលពីខែវិច្ឆិកា ដោយសារការងារមានមិនទៀងទាត់ គឺពេលខ្លះ គ្មានការងារធ្វើ ឬមានការងារធ្វើមិនពេញមួយថ្ងៃ ។ ម្យ៉ាងទៀត មានកម្មករ ៦២,៥% និយាយថា ចំនួនកម្មករគ្មានជំនាញដែលស្វែងរកការងារសំណង់បានកើនឡើង នៅអំឡុងពេលនេះ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរ ស្ទើរតែគ្មានការផ្លាស់ប្តូរចាប់ពីខែវិច្ឆិកាមក ។ ក្នុងចំណោមកម្មករដែលឆ្លើយសម្ភាសន៍ មាន ៤៩% និយាយថា នៅដើមឆ្នាំ២០០៩ មិនមានការងារបន្ថែមម៉ោងសំរាប់ពួកគេឡើយ ហើយ ៣៦%ទៀតនិយាយថា មានការងារបន្ថែមម៉ោងដែរតែមិនសូវញឹកញាប់ ប៉ុន្តែមាន ១៥% ប្រាប់ថា មានការងារបន្ថែមម៉ោងធ្វើជាទៀងទាត់ ។ កម្មករត្អូញត្អែរថា ការងារបន្ថែមម៉ោងបានកាត់បន្ថយ ហើយចំនួនកម្មករក៏បានកាត់បន្ថយទៀត ដោយសាររោងចក្រកាត់ដេរមួយចំនួនបិទទ្វារ (ក្នុងសំណាករោងចក្រចំនួន ១០ នៃអង្កេត មាន ២រោងចក្របានបិទទ្វារ ) ។ ពួកគាត់បន្ថែមថា នឹងមានការបាត់បង់ការងារកាន់តែ

ច្រើនទៀត ប្រសិនបើការបញ្ជាទិញពីបរទេសនៅតែបន្តធ្លាក់ចុះ ព្រោះវាធ្វើឱ្យរោងចក្រកាន់តែច្រើនត្រូវបិទទ្វារ ។ នេះជាក្ដីបារម្ភមួយធំសំរាប់អនាគតរបស់ពួកគាត់ ពីព្រោះពិបាកស្វែងរកការងារផ្សេងទៀតណាស់ ។

នៅខែកុម្ភៈ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកលក់ដូរតូចតាច ធ្លាក់មកត្រឹម ៧៤៦៤រៀល ធៀបនឹង ៩៨៩៧រៀលកាលពីខែវិច្ឆិកា ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៨០% រាយការណ៍ថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគាត់ធ្លាក់ចុះ ស្របពេលដែលចំនួនអ្នកលក់ដូរតូចតាចកើនឡើង និងមាន ៥០% ទៀតនិយាយថា ពួកគាត់បានខ្ចីលុយពីអ្នកចងការប្រាក់ដើម្បីដំណើរការមុខរបររបស់ខ្លួន ។

នៅខែកុម្ភៈ ២០០៩ អ្នករើសអេតចាយរកចំណូលបានច្រើនជាងកាលពីខែវិច្ឆិកា ២០០៨ ដោយប្រាក់ចំណូលរបស់ពួកគាត់ កើនឡើង ៩% ដល់ ៥០៦៨រៀល/ថ្ងៃ ។ អ្នកឆ្លើយសម្ភាសន៍ ៧៣% បានរាយការណ៍ថា កំណើននេះបានមកពីបរិមាណរបស់អេតចាយកើនឡើង ។ អ្នកឆ្លើយសម្ភាស ៦៤% ជាអ្នកមកពីជនបទជាមួយនឹង ក្រុមគ្រួសារទាំងមូលតែម្ដង ក្នុងនេះមានគ្រួសារ ៣៥% គ្មានដីធ្លីទេ ៥៣% មានដីកសិកម្មត្រឹម ១ហិកតា រឺតិចជាង ហើយ ១២%ទៀត មានដីលើសពី ១ហិកតា ។

ប្រាក់ចំណូលរបស់អ្នកលីសែង កើន ១៤% ដល់ ១០.២៧០រៀល/ថ្ងៃ នៅខែកុម្ភៈ ធៀបនឹងត្រឹម ៩០០៤រៀល/ថ្ងៃ កាលពីខែវិច្ឆិកា ។ អ្នកលីសែងភាគច្រើន និយាយថា ពួកគាត់នៅតែមិនអាចសន្សំលុយ សំរាប់គ្រួសារបានដដែល ព្រោះការចំណាយលើម្ហូបអាហារក៏កើនឡើងដែរ ដល់ ៧០០០រៀល/ថ្ងៃ ៕

*រៀបចំដោយ*

*ប៊ុន ដូរីណា និង ផាន់ ដាលីស*


## Cambodia Development Review—2009 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed............................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed...................................................................................

**International Subscription (Individual)**

❐ Thailand, Laos, Vietnam ❐ English edition ($25)* ❐ Khmer edition ($15)*
❐ Asia and Europe ❐ English edition ($30)* ❐ Khmer edition ($20)*
❐ Americas and Africa ❐ English edition ($35)* ❐ Khmer edition ($25)*

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❐Mr ❐Ms ❐Dr ❐Other ..............................................................................................

First name: ..................................................... Last name: ........................................................ Position: .........................................................

Organisation / Company: ...........................................................................................................................

Address (CCC Box if applicable): ..................................................................................................................

City / Province: .......................................................................................... Country: ..........................................................................................

Telephone: ..................................................................................... Fax: .....................................................................................

e-mail: ..................................................................................................... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 19.1 | 2.1 | 12.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 142.7 | 51.2 | 187.2 | 328.0 | 52.9 | 95.0 | 91.6 | 485.4 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *36.6* | *24.3* | *40.7* | *69.1* | *42.3* | *47.8* | *31.3* | *21.4* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 335.7 | 138.0 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *140.3* | *55.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | -48.8 | -61.6 | 504.7 | -35.9 | -78.1 | 1548.2 | 9.2 | -65.3 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | 118.9 | 91.8 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 14.4 | 22.8 | 21.7 | 20.2 | 45.3 | 17.6 | 52.1 | 39.7 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 88.9 | 33.2 | 117.5 | 57.6 | 40.9 | 55.1 | 65.6 | 60.0 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 35.9 | 88.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 | 252.2 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 139.2 | 144.7 | 179.7 | 172.2 | 137.3 | 140.9 | 486.9 | 351.9 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | 78.0 | 3.9 | 24.2 | -4.2 | -1.4 | 2.6 | 245.6 | -27.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 | -2.6 | 170.9 | 104.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 707.8 | 705.0 | 890.8 | 793.4 | 803.1 | 539.6 | 928.7 | 728.6 |
| រួមមាន: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 677.5 | 688.2 | 846.1 | 727.1 | 773.4 | 463.8 | 868.8 | 678.8 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 8.4 | 6.9 | 11.7 | 14.6 | 7.0 | 11.0 | 12.9 | 5.2 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 2.1 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 0.7 | 0.4 | 1.2 | 0.9 | 0.7 | 0.3 | 0.6 | 0.6 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 790.9 | 911.6 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 |
| រួមមាន: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 66.5 | 68.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 | 62.9 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 154.4 | 44.1 | 31.6 | 34.9 | 32.5 | 39.7 | 40.7 | 35.6 | 29.9 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -83.1 | -208.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 | -187.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | -5.4 | 1.6 | 22.9 | -14.1 | 6.4 | -40.0 | 87.3 | -21.9 |
| ការនាំចេញសរុប | - | - | - | - | -3.9 | 0.4 | 26.4 | -10.9 | 1.2 | -32.8 | 72.1 | -21.5 |
| ការនាំចូលសរុប | - | - | - | - | -2.0 | 15.3 | 1.4 | 6.3 | 0.1 | 19.8 | -12.8 | -10.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 19.2 | 8.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 | -6.6 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 17.3 | 8.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 | -8.2 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 14.5 | 17.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 | -6.8 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 | 262.0 | 259.2 | 316.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 177.2 | 148.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 | 261.4 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 550.8 | 424.5 | 431.8 | 608.0 | 644.2 | 454.0 | 445.5 | 577.6 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | 6.7 | -22.9 | 1.7 | 40.8 | 6.0 | -29.5 | -1.9 | 29.6 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 20.4 | 19.2 | 16.5 | 17.8 | 17.0 | 6.9 | 3.2 | -5.0 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៨ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 699.9 | 887.7 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 |
| ពន្ធក្នុងស្រុក | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 | 955.5 | 776.7 | 796.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 | 299.5 | 294.5 | 309.4 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 125.0 | 124.7 | 186.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 | 53.9 | 11.0 | 10.2 |
| លក់ទំនិញ និងសេវា | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 | 96.3 | 99.7 | 109.8 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 8.3 | 16.2 | 72.0 | 38.5 | 89.6 | 41.9 | 106.4 | 60.3 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 0.0 | 4.5 | 0.0 | 4.5 | 4.8 | 16.5 | 8.7 | 49.3 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 199.7 | 242.7 | 253.4 | 362.6 | 250.7 | 367.0 | 363.6 | 415.7 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 | 325.7 | 111.9 | 385.2 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 295.2 | 254.9 | 402.6 | 325.5 | 193.1 | 403.8 | 442.6 | 345.4 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -99.0 | -81.9 | -78.7 | -543.6 | 135.0 | -281.1 | -365.8 | -495.9 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 344.0 | 313.9 | 290.3 | 741.5 | 299.2 | 615.8 | 435.0 | 705.1 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -245.0 | -213.0 | -148.0 | -185.8 | -294.1 | -236.5 | 234.7 | 168.9 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៨

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 1.1 | 3.9 | 5.8 | 4.7 | 3.0 | 4.6 | 6.0 | 9.7 | 16.5 | 24.9 | 21.7 | 15.7 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.5 | 6.4 | 8.6 | 6.4 | 3.0 | 7.2 | 11.3 | 18.1 | 27.6 | 43.5 | 35.2 | 26.1 |
| - ដឹកជញ្ជូន | 4.9 | 9.7 | 11.4 | 9.1 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 | 25.4 | 8.0 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 113.7 | 118.0 | 130.0 | 129.3 | 129.1 | 125.4 | 121.9 | 117.7 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 24.6 | 24.7 | 25.3 | 25.2 | 25.2 | 24.9 | 24.8 | 24.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 77.7 | 79.8 | 80.8 | 94.4 | 111.6 | 107.7 | 106.0 | 98.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508 | 2088 | 2633 | 3140 | 3067 | 3100 | 3203 | 3679 | 3982 | 4975 | 5495 | 3768.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150 | 2833 | 3442 | 4004 | 3750 | 3900 | 4002 | 4368 | 4580 | 5171 | 5391 | 3861.3 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| | | | | | ពាន់លានរៀល | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4027 | 4797 | 5475 | 7224 | 8056 | 9048 | 9768 | 10,735 | 10,911 | 11,353 | 10,809 | 10,345 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | -263 | -172 | 140 | 576 | 1136 | 1345 | 1748 | 1513.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1176 | -1403 | -1547 | -1816 | -2400 | -2678 | -2653 | -2987 |
| ឥណទានដល់ផ្នែកឯកជន | 1337 | 1817 | 2394 | 3630 | 4066 | 4537 | 5376 | 6386 | 8050 | 9206 | 9781 | 9894 |
| រូបិយវត្ថុទូទៅ M2 | 3329 | 4330 | 5025 | 6942 | 7793 | 8876 | 9908 | 11,311 | 12,047 | 12,698 | 12,557 | 11,858 |
| រូបិយវត្ថុ M1 | 937 | 1153 | 1323 | 1658 | 1794 | 1748 | 1750 | 2052 | 2389 | 2467 | 2335 | 2399 |
| រូបិយវត្ថុផ្សេងៗ | 2392 | 3177 | 3702 | 5285 | 5999 | 7128 | 8158 | 9259 | 9658 | 10231 | 10,223 | 9459 |
| | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 36.5 | 46.8 | 53.4 | 62.9 | 54.5 | 43.1 | 26.7 | 4.8 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 | 41.1 | 33.4 | 16.9 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 40.7 | 57.3 | 66.5 | 75.2 | 61.0 | 43.5 | 25.3 | 2.2 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | 2007 | | 2008 | 2009 | 2007 | 2008 | 2009 |
| | វិច្ឆិកា | | | | វិច្ឆិកា | សីហា | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 7126 | 9393 | 12,628 | 8366 | 27 | 34 | -34 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 7704 | 8852 | 9004 | 10,270 | 26 | 2 | 14 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 9116 | 8303 | 9893 | 7464 | 36 | 19 | -25 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 6038 | 5560 | 4651 | 5068 | 42 | -16 | 9 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4193 | 4508 | 4327 | 4198 | 0 | -4 | -3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4561 | 4790 | 7541 | 6256 | 3 | 57 | -17 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 9033 | 8207 | 7582 | 7617 | -8 | -8 | 1 |
| អ្នករត់ម៉ូតូឌុប | 8610 | 10,092 | 9204 | 8201 | 8386 | 8979 | 11,525 | 15,658 | 11,422 | 37 | 36 | -27 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5901 | 7550 | 8779 | 5995 | 43 | 16 | -32 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 11,723 | 10,956 | 12,710 | 11,539 | 7 | 16 | -9 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

ដែលត្រូវអនុវត្តជាដៃគូជាមួយអង្គការ WorldFish គឺកំពុងលើកមកពិចារណា ហើយគំរោង "ការវាយតំលៃពីឥទ្ធិពលសេដ្ឋកិច្ច-សង្គមកិច្ចនៃមហាអនុតំបន់មេគង្គ" ដែលទទួលមូលនិធិពី ADB ទើបបានចុះកិច្ចសន្យារួចរាល់ ។ គំរោងជាសក្ដានុពលមួយផ្ដោតលើ "ការស្វែងយល់ពីអន្តរកាលកសិកម្មនាពេលខាងមុខនៅអាស៊ី" កំពុងកសាងឯកសារគោលគំនិតដើម្បីសុំថវិកាពីមូលនិធិ Rockefeller ។ គំរោងនេះត្រូវចាប់ដំណើរការ នៅខែកញ្ញា ២០០៩ បើសិនម្ចាស់ជំនួយជ្រើសយក ។

តាំងពីឆ្នាំ២០០៧ មក CDRI បានរៀបចំយ៉ាងទៀងទាត់ក្នុងពីរខែម្ដង នូវសិក្ខាសាលាស្រាវជ្រាវមួយខ្សែ ស្ដីពីបញ្ហាផ្សេងៗខាងអភិវឌ្ឍន៍ ក្នុងគោលដៅចែករំលែកលទ្ធផលស្រាវជ្រាវ និងពង្រឹងគុណភាពស្រាវជ្រាវ តាមរយៈការពិភាក្សា ការកែលំអវិធីសាស្ត្រស្រាវជ្រាវ ព្រមទាំង ការកសាងគោលគំនិត និងការវិភាគលើប្រធានបទនៃការស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសិក្ខាសាលានេះ រួមមាន បុគ្គលិក CDRI អ្នកស្រាវជ្រាវ និង អ្នកអនុវត្តជាក់ស្ដែង មកពីស្ថាប័ននានានៅក្រុងភ្នំពេញ ។ តាំងពីខែមេសា ២០០៩ មក អ្នកធ្វើបទបង្ហាញជាអ្នកស្រាវជ្រាវរបស់ CDRI រួមមាន លោក គីម សុធន, កញ្ញា អ៊ួច ច័ន្ទតារ៉ានី, លោក សាំង ច័ន្ទហង្ស, បណ្ឌិត ហែម សុចិត្ត, លោក អ៊ួ ស៊ីវហួច, លោក លន់ ពិដេ, បណ្ឌិត កុយ រ៉ា និងលោក អែម សូរ៉ានី ។ ប្រធានបទនៃបទបង្ហាញ រួមមាន ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្ម ធនធានធម្មជាតិ និង កសិកម្ម ។

*កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទំរង់វិស័យសាធារណៈ:* គំរោងស្ដីពីការដឹកនាំនៅថ្នាក់មូលដ្ឋានជិតចប់សព្វគ្រប់ហើយ ។ ក្នុងអំឡុងពេលបីខែកន្លងមកនេះ កញ្ញា ធន់ វិមាលា បានរៀបចំអត្ថបទស្រាវជ្រាវបីដាក់បញ្ចូលគ្នា ដោយមានប្រធានផ្នែកស្រាវជ្រាវជួយផ្ដល់យោបល់លើសេចក្ដីព្រាងដំបូង និងទីប្រឹក្សានៃគំរោងជួយផ្ដល់យោបល់បន្ថែមជាសំរេច ។ ក្នុងពេលកន្លងមក គំរោងគ្រប់គ្រងធនធានធម្មជាតិ បានធ្វើការលើករណីសិក្សា ហើយបច្ចុប្បន្នកំពុងបង្ហើយជំពូកនានាដែលនៅសេសសល់ ។ គំរោង ការចូលពាក់ព័ន្ធរបស់អង្គនីតិបញ្ញត្តិជាមួយអង្គការសង្គមស៊ីវិល ដែលទទួលមូលនិធិពីវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស បានបញ្ចប់រួចរាល់ហើយនូវការធ្វើសម្ភាសន៍ និងដំណាក់កាលនានានៃអង្កេត ។ ក្រុមនេះបានបង្ហាញលទ្ធផលស្រាវជ្រាវដំបូងៗសំរាប់ការប្រើប្រាស់ផ្ទៃក្នុង និងសរសេររបាយការណ៍ ដែលគ្រោងបញ្ចប់នៅពាក់កណ្ដាលខែមិថុនា ។ គំរោងផ្ដល់យោបល់ពិគ្រោះ ដល់ គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៃក្រសួងមហាផ្ទៃ ដែលទទួលមូលនិធិពីវិទ្យាស្ថានសិក្សាពីទីក្រុង (Urban Institute) បានដាក់ស្នើឡើងហើយនូវកម្មវិធីថ្នាក់ជាតិ ដូច្នេះក៏បានចប់សព្វគ្រប់ជាគោលការណ៍ ។ គំរោងស្ដីពីនយោបាយប្រាក់កាស និងការអភិវឌ្ឍនៅតំបន់មូលដ្ឋានកម្ពុជា កំពុងដំណើរការទៅមុខ ហើយលោក ប៉ក់ គីមជឿន កំពុងតែសរសេររបាយការណ៍ ។

*កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន:* កម្មវិធីនេះកំពុងបន្តអនុវត្តអង្កេតស្នូលជុំទីពីរ សំរាប់សមាសភាគសេដ្ឋកិច្ច នៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវនិងគ្រប់គ្រងធនធានទឹក (WRMRCDP) ។ ការពិនិត្យវាយតំលៃពាក់កណ្ដាលអាណត្តិសំរាប់ WRMRCDP បានអនុវត្តឡើងដោយ CDRI និងទីប្រឹក្សាឯករាជ្យរបស់ AusAID ដោយមានការផ្ដល់អនុសាសន៍សំដៅជួយកែលំអប្រសិទ្ធភាពអនុវត្តកម្មវិធី ។ ការពិគ្រោះយោបល់ជាមួយដៃគូក្នុងកម្មវិធី និងអ្នកពាក់ព័ន្ធសំខាន់ៗ ក៏បានធ្វើឡើងដើម្បីធានាថា សកម្មភាពនានានៃកម្មវិធី វាជាប់ទាក់ទងល្អទៅនឹងតំរូវការបច្ចុប្បន្នរបស់អ្នកកសាងគោលនយោបាយ ។ វគ្គបណ្ដុះបណ្ដាលមួយស្ដីពី "វិធីសាស្ត្រសិក្សាពីវប្បធម៌ និងជនជាតិ សំរាប់ការគ្រប់គ្រងទឹក" មានការចូលរួមយ៉ាងច្រើនពីអ្នកស្រាវជ្រាវ និងបុគ្គលិកនៃស្ថាប័ននានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក ។

ដោយមានជំនួយពីមជ្ឈមណ្ឌលសំរាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ (CIFOR) ផង កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន បានធ្វើការសំអាតទិន្នន័យសំរាប់គំរោងរួមគ្នាមួយស្ដីពី ព្រៃត្រូពិកសំរាប់ការកាត់បន្ថយភាពក្រីក្រ – ការវិភាគទិន្នន័យពីកំរិតគ្រួសារ ដល់កំរិតសាកល ។ សព្វថ្ងៃកម្មវិធីនេះក៏កំពុងធ្វើឯកសារពិភាក្សាមួយ សំរាប់គំរោងព្រៃឈើត្រូពិកដែរ ។ គំរោងស្ដីពីការកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប ត្រូវបានក្រុមបេសកកម្មមួយរបស់ ADB ជួយពិនិត្យឡើងវិញ និងវាយតំលៃរួចហើយ ។ គំរោងរយៈពេលមួយឆ្នាំមួយស្ដីពីមាគ៌ាមានចីរភាពដើម្បីសំរេចគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ ដែលទទួលមូលនិធិពីវិទ្យាស្ថានបរិស្ថានក្រុងស្តុកហុល បានបង្ហើយរបាយការណ៍ព្រាងដំបូងមួយ និងបានដាក់ឡើងរួចហើយដើម្បីសុំមតិបន្ថែមពីម្ចាស់ជំនួយ ។

*កម្មវិធីអភិវឌ្ឍន៍សង្គម:* ក្នុងកិច្ចសហការជាមួយ វិទ្យាស្ថានគោលនយោបាយអុកស្វដ (OPI) កម្មវិធីអភិវឌ្ឍន៍សង្គមកំពុងអនុវត្តគំរោងពីរដែលទទួលមូលនិធិពីអង្គការ DFID គឺមាន ការសិក្សាមូលដ្ឋានពីអ្នកគ្រប់គ្រងគន្លឹះសំរាប់គំរោងកម្មវិធីជួយទ្រទ្រង់វិស័យសុខាភិបាល និងគំរោង ការផ្ដល់គ្រឿងលើកទឹកចិត្ត និង ការថែរក្សាបុគ្គលិកសុខាភិបាលក្នុងតំបន់ជនបទ និងតំបន់អន់ថយនៅប្រទេសកម្ពុជា ។ គំរោងទាំងពីររំពឹងថា ត្រូវចប់សព្វគ្រប់នៅខែកុម្ភៈ ២០១០ ។ កម្មវិធីនេះក៏មានរៀបចំ សន្និសីទថ្នាក់តំបន់មួយស្ដីពី "បណ្ដាស្ថាប័នក្នុងវិស័យសុខាភិបាល សន្ទះចិត្ត និងការផ្ដល់គ្រឿងលើកទឹកចិត្ត" ដែលគ្រោងដំណើរការនៅក្នុងត្រីមាសទី១ ឆ្នាំ២០១០ ។ ម្យ៉ាងទៀត ក៏មានការពិភាក្សាជាមួយអង្គការ UN Habitat ពីលទ្ធភាពធ្វើការសិក្សារយៈពេលពីរខែពីសុវត្ថិភាពនៅក្រុងភ្នំពេញ សំដៅកែលំអសុវត្ថិភាពប្រជាពលរដ្ឋនៅតាមបណ្ដាសហគមន៍ក្រីក្រ ។

ក្នុងអំឡុងពេលដដែល កម្មវិធីបណ្ដុះបណ្ដាលក្នុងអង្គភាពនេះ បានផ្ដល់វគ្គបណ្ដុះបណ្ដាលមួយចំនួនដល់អ្នកបណ្ដុះបណ្ដាល អ្នកអនុវត្តជាក់ស្ដែង និងអ្នកសារព័ត៌មានមកពីខាងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល និងសមាគមន៍សារព័ត៌មាន ។ វគ្គបណ្ដុះបណ្ដាលទាំងនេះ មានអ្នកចូលរួមសរុបទាំងអស់ ១១១នាក់ និងមានគោលដៅផ្ដល់ឱ្យសិក្ខាកាម ដែលធ្លាប់ទទួលការបណ្ដុះបណ្ដាលពីការកសាងសន្តិភាព និងការគ្រប់គ្រងទំនាស់រួចហើយ នូវជំនាញបន្ថែមលើការបណ្ដុះបណ្ដាល និងការសំរបសំរួល ៕

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

ពីខែមេសា ដល់ មិថុនា ២០០៩ នៅតាមកម្មវិធីនានា នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា មានអនុវត្តសកម្មភាពស្រាវជ្រាវ និងសកម្មភាពពាក់ព័ន្ធមួយចំនួន ដែលមានជាសង្ខេបដូចតទៅ:

*កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់:* របាយការណ៍ចុងក្រោយស្តីពី ការសិក្សាពីជំនួញខាងសេវាកម្ម ត្រូវបានទទួលយកទាំងស្រុង ដោយមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ។ សេចក្តីព្រាងទីពីរស្តីពីការសិក្សាលើសេដ្ឋកិច្ចនយោបាយនៃមហាអនុតំបន់មេគង្គ បានបញ្ចប់រួចរាល់ហើយការសិក្សាមួយទៀតស្តីពី សមត្ថភាពប្រកួតប្រជែងលើដំណាំកៅស៊ូ បានបញ្ចប់សេចក្តីព្រាងរបាយការណ៍ដំបូង និងកំពុងរង់ចាំយោបល់ពីម្ចាស់ជំនួយ ។ ក្រុមអនុវត្តគំរោងសិក្សាពីឌីណាមិកភាពក្រីក្រ កំពុងស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យពីទិដ្ឋភាពផ្សេងៗ នៃបញ្ហាទាក់ទងនឹងភាពក្រីក្រ ។ ការសិក្សាពីវិនិយោគរបស់ចិននៅប្រទេសកម្ពុជា បានទទួលយោបល់មួយចំនួនពីដៃគូក្នុងការសិក្សា ហើយរបាយការណ៍នេះគេកំពុងពិនិត្យឡើងវិញរួមទាំង ករណីសិក្សាប្រាំមួយទៀតដែល មានបញ្ជាក់នៅក្នុងឯកសារលក្ខខណ្ឌយោង ។ សេចក្តីព្រាងរបាយការណ៍ដំបូង នៃការសិក្សាខាងធនធានធម្មជាតិ ពីការទាញប្រយោជន៍បានប្រសើរបំផុតពីឱកាសល្អនៃវិនិយោគរបស់ចិននៅកម្ពុជា បានបញ្ជូនរួចហើយទៅអ្នកផ្តល់ជំនួយ ហើយនឹងត្រូវបញ្ចប់ក្រោយពេលទទួលបានមតិយោបល់មកវិញ ។ បណ្តាញវិភាគអភិវឌ្ឍន៍ទី៨ (DAN-8) ដែលជាគំរោងស្រាវជ្រាវរួមគ្នាមួយ ដើម្បីវាយតំលៃពីឥទ្ធិពលរបស់ចិនក្នុងការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់មេគង្គ បានរីកលូតលាស់ទៅមុខច្រើន នៅពេលដំណើរការសិក្ខាសាលាស្តីពីវិធីសាស្ត្រស្រាវជ្រាវកាលពីថ្ងៃទី ០៥-០៧ ឧសភា ២០០៩ ក្នុងទីក្រុងឈៀងម៉ៃ ប្រទេសថៃ ។ ការវាយតំលៃលឿនពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចលើគ្រួសារនៅកម្ពុជា ដែលជាគំរោងសិក្សាស្រាវជ្រាវរួមគ្នាមួយជាមួយកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍជនបទ (PARD) បានបញ្ចប់សេចក្តីព្រាងរបាយការណ៍ទី២ សំរាប់សមាសភាគទី១ ដែលត្រូវបានដាក់ឡើងដើម្បីសុំយោបល់បន្ថែម ។ ការវាយតំលៃពីឥទ្ធិពលខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃគំរោង GMS នានា ដែលជាគំរោងស្រាវជ្រាវរួមគ្នាមួយរវាង PARD និង កម្មវិធីអភិវឌ្ឍន៍សង្គម និងដែលបានទទួលមូលនិធិពី ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ត្រូវបានចុះហត្ថលេខាសម្រេចរួចរាល់ហើយ ។ គំរោងនេះនឹងមានដំណើរការរហូតដល់ខែកក្កដា ២០១០ ។

*កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ:* គំរោង ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ (PDS) ដោយមានជំនួយពីទីប្រឹក្សាខាងភាពក្រីក្ររបស់ធនាគារពិភពលោក (WB) ផង បានជឿនលឿនទៅមុខច្រើន ក្នុងការកំណត់បន្ទាត់ភាពក្រីក្រ ឯការចាត់ចែងទិន្នន័យបែបគុណភាពក៏អនុវត្តរួចរាល់ហើយសព្វថ្ងៃ កំពុងសរសេររបាយការណ៍បច្ចេកទេសដែលគ្រោងបញ្ចប់នៅចុងខែសីហា ២០០៩ ។ អត្ថបទស្រាវជ្រាវមួយ មានចំណងជើងថា "ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារទៅលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា" ដែលធ្វើសំយោគលើលទ្ធផលបានពីគំរោង PDS បានយកទៅចុះផ្សាយក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩ ។ គំរោងវាយតំលៃលឿនលើផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចលើគ្រួសារនៅកម្ពុជា ដែល WB បានចុះកិច្ចសន្យាឱ្យអនុវត្ត បានបញ្ចប់ការចុះប្រមូលព័ត៌មានដល់កន្លែងឯរបាយការណ៍ព្រាងទី១ បានផ្ញើទៅ WB ដើម្បីសុំយោបល់ត្រឡប់ ។ គំរោង "ការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប: សកម្មភាពជាសមូហភាព និងសមត្ថភាពគ្រប់គ្រងការប្រជែងគ្នាលើធនធាន"

(តទៅទំព័រ ៤៣)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ២ ខែមេសា-មិថុនា ឆ្នាំ២០០៩

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdrimail@online.com.kh

website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: គីម ចិត្រ្តា និង អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: ខេង សេង
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ឱ្យដោយឥតគិតថ្លៃតាមរយៈវេបសាយ: http://www.cdri.org.kh